ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ខ្លឹមសារអត្ថានុរូបនៃ ព្រះរាជបណ្ណាល័យហ្លួងម៉ែ

◆ គម្រោងអភិវឌ្ឍន៍សហគមន៍បុរីអូរស្វាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៩៦ ខែសីហា ឆ្នាំ២០២៤

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### សំបុត្រ


- ខ្លឹមសារអត្ថានុរូបនៃ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ.. ១
- ដំណើរឆ្លងទ្វីប ៖ សារសំខាន់នៃទំនួលខុសត្រូវ.. ៦


### ផ្នែកឯកសារ


- ហ៊ី សុធារី ហៅ ធា ៖ មេក្រុមទូរលេខ .......... ៩


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- គម្រោងអភិវឌ្ឍន៍សហគមន៍បុរីអូរស្វាយ ..... ១៣
- យុវនារីទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ......... ១៥
- មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ចែករំលែករឿងរ៉ាវ ផ្ដល់ព័ត៌មាន ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ... ១៧



- មជ្ឈមណ្ឌលឯកសារកោះថ្ម ផ្ដល់វេទិការួម និងការសជំនួយត្រចៀក ជូនអ្នករស់រានមាន ...... ២០
- មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បន្តផ្ដល់វេទិការួម និងការសជំនួយត្រចៀក ជូនអ្នករស់រានមាន... ២៣
- មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តចែករំលែករឿងរ៉ាវ ជូនដល់អ្នករស់រានមានជីវិតពីរបប...... ២៦
- ការកកើត និងឥទ្ធិពល នៃជាតិនិយម.......... ៣១
- ប្រទេសរ៉្វាន់ដា បានប្រារព្ធខួបលើកទី ៣០ឆ្នាំ .... ៣៥
- ក្រុមអ្នកស្រាវជ្រាវមកពីវិទ្យាស្ថានអប់រំអំពីសិទ្ធិមនុស្សភូមា និងបុគ្គលិកអង្គការពណ៌ឥន្ទធនូ .. ៣៧
- សិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែន បាក់ចិញ្ចៀន ទស្សនកិច្ចសិក្សាតំបន់ប្រវត្តិសាស្ត្រ ......... ៣៩
- មជ្ឈមណ្ឌលឯកសារកម្ពុជា បោះពុម្ពសៀវភៅ «រឿងរ៉ាវក្នុងភូមិនៅសម័យខ្មែរក្រហម» ..... ៤៣
- សាស្ត្រាចារ្យប្រវត្តិសាស្ត្រ និងអ្នកស្រាវជ្រាវជាន់ខ្ពស់វៀតណាម សិក្សាស្រាវជ្រាវអំពី ........ ៤៥
- មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ដល់វេទិការួមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ........... ៤៩




ស្តូបអនុស្សាវរីយ៍បុរីអូរស្វាយ ត្រូវបានកសាងឡើងក្រោមស្នាព្រះហស្ដព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ នៅចន្លោះពីឆ្នាំ១៩៦៣ ដល់ ឆ្នាំ១៩៦៧ ស្ថិតនៅខេត្តស្ទឹងត្រែង ក្នុងព្រះរាជបំណងការពារបូរណភាពទឹកដីនាភាគខាងជើង ដែលជាប់នឹងប្រទេសឡាវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


- សិស្សវិទ្យាល័យស្រែណូយ ទស្សនកិច្ចសិក្សាស្ដីពី «សន្តិភាព និងសិទ្ធិមនុស្ស» .............. ៥១
- នុត ជៀន ៖ ខ្ញុំភ័យខ្លាចចំពោះស្រមោល ..... ៥៤


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


- មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនស្ដីពី ការជម្លៀសប្រជាជន.......... ៥៧
- មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាស្រាវជ្រាវស្ដីពី «ជីវិតរស់នៅប្រចាំថ្ងៃ......... ៦០



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧៥ព.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** ឆាំង យុ, សូ ហ្វារីណា, ស្រេង លីដា, ភា រស្មី, ឈុំ រ៉ា, វី ស៊ីថា, ឡុង ដានី, ទូច វណ្ណេត, ព្រុំ ផល្លា, មេក វិន, ដេង ពង្សរ៉ាស៊ី, សាំង ចាន់ធូ និងលី ដេវីត

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លឹម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ខ្លឹមសារអត្ថានុរូបនៃ ព្រះរាជបណ្ណាល័យហ្លួងម៉ែ

ឆាំង យុ



ប្លង់គោលវិទ្យាស្ថានស្លឹករឹតដែលគូរដោយស្ថាបត្យករ ហ្សាហា ហាឌីត គឺជាស្ថាបនិកក្រុមហ៊ុន ហ្សាហា ហាឌីត មានមូលដ្ឋាននៅប្រទេសអង់គ្លេស។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**ព្រះរាជបណ្ណាល័យហ្លួងម៉ែ** គឺជាសំណង់អគារនិម្មាបនកម្មស៊ីវិល័យ សម័យទំនើប ឈរយ៉ាងស្កឹមស្កៃលើទឹកដីអច្ឆរិយ ក្រោមម្លប់សន្តិភាព នា**សម័យសម្តេចតេជោ** អគ្គមគ្គុទ្ទេសក៍ឯក និងជាស្ថាបនិក នយោបាយឈ្នះ ឈ្នះ នៃកម្ពុជា ជាបុព្វធិការី ដែលយកជីវិតជាដើមទុន ដើម្បីភាពសុខសាន្តត្រាណ និងវឌ្ឍនភាពនៃទឹកដីជាតិមាតុភូមិ និងប្រជាពលរដ្ឋ។ ឆ្លងចូលមកដល់សម័យថ្នាក់ដឹកនាំជាបញ្ញវន្ត ដែលត្រូវបានទទួលស្គាល់ និងគាំទ្រភ្លូកទឹកភ្លូកដីពីប្រជាជាតិខ្មែរនិងបរទេសដែលជាសន្ទានការីប្រកបដោយកតញ្ញូតាប្រាជ្ញាគតិបណ្ឌិត, ព្រះរាជបណ្ណាល័យ ហ្លួងម៉ែជាកញ្ចក់ឆ្លុះឱ្យឃើញនូវសមិទ្ធផលជាសារវន្តដូចខាងក្រោម៖

- ជានិមិត្តរូប នៃការគោរពចំពោះវិញ្ញាណក្ខន្ធបុព្វបុរសខ្មែរគ្រប់ជំនាន់ ដែលបានស្លាប់បាត់បង់ជីវិតដោយសារសង្គ្រាម អាណានិគម សង្គ្រាមស៊ីវិល (សង្គ្រាមមនោគមន៍) និងអំពើប្រល័យពូជសាសន៍

- ជានិមិត្តរូប នៃមនសិការជាតិ ប្រកបដោយកតញ្ញូតវេទី ចំពោះដូនតាខ្មែរ ដែលបានបន្សល់ទុកនូវទឹកដី អរិយធម៌ វប្បធម៌ សាសនា ប្រពៃណី និងសង្គមជាតិ

- ជានិមិត្តរូប នៃបដិការគុណ ចំពោះពលិកម្ម របស់វីរជន យុទ្ធជន ដូនតា និងព្រលឹងអធិធម្មជាតិ

- ជានិមិត្តរូបនៃការការពារសិទ្ធិស្វែងរកយុត្តិធម៌ ជូនជនរួមឈាមដែលបានស្លាប់យ៉ាងអណោចអាធ័ម ក្នុងរបប អាវញ្ញវាសី បីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ

- ជានិមិត្តរូប នៃទស្សីករណ៍សមត្ថភាព គំនិតប្រាជ្ញាញាណ និងពលានុភាព ខេមរា បច្ចាជនជំនាន់ថ្មី (យុវជន) អាចធ្វើបាន

- ជាភស្តុតាង នៃសាមគ្គីភាពក្រោមរដ្ឋធម្មនុញ្ញតែមួយ មហាសេ្ដចក្រតែមួយ រាជរដ្ឋាភិបាលតែមួយ កងកម្លាំងប្រដាប់អាវុធតែមួយ ដើម្បីរក្សាសន្តិភាព និងអភិវឌ្ឍន៍

- ធ្វើនវានុវត្តកម្ម ពីបុព្វការី (មនុស្សជំនាន់មុន) មកសន្តានការី(មនុស្សជំនាន់ថ្មី) ស្របតាមសត្យានុម័តភាពនៃសង្គម ក្នុងបរិបទសកលូបនីយកម្មសង្គម

- ស្តម្ភនៃកិត្យានុភាព ដែលពុំធ្លាប់មានពីបុព្វកាល, ទាំងក្នុងប្រទេសនិងពិភពលោក,ដែលដូនតាបានបន្សល់ ទុកនូវសម្បត្តិបេតិកភណ្ឌឱ្យកូនខ្មែរជំនាន់ក្រោយឯព្រះរាជបណ្ណាល័យ ហ្លួងម៉ែ ជាបណ្តុំឯកសារប្រាជ្ញាស្មារតីសម្រាប់មនុស្សជំនាន់ថ្មី និងជំនាន់បន្តបន្ទាប់

- ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ គឺជារតនសម្បត្តិជាតិដ៏សំខាន់ជាប្រវត្តិសាស្ត្រ។ ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ មិនគួរគ្រាន់តែជានិមិត្តរូបនៃការបែកបាក់របស់ប្រទេសកម្ពុជា ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ នៃអំពើប្រល័យពូជសាសន៍តែប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការអបអរសាទរប្រវត្តិសាស្ត្រដ៏មោទនភាពដែលលាតសន្ធឹងដល់ ព្រះបាទ ជ័យវរ្ម័នទី ២ ដែលបានបង្កើតអាណាចក្រខ្មែរដ៏អស្ចារ្យនៅក្នុងសតវត្សរ៍ទី៩ ។

ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ មានអគារចំនួនប្រាំ ដែលមានឈ្មោះដូចខាងក្រោមនេះ៖

- **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
- **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
- **សម្តេច អគ្គមហាសេនាបតី តេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**
- **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា


His Majesty Preah Bat Samdech Preah Boromneath
NORODOM SIHAMONI
KING of CAMBODIA

To Mr Youk Chhang
Executive Director of the Queen Mother's Library
& the Documentation Centre of Cambodia
Mansion II, street 236, Phnom Penh, Kingdom of Cambodia

Dear Mr Executive Director,

I received with sincere appreciation and deep thanks your letter informing about the meaning of the Queen Mother's Library and its logo.

I wish to convey to you my warm congratulations and full support for your commitment to the establishment of the expanded Queen Mother's Library, which will no doubt fulfil the vision of a national healing memorial for our whole nation.

While paying tribute to the success of your ambitious and beneficial work in the Kingdom of Cambodia, I am confident that the Queen Mother's Library will meet with greater success in the future.

Her Majesty the Queen Mother joins me to wish you every success in your noble endeavours.

Phnom Penh, 15 August 2024

# ខ្លឹមសារអត្ថានុរូបនៃនិមិត្តសញ្ញា ព្រះរាជបណ្ណាល័យហ្លួងម៉ែ

**ព្រះរាជបណ្ណាល័យហ្លួងម៉ែ** គឺជាសមុច្ច័យនិម្មាបនកម្ម នៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងវិទ្យាស្ថានស្លឹករឹត ដែលមិនត្រឹមតែជាបូជនីយដ្ឋានរំឭកមួយប៉ុណ្ណោះទេ។ ក្រោយបញ្ចប់ការសាងសង់ ប្រជាជនកម្ពុជានឹងមានស្ថាប័នជាម៌តកមួយ ដែលដើរតួនាទីជាសារមន្ទីររំឭក, មជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍, និងជាបណ្ណសារផ្ទុកឯកសារអេឡិចត្រូនិច ដោយមុខងារទាំងអស់នេះនឹងស្ថិតនៅក្នុងបរិវេណតែមួយ។ ក្រោយពេលចាប់ផ្ដើមដំណើរការពេញលេញ ព្រះរាជបណ្ណាល័យហ្លួងម៉ែ គឺជាអគារពហុមុខងារមួយ។ ព្រះរាជបណ្ណាល័យហ្លួងម៉ែ នឹងរៀបចំជាសិក្ខាសាលាជាន់ខ្ពស់កម្រិតអន្តរជាតិ និងទស្សនកិច្ចផ្លូវរដ្ឋដោយផ្ដោតជាសំខាន់ទៅលើប្រធានបទលំដាប់ជាតិ និងអន្តរជាតិ។ ព្រះរាជបណ្ណាល័យហ្លួងម៉ែ មានវិសាលភាពនៃគោលបំណង ពហុវិស័យ មានជាអាទិ៍ បដិការគុណ, អារ្យធម៌, មនុស្សជាតិ, ព្រលឹង, សហគមន៍, សេដ្ឋកិច្ច និងសន្តិភាពក្នុងគ្រួសារ បុគ្គល និងមនុស្សជាតិកម្ពុជា។

## ខ្លឹមសារអត្ថានុរូបនៃនិមិត្តសញ្ញា




**កញ្ចក់បីផ្ទាំង** — កញ្ចក់បីផ្ទាំងដែលយកចេញពីទម្រង់ស្តូបអនុស្សាវរីយ៍បុរីអូរស្វាយ ខេត្តស្ទឹងត្រែង។ ស្តូបអនុស្សាវរីយ៍បុរីអូរស្វាយនេះ ត្រូវបានសាងសង់ឡើងនៅឆ្នាំ១៩៦៣ ដល់ឆ្នាំ១៩៦៧ ក្រោមស្នាព្រះហស្តព្រះបរមរតនកោដ្ឋ ក្នុងព្រះរាជបំណងការពារបូរណភាពទឹកដីនាភាគខាងជើង ដែលជាប់នឹងប្រទេសឡាវ។ លើស្តូប មានព្រះឆាយាល័ក្ខណ៍៤ បែរទៅទិសធំៗទាំង៤ បង្ហាញពីព្រះរាជសកម្មភាពព្រះបរមរតនកោដ្ឋ។ ស្តូបនេះមានរាងអដ្ឋកោណ ប្រសិនបើមើលចំផ្ទៃណាមួយនោះ នឹងឃើញផ្ទៃទៀតអមសងខាង ដែលតំណាងឱ្យកញ្ចក់ពីរ បីផ្ទាំងដែលកំពុងឆ្លុះបញ្ចាំងអំពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។

**ស្លឹករឹត និងដែកចារ** — ស្លឹករឹតបុរាណៈ គឺជាអ្នកថែរក្សា ចំណែកដែកចារជាអ្នកកត់ចំណាំ។ ទាំងពីរនេះពុំអាចឃ្លាតគ្នាបានឡើយ ខ្វះមួយណាក៏មិនបាន។ ស្លឹករឹត និងដែកចារជានិមិត្តរូបដ៏សំខាន់មួយ ដែលបានដើរតួនាទីចូលរួមថែរក្សាកេរ្តិ៍មតក, វប្បធម៌, ទំនៀមទម្លាប់ និងប្រពៃណីតាំងពីបុរាណកាលមកម្ល៉េះតាមរយៈសំណេរ។ ស្លឹករឹតបុរាណៈ និងដែកចារ គឺជានិមិត្តរូបសំខាន់ដែលតំណាងឱ្យ "បញ្ញា និងចំណេះដឹង" ដែលជាអ្នកបណ្ដុះ បំភ្លឺដល់កុលបុត្រ កុលធីតាខ្មែរជំនាន់

ក្រោយ ឱ្យមានចំណេះវិជ្ជា មានសេចក្តីថ្លៃថ្នូរ ជាប្រយោជន៍ដល់សង្គមជាតិគ្រប់ជំនាន់។

**ក្បាច់អង្គរ (អតីតកាល)** — ទម្រង់ក្បាច់អង្គរតែងតែឃើញមាននៅលើប្រាង្គប្រាសាទបុរាណ មានទម្រង់ក្បូចបត់ចុះឡើងទៅតាមរូបរាងផ្សេងៗ គួបផ្សំជាមួយពណ៌សម្បុរថ្មប្រាសាទដែងនោះ ហាក់បីដូចជាធម្មជាតិ ឬ រុក្ខជាតិដែលមានសភាពក្រៀមក្រោះ មានភាពសោកសៅនឹងរឿងអ្វីមួយ។ ការប្រកាន់ឆ្វេង សំដៅលើភាពអវិជ្ជមាន, អយុត្តិធម៌, ភាពលំអៀង, មិនល្អត្រឹមត្រូវ។ ដូច្នេះក្បាច់ភ្ញីទេសស្ថិតនៅខាងឆ្វេង ជាតំណាងឱ្យភាពមិនល្អនៃរឿងអតីតកាលដែលកន្លង ផុតជាយូរមកហើយ តែនៅបន្សល់ការចងចាំរហូតដល់បច្ចុប្បន្ន។

**ក្បាច់ភ្ញីទេស (អនាគតកាល)** — ភ្ញីទេសជាទម្រង់ក្បាច់ដែលកម្លាយចេញពីរុក្ខជាតិពិត រត់ជាចង្វាយព័ទ្ធឡើងទៅតាមរៀងផ្សេងៗ មានដើម, ស្លឹក, ត្រួយ, ផ្កា, ផ្លែជាដើម មើលទៅហាក់បីដូចជារុក្ខជាតិពិត។ ភ្ញីទេសសំដៅលើភាពស្រស់បំព្រង, ភាពចម្រុងចម្រើន, រីកលូតលាស់ ជឿនលឿនតទៅមុខជានិរន្តរ៍។

ការប្រកាន់ស្តាំ គឺសំដៅលើភាពវិជ្ជមាន, យុត្តិធម៌, ភាពល្អបរិសុទ្ធ, ភាពត្រឹមត្រូវ។ ក្បាច់ភ្ញីទេសស្ថិតនៅខាងស្តាំ ជាតំណាងឱ្យការអភិវឌ្ឍ នាំឱ្យមានភាពចម្រុងចម្រើន, លូតលាស់តទៅថ្ងៃអនាគត ផ្តល់ឱ្យកូនចៅជំនាន់ក្រោយទទួលបាន សេចក្តីសុខសប្បាយ និងមោទកភាព។

**ផ្កាចម្ប៉ា** — ផ្កាចម្ប៉ាជាផ្កាមួយប្រភេទក្នុងចំណោមប្រភេទផ្កាទាំងអស់ដែលហ្លួងម៉ែទ្រង់សព្វព្រះរាជហឫទ័យ តែងតែដាក់ថ្វាយព្រះបរមរតនកោដ្ឋ។ កាលដែលដាក់និមិត្តរូបផ្កាចម្ប៉ាក្នុងបណ្តុំផ្កាកុលាបនេះមានន័យជាការនឹករឭកមិនដាច់អាល័យពីព្រះបរមរតនកោដ្ឋ។

**ផ្កាកុលាបស** — ផ្កាកុលាបពណ៌ស គឺជាផ្កាមួយប្រភេទក្នុងចំណោមប្រភេទផ្កាទាំងអស់ ដែលហ្លួងម៉ែទ្រង់សព្វព្រះរាជហឫទ័យជាងផ្កាដទៃទៀត។ ផ្កាកុលាបពណ៌ស បញ្ជាក់អត្ថន័យនៃភាពស្មោះត្រង់, បរិសុទ្ធ, គ្មានកំហុស និង ការចាប់ផ្តើមជាថ្មី។ បើយោងតាមអត្ថបទក្នុងគេហទំព័រ ធីតាតូរី បកប្រែចេញពីឯកសារបរទេស ផ្កាកុលាបពណ៌ស បង្ហាញដល់សេចក្តីស្រឡាញ់ដែលស្រស់ស្អាត, ល្អបរិសុទ្ធ, គួរឱ្យចង់ថ្នាក់ថ្នម ដោយមិនគិតទេថាក្តីស្រឡាញ់ដែលប្រគល់ឱ្យនោះបានការតបស្នងប៉ុណ្ណា/ឬអត់។ កុលាបពណ៌ស ត្រូវបាននិយមប្រើដើម្បីបង្ហាញពីក្តីស្រឡាញ់ស្មោះសររបស់ខ្លួនដូចជាកូនចៅជូនចៅហ្វាយនាយ, សិស្សជូនគ្រូបាធ្យាយ, កូនជូនឪពុកម្តាយ។

**ក្រឡាស់អាវ និងខ្សែរបូ** — ក្រឡាស់អាវ គឺជាគ្រឿងលម្អលើអម្ពរពស្ត្រារបស់ព្រះមហាក្សត្រ ដែលគ្រងគ្រង់ព្រះឱរា ខាងឆ្វេង រាល់ពេលមានព្រះរាជពិធីធំៗ។ ក្រឡាស់អាវនេះ គឺជានិមិត្តរូបនៃក្តីស្រឡាញ់, មេត្តាអាណិត, សន្តោសប្រោសប្រណីនៃព្រះមហាក្សត្រ ដែលអត្ថន័យពណ៌ជាម្ចប់ដីត្រជាក់ទៅដល់ប្រជានុរាស្ត្រ ដែលជាកូនចៅ ចៅទួត។ រីឯខ្សែរបូ ក្រវាត់ព័ទ្ធជុំវិញកញ្ចក់ទាំងបីផ្ទាំងជាតំណាងឱ្យសេចក្តីស្រឡាញ់របស់ព្រះមហាក្សត្រនៅគ្រប់ស្ថានការណ៍ ទាំងអតីតកាល, បច្ចុប្បន្នកាល និងអនាគតកាល។

**កម្រាលព្រំ** — កម្រាលព្រំ តំណាងឱ្យការអណ្តែតឡើងនូវកិត្តិនាម, ភាពល្បីរន្ទឺ, ភាពខ្ពង់ខ្ពស់ឧត្តុងឧត្តម ការលើកបង្ហាញឱ្យសកលលោកបានឃើញ, បានដឹង, និងបានស្គាល់។

**ព្រះបាទ សម្តេចព្រះ បរមនាថ**
**នរោត្តម សីហមុនី**
**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

**ជូនចំពោះ លោក ឆាំង យុ**
*នាយកព្រះរាជបណ្ណាល័យ ហ្វូងម៉ែ*
*និងមជ្ឈមណ្ឌលឯកសារកម្ពុជា*
*ភូមិគ្រឹះលេខ១១ ផ្លូវ២៥៦ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា*

*ខ្ញុំពិតជាមានព្រះហឫទ័យសោមនស្សរីករាយ និងសូមថ្លែងអំណរគុណចំពោះលិខិតរបស់លោក ទូលថ្វាយអំពីព្រះរាជអត្ថន័យ និងនិមិត្តសញ្ញារបស់ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ។*

*ខ្ញុំសូមសម្តែងអំណរសាទរ និងការគាំទ្រពេញទំហឹងចំពោះការប្តេជ្ញាចិត្តរបស់លោក ក្នុងការបង្កើតនិងពង្រីកព្រះរាជបណ្ណាល័យ ហ្វូងម៉ែ ដែលដោយពុំមានមន្ទិលសង្ស័យ គឺជាកេរដំណែលនៃការសះស្បើយផ្លាក់ជាតិសម្រាប់ប្រជាជាតិរបស់យើងទាំងមូល។*

*ក្រៅពីសម្តែងការកោតស្ញប់ស្ញែងចំពោះជោគជ័យនៃការងារប្រកបដោយតម្លៃជាសារវន្តនិងឧត្តមគតិយ៉ាងមោះមុតរបស់លោក សម្រាប់ព្រះរាជាណាចក្រកម្ពុជា ខ្ញុំជឿជាក់ថា ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ ប្រាកដជាអាចសម្រេចបានជោគជ័យយ៉ាងធំធេងនាពេលអនាគត។*

*សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសន្តិភាព និងខ្ញុំផ្ទាល់ សូមជូនពរលោកឲ្យសម្រេចបានជោគជ័យនូវរាល់ភារកិច្ចដ៏ប្រពៃរបស់លោក។*

*រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤*

# ដំណើរឆ្លងទ្វីប ៖
## សារសំខាន់នៃទំនួលខុសត្រូវកម្រិតបុគ្គលក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ

*សូ ហ្វារីណា*



រូបពីឆ្វេងទៅស្តាំ៖ ១) អ្នកស្រី សុភ័ក្ត្រ ភាណា ប្រធានគម្រោងស្រាវជ្រាវភាសាចិននៃមជ្ឈមណ្ឌលឯកសារកម្ពុជា, ២) អ្នកស្រី សូ ហ្វារី នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា, ៣) អ្នកស្រី អាលីស វ៉ៃរីមូ ឌឺរីទូ អគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជាទីប្រឹក្សាពិសេស ទទួលបន្ទុកការទប់ស្កាត់អំពើប្រល័យពូជសាសន៍, ៤) វ៉ាគិន, ៥) លោក ឈឹម ពៅ បុគ្គលិកផ្នែកព័ត៌មានវិទ្យានៃមជ្ឈមណ្ឌលឯកសារកម្ពុជា និង ៦) វ៉ាគិន ចូលរួមសន្និសីទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រោមប្រធានបទ «ការស្តាប់ និងការដឹកនាំ» ដែលធ្វើឡើងរយៈពេល៣ថ្ងៃ ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៤ នៅទីក្រុងគីហ្គាលី ប្រទេសរ៉្វាន់ដា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លោកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា មានមោទកភាពក្នុងការរៀបរាប់ពីការអង្កេតរបស់លោកស្រី ក្នុងថ្ងៃដំបូងនៃសន្និសីទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រោមប្រធានបទ«ការស្តាប់ និងការដឹកនាំ» ដែលធ្វើឡើងរយៈពេល៣ថ្ងៃ ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៤ នៅទីក្រុងគីហ្គាលី ប្រទេសរ៉្វាន់ដា។ ថ្ងៃដំបូងនៃសន្និសីទរួមមាន សុន្ទរកថាបើក ដោយអ្នកឧបត្ថម្ភកម្មវិធីភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិរួមមាន ប្រធានក្រុមប្រឹក្សាភិបាល Aegis Trust, ឯកអគ្គរដ្ឋទូតស៊ុយអែតប្រចាំប្រទេសរ៉្វាន់ដា, ទីប្រឹក្សាពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍, រដ្ឋមន្ត្រីឯកភាពជាតិរ៉្វាន់ដា, ជំនួយការអគ្គនាយកអង្គការយូណេស្កូស្តីអំពីការអប់រំ, សង្គម






លោក ប៊ីល គ្លីនតុន អតីតប្រធានាធិបតីសហរដ្ឋអាមេរិក និងអ្នកស្រី អាលីស វ៉ៃរីមូ ឌីរីទូ អគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជាទីប្រឹក្សាពិសេស ទទួលបន្ទុកការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ថ្លែងសុន្ទរកថានៅក្នុងសន្និសីទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រោមប្រធានបទ «ការស្តាប់ និងការដឹកនាំ» ដែលធ្វើឡើងរយៈពេល៣ថ្ងៃ ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៤ នៅទីក្រុងគីហ្គាលី ប្រទេសរ៉្វាន់ដា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស៊ីវិលដែលពាក់ព័ន្ធ និងស្ថាប័នជាច្រើនទៀត។ លើសពីនេះ អតីតប្រធានាធិបតីសហរដ្ឋអាមេរិក លោកវិល្លៀម ជេ គ្លីនតុន ក៏បានថ្លែងសុន្ទរកថាតាមវីដេអូពីចម្ងាយ។

ក្នុងចំណោមកម្មវិធីសំខាន់ៗនៃថ្ងៃដំបូង សន្និសីទបានប្រកាសជាផ្លូវការនៃការបង្កើតវិទ្យាស្ថានសន្តិភាព Isōko ដែលនឹងបម្រើជាមជ្ឈមណ្ឌលអប់រំស្តីពីសន្តិភាពក្នុងតំបន់ និងសកលរបស់ប្រទេសរ៉្វាន់ដា។ កម្មវិធីថ្ងៃនេះគឺពោរពេញទៅដោយវគ្គពិភាក្សាដែលផ្តោតលើការអប់រំសន្តិភាព និងសារសំខាន់នៃការអត់ឱនទោស និងការផ្សះផ្សា។ អ្នកសម្របសម្រួលវគ្គនេះបានអញ្ជើញអ្នកចូលរួមឱ្យឡើងសម្តែងជាតួ ឬអនុវត្តផ្ទាល់នៅលើឆាក ស្តីពីការអត់ឱន និងបង្ហាញពីស្ថានភាព ឬកម្រិតនៃការអត់ឱននៅក្នុងប្រទេសរ៉្វាន់ដា ដើម្បីជាការបើកឆាកទៅកាន់វគ្គមានពិតប្រាកដរបស់ជនរងគ្រោះ និងជនដៃដល់ដែលបានបង្ហាញជាឧទាហរណ៍ជាក់ស្តែង។ ក្រុមអ្នកនៅរស់រានមានជីវិតចំនួនជាង១០នាក់ ដែលមកពីភូមិផ្សះផ្សា វើរូ (Rweru Reconciliation Village) បានចែករំលែកបទពិសោធន៍ដែលគាត់ និងក្រុមគ្រួសារបានជួបប្រទះក្នុងអំឡុងពេលអំពើកាប់សម្លាប់ ដែលស្គាល់ថា ជាអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិទុតស៊ីបានកើតឡើង។ បន្ទាប់ពីរៀបរាប់ពីបទពិសោធន៍រួច អ្នករស់រានមានជីវិតទាំងនោះ បានរៀបរាប់ប្រាប់អំពីមូលហេតុ និងកត្តាជំរុញ ដែលនាំឱ្យគាត់សុំការអត់ឱនទោសពីជនរងគ្រោះ និងការដែលគាត់បានអត់ឱនឱ្យជនដៃដល់ផ្ទាល់។

ការពិភាក្សា និងការអត់ឱនទោស នៅក្នុងបរិបទប្រទេសរ៉្វាន់ដា ពឹងផ្អែកយ៉ាងខ្លាំងទៅលើគោលគំនិតនៃភាពជាអ្នកដឹកនាំ និងសាសនា ប៉ុន្តែសំខាន់ជាងនេះទៅទៀត មជ្ឈមណ្ឌលទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅបានជំរុញកិច្ចការនេះ ដោយផ្តោតលើការអប់រំ ការសន្ទនា និងការទទួលខុសត្រូវកម្រិតបុគ្គល។ ទំនួលខុសត្រូវបុគ្គលអាចត្រូវបានអនុវត្តតាមវិធីជាច្រើន ដែលមួយចំនួនត្រូវបានស្វែងយល់នៅក្នុងថ្ងៃដំបូងនៃសន្និសីទ។ សម្រាប់មនុស្សម្នាក់ ការស្វែងរក និងការលើកលែងទោស គឺជាទង្វើរបស់បុគ្គលផ្ទាល់ខ្លួនដែលជាមូលដ្ឋានខ្ពស់បំផុត ព្រោះវាអាចជួយដល់ការព្យាបាល សន្តិភាព និងការផ្លាស់ប្តូរនៅកម្រិតគ្រួសារ សមូហភាព និងជាតិ។ ដូចដែលបានពន្យល់ក្នុងអំឡុងសន្និសីទ ការអត់ឱនអាចកើតឡើងតាមរយៈទម្លាប់រស់នៅសាមញ្ញរាល់ថ្ងៃ។ ឧទាហរណ៍មួយដែលបានលើកឡើងគឺមានជនដៃដល់សុំការអភ័យទោសពីជនរងគ្រោះដោយផ្ញើលិខិតសុំទោសទៅគ្រួសារជនរង

គ្រោះផ្ទាល់។

សន្និសីទនេះផ្សាភ្ជាប់ជាមួយ ទំនួលខុសត្រូវបុគ្គល ដែលត្រូវបានប្រកាសដោយ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានប្រសាសន៍ថា «យើងត្រូវចងចាំថា កាតព្វកិច្ចនៃលើកកម្ពស់ការអប់រំអំពើប្រល័យពូជសាសន៍គឺជាការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា មិនមែនត្រឹមតែរដ្ឋាភិបាលទេ។ សន្និសីទលើកទី១ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ដែលបានរៀបចំឡើងនៅប្រទេសកម្ពុជាកាលពីថ្ងៃទី២០-២២ ខែឧសភា ឆ្នាំ ២០២៤ គឺជាគំរូដ៏ល្អនៃកិច្ចសហប្រតិបត្តិការ និងសាមគ្គីភាពដ៏ល្អរវាងភាគីពាក់ព័ន្ធនានា។ ខ្ញុំសូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានជួយដល់រាជរដ្ឋាភិបាលក្នុងការរួមបញ្ចូលការបង្រៀនអំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ទៅក្នុងការអភិវឌ្ឍវិជ្ជាជីវៈ និងស្ថាប័ននិងក្នុងការផ្សព្វផ្សាយសកម្មភាពក្នុងសង្គមជាតិ និងអន្តរជាតិ ដោយប្រើប្រាស់ប្រវត្តិសាស្ត្រដើម្បីឆ្លុះបញ្ចាំង និងបំផុសគំនិតដើម្បីអភិវឌ្ឍន៍អនាគតនៃប្រទេសកម្ពុជា»។

សន្និសីទដែលរៀបចំឡើងដោយប្រទេសរ៉្វាន់ដា និងសន្និសីទដែលបានរៀបចំឡើងដោយប្រទេសកម្ពុជា គឺជាការខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់ការទទួលខុសត្រូវបុគ្គល ដែលជាការទទួលខុសត្រូវរួម។ ទំនួលខុសត្រូវបុគ្គលបាននាំទៅដល់ទំនួលខុសត្រូវជារួម ហើយនឹងធ្វើឱ្យមានការយល់ដឹងអំពីកាតព្វកិច្ចជាតិ និងអន្តរជាតិ។ ការងាររបស់យើងត្រូវតែផ្តោតជានិច្ចលើការទទួលខុសត្រូវរួម ថ្នាក់ជាតិ និងអន្តរជាតិ ប៉ុន្តែយើងក៏មិនត្រូវភ្លេចដែរថា ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅចាប់ផ្តើម និងបញ្ចប់ដោយការទទួលខុសត្រូវកម្រិតបុគ្គល។ បុគ្គលគ្រប់រូបមានតួនាទីក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មដ៏ឃោរឃៅ ហើយជួនកាលឧបសគ្គដ៏ធំបំផុតក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មដ៏ឃោរឃៅនៅកម្រិតជាតិ និងអន្តរជាតិ អាចត្រូវបានយកឈ្នះដោយការអនុវត្តការប្តេជ្ញាចិត្តដ៏លើសលប់នៅកម្រិតបុគ្គល។ ពាក្យស្លោកដែលយើងតែងតែរំឭក «មិនត្រូវឱ្យរឿងនេះកើតឡើងម្តងទៀត» គឺផ្តោតសំខាន់លើកាតព្វកិច្ចបុគ្គល ក៏ដូចជាជាតិ និងអន្តរជាតិ។

កិច្ចពិភាក្សារវាងជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ និងរាគ្និន នៅក្នុងសន្និសីទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ក្រោមប្រធានបទ «ការស្តាប់ និងការដឹកនាំ» ដែលធ្វើឡើងរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៤ នៅទីក្រុងគីហ្គាលី ប្រទេសរ៉្វាន់ដា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# ហ៊ី សុធារី ហៅ ធា ៖ មេក្រុមទូរលេខមន្ទីរកងពល៨០១

**ជាវ៉ារដ្ឋ មេត្តា**



*យោធាខ្មែរក្រហមឈរអមសងខាងរថក្រោះនៅសមរភូមិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ហ៊ី សុធារី ហៅ ធា អាយុ២៧ឆ្នាំ (ក្នុងឆ្នាំ១៩៧៧) នៅលីវ។ ខ្ញុំកើតនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៥០ នៅភូមិអង្គរកា ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ ហ៊ី លីម និង ម្ដាយឈ្មោះ ទូច ផន។ នៅឆ្នាំ១៩៥៨ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាអង្គរកា ចាប់ពីថ្នាក់ទី១២ដល់ថ្នាក់ទី៧ (សង្គមចាស់)។ នៅឆ្នាំ១៩៦៥ ខ្ញុំរៀននៅអនុវិទ្យាល័យអង្គតាសោម ចាប់ពីថ្នាក់ទី៦ ដល់ថ្នាក់ទី៤។ នៅឆ្នាំ១៩៦៨ ខ្ញុំរៀននៅវិទ្យាល័យព្រះខទ័យតាកែវក្រុង គឺចាប់ពីថ្នាក់ទី៣ដល់ថ្នាក់ទីបញ្ចប់។ នៅឆ្នាំ១៩៧០ ខ្ញុំបន្តមករៀននៅវិទ្យាល័យព្រះយុគន្ធរ ក្នុងក្រុងភ្នំពេញ។ ពីឆ្នាំ១៩៧១ ដល់ ឆ្នាំ១៩៧៣ ខ្ញុំគឺជានិស្សិតមហាវិទ្យាល័យច្បាប់និងសេដ្ឋកិច្ច ហើយខ្ញុំបានជួបប្រទះការលំបាកក្នុងជីវភាពយ៉ាងខ្លាំងពីព្រោះឪពុកម្ដាយខ្ញុំពុំអាចផ្ដល់លុយកាក់ពីស្រុកកំណើតមកឱ្យខ្ញុំនៅភ្នំពេញបាន។

នៅខែមិថុនា ឆ្នាំ១៩៧១ ខ្ញុំទៅសុំការងារធ្វើក្រៅក្របខ័ណ្ឌ នៅក្រសួងឃោសនាការ លន់ នល់។ ឈ្មោះ ស៊ិន គិមស៊ុយ អតីតសាស្ត្រាចារ្យចាងហ្វាងវិទ្យុបានយល់ព្រមឱ្យខ្ញុំធ្វើការ។ នៅទីនោះខ្ញុំមានតួនាទីគឺជាអ្នកបកប្រែព័ត៌មានពីកាសែតអាកាប៉េ

(AKP) ភាសាបារាំងមកភាសាខ្មែរសម្រាប់វិទ្យុផ្សាយ សំឡេង លន់ នល់។ មួង ស៊ីនួន ជាសាស្ត្រាចារ្យ គឺជានាយករៀបចំព័ត៌មានសម្រាប់វិទ្យុ បានណែនាំការងារជាប្រចាំដល់ខ្ញុំ។ ក្នុងរយៈពេលធ្វើការងារជាមួយ ស៊ិន គិមស៊ុយ និង មួង ស៊ីនួន គឺអ្នកទាំងពីរបានយកចិត្តទុកដាក់ផ្តល់លុយកាក់មកឱ្យខ្ញុំ ហើយបានអប់រំខ្ញុំដូចតទៅ៖ ១) ផ្នែកសីលធម៌រស់នៅ ៖ គឺបាននាំខ្ញុំដើរកម្សាន្ត ផឹកស៊ី និងមានស្រីស្រា។ ២) ផ្នែកមនោគមវិជ្ជា ៖ បានបំពាក់មនោគមវិជ្ជានាយទុនដែលមានរបបសេដ្ឋកិច្ចសេរីនិយមជាគ្រឹះ។ ៣) ផ្នែកនយោបាយជាតិ ៖ បានពន្យល់ណែនាំខ្ញុំឱ្យជឿ និងឱ្យយល់ថាខ្មែរក្រហម គឺជាពួកខ្ញុំយួនកុម្មុយនីស្ត ព្រមទាំងលើកពីផែនការហូជីមិញស្តីពីកុម្មុយនីស្តឥណ្ឌូចិន។ ដូច្នេះ បើចូលខ្មែរក្រហមគឺមានន័យថាឱ្យយួនលេបទឹកដីខ្មែរ។ ដោយសារខ្ញុំសេពគប់ជាមួយ និងភាពប៉ិនប្រសប់អប់រំរបស់ ស៊ិន គិមស៊ុយ និង មួង ស៊ីនួន ទាំងផ្នែកមនោសញ្ចេតនា និងមនោគមវិជ្ជាតាមរូបភាពពិភាក្សាពីបញ្ហាសង្គមជាតិ ធ្វើឱ្យខ្ញុំជឿស្លុង និងគោរពតាមគាត់។

នៅខែកញ្ញា ឆ្នាំ១៩៧១ មួង ស៊ីនួន ហៅខ្ញុំទៅជួបនៅផ្ទះ ស៊ិន គិមស៊ុយ ដោយបានសម្រេចខ្ទេសនាមខ្ញុំចូលក្នុងជួរយុជនអង្គការ សេ-អ៊ី-អា។ បន្ទាប់ពីមានការទទួលស្គាល់ខ្ញុំទទួលភារកិច្ច៖ ១) សរសេរអត្ថបទនយោបាយផ្សាយតាមវិទ្យុក្នុង «នាទីឆ្លើយពាក្យ តបពាក្យឃោសនារបស់ខ្មែរក្រហម និងយួនកុម្មុយនីស្ត» តាមគម្រោងដែល ស៊ិន គិមស៊ុយ ដាក់ឱ្យ។ ២) តាមដានចលនាខ្មែរក្រហមក្នុងអង្គការសមាគមសិស្សនិស្សិតក្រុងភ្នំពេញ។ ៣) ឃោសនាអប់រំយុវជនឱ្យស្អប់ខ្ពើមខ្មែរក្រហម និងចាត់តាំងឱ្យធ្វើសកម្មភាពប្រឆាំងនឹងខ្មែរក្រហម។ ៤) ធ្វើសកម្មភាពបំផ្លិចបំផ្លាញអង្គការបដិវត្តន៍តាមគ្រប់រូបភាព។ ៥) បង្កប់ខ្លួនស៊ើរូងផ្ទៃក្នុងអង្គការបដិវត្តន៍ដើម្បីចូលរួមធ្វើសកម្មភាពកម្ទេចរបបកុម្មុយនីស្តពីសង្គមកម្ពុជាដាច់ខាត។

នៅខែកុម្ភៈ ឆ្នាំ១៩៧២ មួង ស៊ីនួន ខ្ទេសនាមខ្ញុំឱ្យស្គាល់ឈ្មោះ ឡុច សឿន អតីតនិស្សិតអក្សរសាស្ត្រ ហើយក្រោយថ្ងៃទី១៧ ខែមេសា នៅក្រសួងរោងពុម្ពរដ្ឋ។ ក្រោយមក ឡុច សឿន ហៅ ដាវ ណែនាំខ្ញុំឱ្យស្គាល់ឈ្មោះ ខៀវ សិរីវឌ្ឍន៍ ហៅ វ៉ាង អតីតនិស្សិតមហាវិទ្យាល័យច្បាប់និងសេដ្ឋកិច្ច និងជាប្រធានរោងចក្រអគ្គិសនីផ្សារតូច។ ចាប់តាំងពីខែមីនា ដល់ ខែកក្កដា ឆ្នាំ១៩៧២ អង្គការបដិវត្តន៍បានបំផុសឱ្យយុវជនសិក្សាក្រុងភ្នំពេញ ធ្វើចលនាកូដកម្មមិនព្រមចូលរៀន ដោយវាយប្រហារថ្កោលទោសលើរបបយោធានិយម ហ្វាស៊ីរបស់ លន់ នល់ ដែលពុករលួយ ចូលដៃជើងជាមួយ ឈ្មួញចិន និងបរទេសដំឡើងថ្លៃទំនិញធ្វើឱ្យជីវភាពប្រជាជនក្រីក្ររស់នៅយ៉ាងដុនដាប។

នៅខែកុម្ភៈ ឆ្នាំ១៩៧៣ ខ្ញុំ, ខៀវ សិរីវឌ្ឍន៍, ដួង គីមហុង ត្រូវបាននិស្សិតមហាវិទ្យាល័យច្បាប់-សេដ្ឋកិច្ចជ្រើសតាំងឱ្យដឹកនាំសមាគមនិស្សិតមហាវិទ្យាល័យច្បាប់-សេដ្ឋកិច្ច។ គុណ ថុនថាណាក់, ពែក អន ដឹកនាំសមាគមនិស្សិតមហាវិទ្យាល័យអក្សរសាស្ត្រ។ ជួប រ៉ែត ដឹកនាំសមាគមនិស្សិតមហាវិទ្យាល័យគរុកោសល្យ។ មាស សារិន ដឹកនាំសមាគមនិស្សិតមហាវិទ្យាល័យកសិកម្មចំការដូង។ ឡុច សឿន បានចូលទៅក្តាប់សមាគមបុគ្គលិកសិក្សា។ ស្បោង រុន ហៅ រិទ្ធិ អតីតសាស្ត្រាចារ្យ អនុប្រធានមន្ទីរកងពល៨០១។ នួន យឿន ហៅ ផន់ អតីតសាស្ត្រាចារ្យចេញទៅជនបទឆ្នាំ១៩៧៣ អង្គការបញ្ជូនទៅតំបន់ព្រះវិហារ។ ផាត់ ស៊ីផូ ហៅ ផែន អតីតវិស្វករសាស្ត្រាចារ្យបច្ចេកទេស ក្រោយរំដោះទូទាំងប្រទេសមកនៅក្រសួងសាធារណការ។ នួន យឿន, ទូន សុខផល្លា អតីតវិស្វករ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅក្រសួងសាធារណការ។ នៅថ្ងៃទី១៧ ខែមីនា មីទ្ទេញមហាជនមួយដ៏ធំបានកើតឡើងតាមទិសដៅក្នុងកងកម្លាំងប្រដាប់អាវុធដោយបាញ់រះ និងបោកគ្រាប់បែកទៅលើហ្វូងមហាជន។

នៅចុងខែមីនា ឆ្នាំ១៩៧៣ ខៀវ សិរីវឌ្ឍន៍ និង ឡុច សឿន ចាត់តាំងខ្ញុំបង្កប់ខ្លួនស៊ើរូងផ្ទៃក្នុងអង្គការបដិវត្តន៍នៅជនបទ ដោយខ្ទេសនាមខ្ញុំទៅឱ្យនីរ សារ

នាំមកមន្ទីរប្រចាំការទាក់ទងក្រុងនៅកណ្ដាលស៊ឹង តំបន់១៥ ខាងត្បូងផ្លូវជាតិលេខ៤។ ខៀវ សិរីវឌ្ឍន៍ បានខទ្សេសនាមខ្ញុំជាមួយឈ្មោះ សុខ គឺជាគណៈក្រុងភ្នំពេញ។ នៅខែមេសា ឆ្នាំ១៩៧៣ សុខ បានខទ្សេសនាមខ្ញុំឱ្យមកកាន់មន្ទីរភូមិភាគពិសេសខាងត្បូងភ្នំពេញ។ ខែឧសភា អង្គការបានឱ្យខ្ញុំមកមន្ទីរទទួលភ្ញៀវចេញពីក្រុងភ្នំពេញ នៅក្រាំងក្ដិប តំបន់១៥ ខាងជើងផ្លូវជាតិលេខ៤។ នៅខែមិថុនា អង្គការចាត់តាំងខ្ញុំមកកាន់តេអូ ក្ដាប់សភាពការណ៍យោធាទាហាន ប្រចាំមន្ទីរយោធា៣១១ ភូមិភាគពិសេសខាងជើងផ្លូវជាតិលេខ៤។

នៅខែសីហា ឆ្នាំ១៩៧៣ មកដល់ខែមីនា ឆ្នាំ១៩៧៤ ខ្ញុំរាយការណ៍ផ្ដល់ចំណុចបោះទីតាំងទ័ពរបស់កងទ័ពបដិវត្តន៍នៅចន្លោះភ្នំបាសិតបែកចានជាបន្តបន្ទាប់ដល់ សុខ។ យន្តហោះនិងកាំភ្លើងធំទាហានបានធ្វើសកម្មភាពទម្លាក់ និងផ្ដក់គ្រាប់យ៉ាងខ្លាំងតាមចំណុចដែលខ្ញុំផ្ដល់ទៅឱ្យ សុខ។ ខែមីនា ឆ្នាំ១៩៧៤ ខ្ញុំរាយការណ៍ពីផែនការវាយកាត់ផ្ដាច់ផ្លូវជាតិលេខ៤ ម្ដុំអង្គស្នួល ទៅឱ្យសុខ។ ចាប់ពីខែមេសា ឆ្នាំ១៩៧៤ ដល់ខែមិថុនា ឆ្នាំ១៩៧៤ គឺជាវគ្គនៃសមរភូមិឧដុង្គ, កំពង់ហ្លួង-ពាមសេដ្ឋា។ ខ្ញុំទទួលបានការចាត់តាំងពីកែវ ឱ្យទាក់ទងជាមួយយន្តហោះទាហាន ដើម្បីផ្ដល់ចំណុចដែលត្រូវទម្លាក់គ្រាប់បែកដាក់លើខ្សែត្រៀម និងត្រៀមកាំភ្លើងធំផ្ដក់ដាក់លើកងទ័ពបដិវត្តន៍។ ខ្ញុំបានទាក់ទងជាមួយយន្តហោះចំនួន៥លើក ហើយបានឃើញយន្តហោះទាហានមកទម្លាក់គ្រាប់បែកនិងកាំភ្លើងធំផ្ដក់លើខ្សែត្រៀមកងទ័ពបដិវត្តន៍តាមចំណុចដែលខ្ញុំផ្ដល់ឱ្យ។ ប៉ុន្តែក្រៅពីថាទម្លាក់ដាក់ត្រូវចំៗកន្លែងកំណត់ កែវ ពុំបានប្រាប់ខ្ញុំពីលទ្ធភាពនៃការខូចខាតសម្ភារនិងកម្លាំងប្រយុទ្ធរបស់កងទ័ពឱ្យខ្ញុំបានដឹងឡើយ។

នៅខែកក្កដា ឆ្នាំ១៩៧៤ អង្គការចាត់តាំងខ្ញុំឱ្យមកកាន់តេអូ ក្ដាប់សភាពការណ៍យោធា ប្រចាំមន្ទីរកងពល១៨។ ខ្ញុំបានទាក់ទងរាយការណ៍ឱ្យ សុខ បន្តទៀត។ ខ្ញុំប្រាប់ សុខ ថា នៅរដូវវស្សានេះកងទ័ពបដិវត្តន៍នៅមុខសញ្ញាពាយ័ព្យក្រុងភ្នំពេញសម្រាកពីព្រោះហត់ហេវខ្លាំងពីសមរភូមិឧដុង្គ, កំពង់ហ្លួង-ពាមសេដ្ឋា ហើយគ្មានផែនការវាយធំទេ មានតែផែនការវាយឈ្លប និងវាយពិសេស។ ខ្ញុំបានផ្ដល់ចំណុចបោះទីតាំងកងទ័ពបដិវត្តន៍ម្ដុំភ្នំបាសិត ទួលលាប និង បែកចាន។ ក្រៅពីនេះ ខ្ញុំឃើញមានប្រតិកម្មពីកងទ័ពបើកប្រតិបត្តិការសឹកមកភ្នំត្នោតពងនៅខែសីហា ឆ្នាំ១៩៧៤។ នៅខែធ្នូ ឆ្នាំ១៩៧៤ ខ្ញុំបានរាយការណ៍ប្រាប់ សុខ អំពីវគ្គវាយសម្រុកធំផ្ដាច់ទីក្រុងភ្នំពេញនៅដើមរដូវប្រាំង ឆ្នាំ១៩៧៥ និងប្រាប់អំពីផែនការវាយនៅមុខសញ្ញាពាយ័ព្យក្រុងភ្នំពេញដែលខ្ញុំក្ដាប់បានតាមការពិភាក្សាគ្នារបស់គណៈកងពល។ ខ្ញុំក្ដាប់បានកម្លាំងប្រយុទ្ធ មុខសញ្ញាវាយ ប៉ុន្តែថ្ងៃបើកសមរភូមិខ្ញុំក្ដាប់មិនបានទេ។ ខ្ញុំបានប្រាប់ សុខ ថាជាការប្រមូលផ្ដុំកម្លាំងទ័ពរបស់ភូមិភាគនៅឧដុង្គរួមជាមួយកងពលលេខ១៨ ភូមិភាគពិសេស និងរួមជាមួយកងពលភូមិភាគនិរតី ដែលបែកមុខសញ្ញាគ្នាវាយតាំងពីអង្គស្នួល បែកចាន ទួលលាប បាសិត ភូមិធំ ត្រពាំងព្រាយ ពាមសេដ្ឋា។

នៅខែមីនា ឆ្នាំ១៩៧៥ កងពលបានចាត់តាំងឱ្យខ្ញុំចុះជាប់នឹងវរសេនាធំ កែវ សារឿន ពេលដែលកងទ័ពបដិវត្តន៍បានឆ្លងផុតទំនប់កប់ស្រូវមកដល់ឃ្មុញ។ កងវរសេនាធំ កែវ សារឿន បានមកដល់ឃ្មុញ ហើយខ្ញុំគឺជាជំនួយការភូមិសាស្ត្រឱ្យ កែវ សារឿន ព្រោះអង្គការកងពលយល់ឃើញថា ខ្ញុំស្គាល់ភូមិសាស្ត្រម្ដុំនោះ និងវត្តភ្នំ។ កែវ សារឿន ប្រាប់ខ្ញុំថា ទាហានបាក់ខ្លាំងណាស់ ទោះបីជាដាក់ផែនការមិនឱ្យកងទ័ពរំកិលខ្សែត្រៀមក៏គ្មានផលអ្វីដែរ ក្រុងភ្នំពេញ ពិតជាត្រូវរំដោះឆាប់ៗព្រោះទាហាននាំគ្នារត់ចូលក្រុងជាបន្តបន្ទាប់។ ភ្នំពេញក៏ត្រូវបានរំដោះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នៅខែឧសភា ឆ្នាំ១៩៧៥ សុខ ហៅខ្ញុំមកជួបនៅមហាវិទ្យាល័យគរុវិជ្ជាជាន់ខ្ពស់។ សុខ បានណែនាំខ្ញុំឱ្យចេញពីកងពល១៨មកប្រមូលផ្ដុំគ្នាក្ដាប់កម្មករនៅក្រោមការគ្រប់គ្រងរបស់គាត់។ នៅខែមិថុនា ឆ្នាំ១៩៧៥ ខ្ញុំបានមកនៅជាមួយ សុខ។ សុខ ប្រាប់ខ្ញុំថា បន្ទាប់ពីដំណើរការមួយរយៈ គឺអង្គការ

បានដករោងចក្រទាំងអស់ប្រគល់ទៅឱ្យក្រសួងឧស្សាហកម្ម។ សុខ ទទួលខុសត្រូវតែផ្នែករោងចក្រទឹក និងរោងចក្រអគ្គិសនីប៉ុណ្ណោះ។ នៅខែកក្កដា ឆ្នាំ១៩៧៥ សុខ ក៏បានខ្ទេសនាមឱ្យខ្ញុំមកនៅជាមួយ ខៀវ សិរីវឌ្ឍន៍ ប្រធានរោងចក្រអគ្គិសនីផ្សារតូច ហើយ ខៀវ សិរីវឌ្ឍន៍ ក៏បានចាត់តាំងខ្ញុំដឹកនាំកម្មករដើរធ្វើភ្លើង។ ខ្ញុំដឹកនាំកម្មករធ្វើការផ្សារបានរយៈពេល១ខែ ក្នុងខែសីហា សុខ បានហៅខ្ញុំមកជួបនៅសាលាគរុវិជ្ជាជាន់ខ្ពស់។ សុខ បានណែនាំថា ឥឡូវនេះអង្គការបដិវត្តន៍ត្រូវការពួកបញ្ញជន និស្សិតទៅតាមក្រសួង។ ដូច្នេះ គាត់អាចខ្ទេសនាមក្រុមខ្ញុំឱ្យទៅបង្កប់ខ្លួននៅតាមក្រសួង។ ក្រោយមក សុខ បានខ្ទេសនាមខ្ញុំមកកាន់ស្ថានីយវិទ្យុស្ទឹងមានជ័យ។ មិនបានរយៈពេល១ខែ សុខ បានហៅខ្ញុំមកនៅជាមួយគាត់វិញ។ នៅខែកញ្ញា ឆ្នាំ១៩៧៥ ដដែល ខ្ញុំត្រឡប់មកនៅជាមួយ សុខ ហើយគាត់ឱ្យខ្ញុំសម្រាកមួយរយៈខ្លីដើម្បីរង់ចាំភារកិច្ចថ្មី។ នៅខែតុលា ឆ្នាំ១៩៧៥ សុខ បានខ្ទេសនាមខ្ញុំមកនៅកងពល៨០១ អតីតកងពល១៨។ សុខ ប្រាប់ខ្ញុំឱ្យរង់ចាំទទួលការណែនាំភារកិច្ចជាក់ស្តែងពី កែវ សារឿន ផ្ទាល់។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ខ្ញុំជាប់រៀនសូត្រនយោបាយរបស់អង្គការបដិវត្តន៍។ នៅខែធ្នូ ឆ្នាំ១៩៧៥ កងពល៨០១ បានចេញដំណើរមកនៅខេត្តរតនគិរី។

នៅខែមករា ឆ្នាំ១៩៧៦ ខ្ញុំបានមកដល់ខេត្តរតនគិរី។ ខ្ញុំបានជួបជាមួយ កែវ សារឿន នៅបានលុង ពេលខាងកងពលហៅគាត់មកប្រជុំ។ កែវ សារឿន ប្រាប់ខ្ញុំថា ពុំទាន់មានភារកិច្ចអ្វីទេ ព្រោះកងទ័ពទើបមកដល់ ហើយកំពុងរៀបចំកន្លែងបោះទ័ព។ នៅខែមីនា ឆ្នាំ១៩៧៦ បន្ទាប់ពីរៀបចំទីតាំងទ័ពហើយ កងទ័ពក៏ចុះរានដីធ្វើស្រែចម្ការ ហើយពេលនោះជំងឺគ្រុនចាញ់ក៏ចាប់ផ្តើមរាតត្បាតខ្លាំងមកលើកងទ័ពបដិវត្តន៍ដែរ។ កែវ សារឿន បានប្រាប់ខ្ញុំនៅបានលុងឱ្យចាប់ផ្តើមធ្វើសកម្មភាពបណ្តើរៗដើម្បីឱ្យកងពល៨០១បាត់ម្ចាស់ការ។ នៅខែកក្កដា ឆ្នាំ១៩៧៦ កែវ សារឿន ឡើងជាសមាជិកកងពល។ កែវ សារឿន បានហៅខ្ញុំទៅជួបដើម្បីណែនាំពីសកម្មភាព សេ-អ៊ី-អា ដែលដាក់ផែនការផ្តួលរំលំរដ្ឋអំណាចបដិវត្តន៍។ កែវ សារឿន បានឱ្យខ្ញុំដឹងថាភារកិច្ចដែលគាត់ទទួលបានគឺរៀបចំកម្លាំងវាយកងពលលេខ៨០១។ កម្លាំងដែលបានរៀបចំគឺជាកម្លាំងដែល កែវ សារឿន ខំកសាងបាននៅក្នុងកងពល៨០១ ហើយមានកម្លាំងយួន សេ-អ៊ី-អា ដែលបង្កប់ខ្លួននៅតាមព្រំដែន ក្នុងដីយួនជួរខាងមុខបរកែវចូលរួមសហការដែរ។ នៅខែធ្នូ ឆ្នាំ១៩៧៦ កែវ សារឿន ចេញមកភ្នំពេញ។

នៅខែមករា ឆ្នាំ១៩៧៧ ខ្ញុំត្រូវឈ្មោះ ស៊ិន ហៅទៅណែនាំការងារបន្តពី កែវ សារឿន។ ស៊ិន បានហៅខ្ញុំទៅជួបនៅមន្ទីរពេទ្យ៨០៥ នៅផ្ទះគ្រួសាររបស់ ស៊ិន។ នៅខែកុម្ភៈ ឆ្នាំ១៩៧៧ ខាងយួនបានរាយការណ៍ថា មានភាពលំបាកស្មុគស្មាញក្នុងការស៊ើបពិនិត្យទីតាំងនៅសាលាខោង និងអូរតាងពីព្រោះលំបាកឆ្លងព្រំដែន ដោយសារជួបនឹងកងចល័តការពារព្រំដែនរបស់កងទ័ពបដិវត្តន៍ និងមានព្រៃក្រាស់ផង។ នៅចុងខែមីនា ឆ្នាំ១៩៧៧ ខ្ញុំត្រូវកងពលដកភារកិច្ចពីផ្នែកទូរលេខ។ បន្ទាប់មកខ្ញុំត្រូវបានមន្ទីរកងពលចាត់តាំងឱ្យកាប់ចម្ការសម្រាប់អង្គភាពកងពល។ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៧៧ កងពលបញ្ជូនខ្ញុំពីរតនគិរីមកកាន់ភ្នំពេញ។ នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៧ ខ្ញុំត្រូវបានអង្គការចាប់ខ្លួនតែម្តង។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខJ០០១១៨។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ហ៊ី សុធារី ហៅ ធា ពិតប្រយ៉ាងណានោះទេ?***

# គម្រោងអភិវឌ្ឍន៍សហគមន៍បុរីអូរស្វាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ស្រេង លីជា




លោក លី មីណា អភិបាលនៃគណៈអភិបាលស្រុកបុរីអូរស្វាយសែនជ័យ បានទទួលស្វាគមន៍ឯកឧត្តម សរ សុពុត្រា អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង និងគណៈប្រតិភូនៃដំណើរទស្សនកិច្ចមហាជន និងយុវជនខេត្តស្ទឹងត្រែងមកទស្សនកិច្ចសិក្សាស្រុកបុរីអូរស្វាយសែនជ័យ ជាប់ព្រំដែនប្រទេស ឡាវ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៤ លោក លី មីណា អភិបាលនៃគណៈអភិបាលស្រុកបុរីអូរស្វាយសែនជ័យ បានទទួលស្វាគមន៍ឯកឧត្តម សរ សុពុត្រា អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង និងគណៈប្រតិភូ នៃដំណើរទស្សនកិច្ចមហាជន និង យុវជនខេត្តស្ទឹងត្រែងមកកាន់ស្រុកបុរីអូរស្វាយសែនជ័យ។ ឆ្លៀតក្នុងឱកាសនៃដំណើរទស្សនកិច្ចនេះ លោក លី មីណា អភិបាលនៃគណៈអភិបាលស្រុកក៏បានធ្វើបទបង្ហាញស្តីពីគម្រោងអភិវឌ្ឍន៍សហគមន៍បុរីអូរស្វាយ ដែលជាគំនិតផ្តួចផ្តើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គាំទ្រដោយ ទីភ្នាក់ងារអភិវឌ្ឍន៍សហប្រតិបត្តិការ និងសម្របសម្រួលរបស់ស្ថានទូតតួកគី ហៅកាត់ថា (TİKA) ប្រចាំនៅប្រទេសកម្ពុជា។ នៅក្នុងបទបង្ហាញលោក លី មីណា បានរៀបរាប់ថា គម្រោងអភិវឌ្ឍន៍សហគមន៍បុរីអូរស្វាយ គ្រោងនឹងសាងសង់បណ្ណាល័យអូរស្វាយសែនជ័យចំនួន១ខ្នង, ដែបណ្តែតទឹកចំនួន៨ និងទូកចម្លងចំនួន៨ សម្រាប់ជួយសម្រួលប្រជាជនក្នុងការឆ្លងពីកោះមួយទៅកោះមួយទៀត និងប្រើប្រាស់ក្នុងសហគមន៍។

កន្លងមកគម្រោងអភិវឌ្ឍន៍សហគមន៍បុរីអូរស្វាយ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះស្រាវជ្រាវអំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម, រៀបចំវេទិកា

អប់រំអំពីសុខភាព និងផ្ដល់សេវាពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន៣លើករួចមកហើយ ដែលក្នុងនោះមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៦០០នាក់ ទទួលបានសេវាពិនិត្យសុខភាពដោយគិតថ្លៃដោយគ្រូពេទ្យជំនាញ នៅទីតាំងមណ្ឌលសុខភាព ព្រះនរោត្តម សីហនុរាជា និងសម្ដេចព្រះវររាជមាតា នរោត្តម មុនីនាថ សីហនុ អូរស្វាយ ស្ថិតនៅក្នុងឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ លើសពីនេះ គម្រោងអភិវឌ្ឍន៍សហគមន៍បុរីអូរស្វាយ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានផ្ដល់រទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព ដើម្បីជួយសម្រួលដល់ការធ្វើដំណើរប្រចាំថ្ងៃ និងទុក្ខលំបាករបស់គាត់ដែរ។








លោក លី មីណា អភិបាលនៃគណៈអភិបាលស្រុកបុរីអូរស្វាយសែនជ័យ បានទទួលស្វាគមន៍ឯកឧត្តម សរ សុពុត្រា អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង និងគណៈប្រតិភូនៃដំណើរទស្សនកិច្ចមហាជន និងយុវជនខេត្តស្ទឹងត្រែង មកទស្សនកិច្ចសិក្សាស្រុកបុរីអូរស្វាយសែនជ័យ ជាប់ព្រំដែនប្រទេស ឡាវ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៤។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យុវនារីទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញសុខភាពសហគមន៍ ក្រោមប្រធានបទ

## «ស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង»

***មីន សាណាស់***

មជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ផ្ដើមគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៅឆ្នាំ២០២១ និងបានជ្រើសរើសអ្នកស្ម័គ្រចិត្តកម្ពុជាមកពីទូទាំងប្រទេសចំនួន៣៨៦៨នាក់ (គិតត្រឹមឆ្នាំ២០២៤) ឱ្យចុះជួបសួរសុខទុក្ខ និងសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អំពីបញ្ហាប្រឈមផ្នែកសុខភាព និងរឿងរ៉ាវជីវិតឆ្លងកាត់របបខ្មែរក្រហម នៅក្នុងភូមិឃុំដែលខ្លួនកំពុងរស់នៅ។ កញ្ញា កើត សុរចនា គឺជាអ្នកស្ម័គ្រចិត្តកម្ពុជាម្នាក់ មកពីខេត្តស្វាយរៀង ក្នុងចំណោមអ្នកស្ម័គ្រចិត្តកម្ពុជានៅទូទាំងប្រទេស ដែលត្រូវបានជ្រើសរើសឱ្យធ្វើការងារស្ម័គ្រចិត្ត និងជួយដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងសហគមន៍របស់ខ្លួន។ ដោយសារការព្យាយាមលើការងារស្ម័គ្រចិត្ត ការប្ដេជ្ញាចិត្ត និងចង់បន្តការសិក្សា កញ្ញា កើត សុរចនា ក៏បានទទួលអាហារូបករណ៍លើមុខវិជ្ជា «សុខភាពសហគមន៍» នៅសាកលវិទ្យាល័យអន្តរជាតិ ពីគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។



កើត សុរចនា អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបរិញ្ញាបត្រជាន់ខ្ពស់ជំនាញសុខភាពសហគមន៍ពីសាកលវិទ្យាល័យអន្តរជាតិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្មីៗនេះ កញ្ញា កើត សុរចនា បានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកសុខភាពសហគមន៍ ដោយកញ្ញា កើត សុរចនា បានស្រាវជ្រាវលើនិក្ខេបបទ «ស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង»។ មូលហេតុដែលកញ្ញា កើត សុរចនា លើកយកបញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកសិក្សា

ដោយសារតែរហូតមកដល់សព្វថ្ងៃនេះ ប្រជាជនកម្ពុជាប្រមាណជា៥លាននាក់ ដែលបានរួចរស់ជីវិតពីរបបខ្មែរក្រហម នៅតែប្រឈមជាមួយបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្ត ព្រមទាំងផលប៉ះពាល់ពីរបបខ្មែរក្រហម។ កញ្ញា កើត សុរចនា បានប្រមូលទិន្នន័យ ឬសំណាក ពីប្រជាជនចំនួន៦០នាក់ ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅភូមិតាកឹង ឃុំព្រៃធំ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង និងបានរកឃើញថាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មានជំងឺប្រចាំកាយចំនួន៩ប្រភេទ ហើយជំងឺដែលមានសន្ទុះខ្ពស់នោះ គឺជំងឺឈឺសន្លាក់ដៃជើង (៥៦.២៥%) ជំងឺក្រពះពោះវៀន (៥០%) ជំងឺលើសសម្ពាធឈាម (៤៣.៧៥%)។ ក្រៅពីជំងឺប្រចាំកាយ គឺមានជំងឺចំនួន១៧ប្រភេទទៀត ហើយជំងឺដែលលេចធ្លោជាងគេ មានដូចជា ឬសដូងបាត ជំងឺរលាកសួត ជំងឺទន់ចង្កេះ លើសជាតិស្ករ និងជំងឺខ្វះគ្រាប់ឈាមក្រហម។

តាមរយៈនិក្ខេបបទស្រាវជ្រាវនេះ នឹងជួយផ្តល់ជាព័ត៌មានដល់ផ្នែកសេវាសុខភាពសាធារណៈ ដើម្បីធ្វើឱ្យសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកាន់តែប្រសើរឡើង។



កើត សុរចនា អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចុះសម្ភាសន៍ និងចែកប្រអប់អនុស្សាវរីយ៍ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ចែករទេះរុញដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

## ដែលមានពិការភាព នៅសង្កាត់គាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង

ភា រស្មី



ភា រស្មី បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបាន ចុះចែករទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានជំងឺឡើងជាតិអាស៊ីត ឈឺចង្កេះ, ជំងឺសន្លាក់ និងវ័យចាស់ជរាពិបាកក្នុងការធ្វើដំណើរ រស់នៅក្នុងសង្កាត់គាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង ចន្លោះពីថ្ងៃទី១៥ ដល់ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចន្លោះពីថ្ងៃទី១៥ ដល់ ថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០២៤ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានចែករទេះរុញចំនួន៥គ្រឿង ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានជំងឺឡើងជាតិអាស៊ីត ឈឺចង្កេះ, ជំងឺសន្លាក់ និងវ័យចាស់ជរាពិបាកក្នុងការធ្វើដំណើរ ដែលស្ថិតនៅក្នុងសង្កាត់គាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។ ការចែករទេះរុញនេះ ក៏មានការចូលរួមពីចៅសង្កាត់គាកោ និងសមាជិកសង្កាត់ដើម្បីចុះទៅជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមផ្ទះរៀងៗខ្លួន ។

គោលបំណងនៃការចែករទេះរុញ គឺដើម្បីជួយសម្រួលដល់ការរស់នៅរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដូចជា ការធ្វើដំណើរ និងការប្រាស្រ័យទាក់ទងជាមួយញាតិជិតខាង ឬចូលរួមនៅក្នុងកិច្ចការងារផ្សេងៗ ព្រមទាំងការបន្តការចែករំលែកការ

ចង់ចាំពីប្រវត្តិសាស្ត្រខ្មែរក្រហមដល់យុវជនជំនាន់ក្រោយៗ ការផ្តល់ជូនរទេះរុញនេះ នឹងធ្វើឱ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមានសុខភាពកាន់តែប្រសើរជាងមុន និងកាត់បន្ថយជំងឺបាក់ទឹកចិត្ត។ មួយវិញទៀត គឺជួយសម្រាលបន្ទុកមួយផ្នែកដល់ជីវភាពរស់នៅប្រចាំថ្ងៃ និងការចំណាយថវិកាគ្រួសារទិញរទេះរុញ។ ក្នុងឱកាសនោះ អាជ្ញាធរភូមិ និងសង្កាត់បានថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងដែលបានផ្តល់រទេះរុញជូនប្រជាជននៅក្នុងភូមិ សង្កាត់របស់គាត់ ក៏ដូចជាផ្តល់ឱកាសឱ្យជនដែលមានពិការភាពបានចូលរួមក្នុងកិច្ចការក្នុងមូលដ្ឋាន។ បន្ថែមលើនេះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានទទួលរទេះរុញ ក៏បានបង្ហាញពីអារម្មណ៍រំភើបរីករាយ និងចំណាប់អារម្មណ៍ដូចខាងក្រោម ៖

ខ្ញុំឈ្មោះ **នួន យ៉ុន** ភេទស្រី អាយុ៨០ឆ្នាំ រស់នៅភូមិខ្នុយ សង្កាត់គាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។ ខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់ដែលបានទទួលរទេះនេះ ព្រោះតាំងពីខ្ញុំធ្លាក់ខ្លួនឈឺមកគឺមិនដែលបានចេញទៅណាទេ។ ការឈឺចង្កេះរបស់ខ្ញុំអាចបណ្តាលមកពីការធ្វើការងារធ្ងន់ៗនៅក្នុងសម័យខ្មែរក្រហម។ ខ្ញុំចាប់ផ្តើមឈឺចង្កេះប្រហែល១០ឆ្នាំមុន និងបានទៅព្យាបាលនៅភ្នំពេញម្តងដែរ ប៉ុន្តែដោយសារតែជីវភាពគ្រួសារខ្វះខាត មានកូនច្រើន ហើយត្រូវធ្វើដំណើរឆ្ងាយ ទើបខ្ញុំមិនបានទៅព្យាបាលបន្តទៀត។ នៅពេលដែលជាតិអាស៊ីតនៅក្នុងខ្លួនរបស់ខ្ញុំឡើង គឺធ្វើឱ្យខ្ញុំឈឺខ្លាំង ហើយកូនៗរបស់ខ្ញុំត្រូវចំណាយថវិកាទៅទិញថ្នាំនៅទីរួមខេត្តព្រៃវែង ឱ្យខ្ញុំលេប ប៉ុន្តែប្រសិនបើកូនខ្ញុំមិនមានថវិកាគ្រប់គ្រាន់ទេ គឺទ្រាំឈឺបែបនេះ។ ខ្ញុំសូមជូនពរឱ្យក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងទទួលជោគជ័យគ្រប់ភារកិច្ច និងមានសុខភាពល្អទាំងអស់គ្នា។

ខ្ញុំឈ្មោះ **ជុំ ចុន** ភេទប្រុស អាយុ៨៧ឆ្នាំ រស់នៅភូមិគោកត្រុំខ សង្កាត់គាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។ កាលពីឆ្នាំ២០២០ ខ្ញុំបានជួបហេតុការណ៍មួយដែលបណ្តាលឱ្យខ្ញុំមិនអាចដើរទៅណាមកណាបានដោយខ្លួនឯងទៀត ។ កាលនោះខ្ញុំត្រូវបានស្ត្រីម្នាក់ដែលមានអាយុប្រហែល៥០ឆ្នាំជាង បានដាក់អន្ទាក់ខ្ញុំឱ្យជួលកង់នៅខាងទ្វារក្នុងវត្ត។ ខ្ញុំបានបោកខ្លួនទៅនឹងដីរួចក៏បានសន្លប់។ ខ្ញុំត្រូវបានបងប្អូនយកមកសម្រាកនៅផ្ទះ និងអញ្ជើញគ្រូពេទ្យឱ្យមកព្យាបាលខ្ញុំ។ បន្ទាប់ពីខ្ញុំបានដឹងខ្លួន ខ្ញុំក៏បានធ្លាក់ខ្លួនពិការ។ ខ្ញុំបានខ្ចីរទេះរុញពីក្មួយខ្ញុំមកជិះ។ ថ្ងៃនេះ ខ្ញុំសប្បាយចិត្តណាស់ ដែលក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានយករទេះរុញមកប្រគល់ជូនខ្ញុំ។ ខ្ញុំនឹងជិះរទេះរុញនេះជារៀងរាល់ថ្ងៃ ព្រមទាំងយករទេះរុញចាស់ទៅប្រគល់ឱ្យក្មួយរបស់ខ្ញុំវិញ។

ខ្ញុំឈ្មោះ **គិត លាប** ភេទស្រី អាយុ៨៤ឆ្នាំ ខ្ញុំរស់នៅភូមិស្គរដាច សង្កាត់គាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។ ក្នុងរបបខ្មែរក្រហម អង្គការបានប្រើខ្ញុំឱ្យធ្វើការហួសកម្លាំង រួមមាន ស្ទូងដក រែកដី និងលើកភ្លឺស្រែ។ ចំណែកការហូបអាហារវិញគឺខ្ញុំហូបតែបបរតិចតួចប៉ុណ្ណោះ។ ខ្ញុំគិតថា ការឈឺសន្លាក់របស់ខ្ញុំសព្វថ្ងៃនេះ គឺបណ្តាលមកពីការធ្វើការងារធ្ងន់ៗរបស់ខ្ញុំនៅក្នុងសម័យខ្មែរក្រហម។ ខ្ញុំចាប់ផ្តើមឈឺសន្លាក់ជាង១០ឆ្នាំមកហើយ ប៉ុន្តែដំបូងគឺខ្ញុំអាចដើរបាន។ ក្នុងរយៈពេល៣ខែចុងក្រោយនេះគឺខ្ញុំមិនអាចដើរបានទេ សូម្បីតែងើបឡើងដោយខ្លួនឯងក៏មិនបានដែរ។ ខ្ញុំពិតជាសប្បាយចិត្តណាស់ដែលក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានប្រគល់រទេះរុញឱ្យខ្ញុំ។ ខ្ញុំអាចឱ្យកូនលើកដាក់ក្នុងរទេះរុញខ្ញុំទៅលេងជុំវិញផ្ទះ ឬក៏ទៅកន្លែងផ្សេងៗ។ នៅពេលដែលខ្ញុំបានអង្គុយលើរទេះរុញនេះ គឺស្រួលខ្លួន ព្រោះមានកន្លែងផ្អែកនៅខាងក្រោយដោយមិនសូវប្រើកម្លាំងទប់ខ្លួន។ ជាចុងក្រោយខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និងជូនពរឱ្យក្រុមការងារជោគជ័យគ្រប់ភារកិច្ច។

ខ្ញុំឈ្មោះ **អ៊ិត យ៉ុង** ភេទប្រុស អាយុ៦៥ឆ្នាំ រស់នៅភូមិត្នោតទ្រេត សង្កាត់គាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។ ខ្ញុំមានជំងឺមួយដែលធ្វើឱ្យខ្ញុំទន់ជើង ហើយមិនអាចដើរបានស្រួល ព្រមទាំងមានជំងឺរលាកព្រះ។ នៅឆ្នាំ១៩៩៧ កំឡុងពេលដែលខ្ញុំចេញទៅឃ្វាលក្របីនៅខាងក្រោយផ្ទះ ស្រាប់តែ

ងងឹតមុខ ហើយដួលសន្លប់។ បន្ទាប់ពីខ្ញុំដឹងខ្លួន ខ្ញុំមិនអាចងើបមកអង្គុយបានឡើយ ហើយសឹងតែមិនស្គាល់កូនចៅទៀតផង។ អស់រយៈពេលជាច្រើនឆ្នាំក្រោយមក ទើបខ្ញុំបានធូរស្រាលជាងមុន ប៉ុន្តែជើងរបស់ខ្ញុំគឺមិនអាចដូចដើមឡើយ។ ខ្ញុំបានត្រឹមតែអង្គុយនៅមួយកន្លែង។ ខ្ញុំចង់ទៅណាមកណា ទាល់តែមានកូនក្មួយនៅចាំជួយ។ ថ្ងៃនេះ ខ្ញុំសប្បាយចិត្តណាស់ដែលខ្ញុំទទួលបាននូវរទេះរុញដ៏ថ្មីស្រឡាងនេះ។ ខ្ញុំសូមអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដែលបាននាំយករទេះរុញមកប្រគល់ជូនខ្ញុំ។ ខ្ញុំនឹងជិះរទេះរុញនេះទៅមើលគេមើលឯង, មើលបាល់ទាត់ និងចេញទៅលេងផ្ទះបងប្អូន ឬអ្នកជិតខាងនៅជិតៗនេះ។ ឥឡូវនេះ ខ្ញុំមិនទាន់ស្ទាត់ក្នុងការជិះរទេះរុញទេ ប៉ុន្តែខ្ញុំនឹងព្យាយាមជិះវាជារៀងរាល់ថ្ងៃ។







ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ចុះចែករទេះរុញចំនួន៥គ្រឿង ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានជំងឺឡើងជាតិអាស៊ីត ឈឺចង្កេះ, ជំងឺសន្លាក់ និងវ័យចាស់ជរាពិបាកក្នុងការធ្វើដំណើរ រស់នៅក្នុងសង្កាត់តាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង ចន្លោះពីថ្ងៃទី១៥ ដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលឯកសារកោះថ្ម ផ្តល់រទេះរុញ និង ការសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅភូមិដាំអំពិល និងភូមិងៀវ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

*ឈុំ រ៉ា និង ទី ស៊ីថា*



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចុះចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព នៅភូមិដាំអំពិល, ភូមិងៀវ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានផ្តល់រទេះរុញចំនួន ២គ្រឿង និងកាសជំនួយត្រចៀកចំនួន ៥គ្រឿង ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព នៅភូមិដាំអំពិល និងភូមិងៀវ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ការចែករទេះរុញ និងកាសជំនួយត្រចៀកដល់ប្រជាជនដែលមានពិការភាព ក៏មានការចូលរួមសហការពីអាជ្ញាធរមូលដ្ឋានដែរ។ លោក សៀង ឌី គឺជាមេភូមិដាំអំពិល បានថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលតែងតែយកចិត្តទុកដាក់ចំពោះសុខភាពប្រជាជន និងជាពិសេស បានផ្តល់រទេះរុញ និងកាសជំនួយត្រចៀកដល់ការស្តាប់។ សម្ភារទាំងនេះ គឺជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ជួយដល់សង្គមជាតិ ជាពិសេសអាចជួយសម្រាលទុក្ខលំបាកដល់ក្រុមគ្រួសាររបស់ជនពិការ។ ជាចុងក្រោយលោក សៀង ឌី សូមអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម និង

សូមជូនពរឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានជោគជ័យគ្រប់ភារកិច្ចការងារ។

បន្ទាប់ពីចប់កម្មវិធី អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលទទួលបានរទេះរុញ និងកាសជំនួយត្រចៀក បង្ហាញពីចំណាប់អារម្មណ៍ដូចខាងក្រោម៖

ខ្ញុំឈ្មោះ **គីប ហ៊ុម** ភេទស្រី អាយុ៩៣ឆ្នាំ កើតនៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិជាំអំពិល ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានបញ្ហាចង្កេះ និងជើងតាំងពីជំនាន់អាមេរិកាំងទម្លាក់គ្រាប់បែកត្រូវត្រង់សេ ដែលគ្រួសារខ្ញុំលាក់ខ្លួន ហើយដីបានបាក់សង្កត់លើខ្ញុំ។ ចង្កេះខ្ញុំចាប់ផ្តើមមានការឈឺចាប់ពេលធ្វើការងារធ្ងន់ ជាពិសេសនៅក្នុងរបបខ្មែរក្រហម ពេលខ្មែរក្រហមប្រើខ្ញុំឱ្យធ្វើការងារជីកប្រឡាយ និងឆ្ការព្រៃ។ ចាប់តាំងពីពេលនោះមក ជើងខ្ញុំចេះតែធ្វើទុក្ខ និងធ្លាក់ខ្លួនពិការ។ ពីមុនមក ខ្ញុំធ្លាប់បានស្នើរទេះរុញតាមរយៈអាជ្ញាធរភូមិ ប៉ុន្តែមិនទាន់ទទួលបាន។ ខ្ញុំគ្មានថវិកាសម្រាប់ទិញរទេះរុញទេ។ ចៅប្រុសខ្ញុំឈ្មោះ គួប ឆៀង បានចូលធ្វើការងារជាអ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំខេត្តត្បូងឃ្មុំ បានទាក់ទងមកក្រុមការងារមជ្ឈ-មណ្ឌលឯកសារកោះថ្ម ដើម្បីស្នើសុំរទេះរុញឱ្យខ្ញុំ។ ថ្ងៃនេះខ្ញុំរីករាយខ្លាំងណាស់ ដែលក្រុមការងារមជ្ឈ-មណ្ឌលឯកសារកោះថ្ម បានយករទេះរុញមកប្រគល់ឱ្យខ្ញុំ។ រទេះរុញនេះពិតជាមានសារប្រយោជន៍សម្រាប់ខ្ញុំនិងក្រុមគ្រួសារ ព្រោះអាចជួយសម្រាលផ្លូវចិត្តបានមួយកម្រិត។ ខ្ញុំអាចចេញទៅក្រៅផ្ទះ មើលគេមើលឯង ធូរស្បើយ និងមានអារម្មណ៍ស្រស់ស្រាយ។ ជាពិសេសជួយសម្រាលកម្លាំងកូនប្រសារ និងចៅប្រុស។ រាល់ថ្ងៃនេះ បានចៅប្រុសឈ្មោះ គួប ឆៀង ជួយគ្រា លើកទៅងូតទឹក និងលើកទៅកន្លែងដេក។ ចុងក្រោយ ខ្ញុំសូមអរគុណដល់ក្រុមការងារមជ្ឈ-មណ្ឌលឯកសារកោះថ្ម ដែលបានផ្តល់រទេះរុញមកខ្ញុំដោយឥតគិតថ្លៃ។ ខ្ញុំសូមជូនពរក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានជោគជ័យគ្រប់ការងារ។

ខ្ញុំឈ្មោះ **ធិត្យ រិន** ភេទស្រី អាយុ៩០ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិជាំអំពិល ឃុំជាំ ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិជាំអំពិល ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ នៅឆ្នាំ២០១៨ ខ្ញុំធ្លាក់ខ្លួនឈឺធ្ងន់ ហើយស្តាប់លែងឮ។ ខ្ញុំធ្ងន់ត្រចៀក ធ្ងន់ក្បាល និងចុកដៃជើង។ សព្វថ្ងៃខ្ញុំមានជំងឺឡើងឈាម និងត្រូវលេបថ្នាំជាប្រចាំ។ ខ្ញុំស្តាប់មិនសូវឮជិត១០ឆ្នាំមកហើយ ហើយឥឡូវខ្ញុំចាស់ជរា វង្វេងវង្វាន់ សូម្បីចៅខ្លួនឯងក៏ខ្ញុំមិនស្គាល់ដែរ។ ពេលស្តាប់មិនឮ ខ្ញុំពិបាកចិត្តណាស់ និងចង់តែស្លាប់។ ដៃជើងរបស់ខ្ញុំឈឺ និងពិបាកទ្រាំ ចំណែកកូនខ្ញុំ ចៅទៅចោលអស់។ ថ្ងៃនេះខ្ញុំសប្បាយចិត្តខ្លាំងណាស់ ដែលក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មបានជូនកាសជំនួយត្រចៀកដល់ខ្ញុំ ដើម្បីឱ្យខ្ញុំមានឱកាសស្តាប់ឮ និងងាយស្រួលដល់ការទាក់ទងជាមួយកូនចៅ និងអាចនិយាយលេងជាមួយបងប្អូននៅក្នុងភូមិ។

ខ្ញុំឈ្មោះ **កុល ពៅ** ភេទស្រី អាយុ៨០ឆ្នាំ កើតនៅភូមិជាំអំពិល ឃុំជាំ ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិជាំអំពិល ឃុំជាំអំពិល ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំថ្លង់បន្ទាប់ពីសម្រាលកូនរួច។ នៅពេលខ្ញុំដេកអាំងភ្លើង ស្រាប់តែខ្ញុំហ៊ឹងត្រចៀក ធ្វើឱ្យខ្ញុំស្តាប់មិនឮរហូតមកដល់បច្ចុប្បន្ន។ ខ្ញុំចង់ស្តាប់ឮដូចមុន និងអាចនិយាយលេងជាមួយកូនចៅក្នុងភូមិបាន។ ខ្ញុំពិតជារីករាយណាស់ដែលមជ្ឈមណ្ឌលឯកសារកោះថ្មផ្តល់កាសជំនួយត្រចៀកមកខ្ញុំ ដើម្បីធ្វើឱ្យខ្ញុំអាចស្តាប់បាន ហើយងាយស្រួលក្នុងការទំនាក់ទំនង។ ខ្ញុំពិតជាអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មដែលបានជួយឱ្យខ្ញុំស្តាប់ឮម្តងទៀត។

ខ្ញុំឈ្មោះ **ឯម វ៉ែគ្រង** ភេទប្រុស អាយុ៧៥ឆ្នាំ កើតនៅភូមិក្រវៀនធំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិជាំអំពិល ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំស្តាប់មិនសូវឮ ហើយភ្នែកក៏មើលមិនសូវឃើញដែរ។ ខ្ញុំស្តាប់មិនសូវឮដោយសារតែសំឡេងទម្លាក់គ្រាប់បែក និងមួយផ្នែកទៀត ដោយសារការឡើងជាតិអាស៊ីត។

ខ្ញុំលំបាកខ្លាំងណាស់ ព្រោះមិនសូវមានកូនចៅណាមកនិយាយជាមួយ ព្រោះខ្ញុំស្តាប់មិនឮ។ ប្រសិនបើនិយាយជាមួយខ្ញុំទាល់តែនិយាយខ្លាំងៗ ទើបខ្ញុំស្តាប់បាន។ ខ្ញុំពិតជាសប្បាយរីករាយណាស់ដែលទទួលបានការសជំនួយត្រចៀកពីមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលធ្វើឱ្យខ្ញុំអាចនិយាយឆ្លើយឆ្លងជាមួយកូនចៅបានដូចធម្មតាវិញ។

ខ្ញុំឈ្មោះ **ភឿក ហ៊ា** ភេទប្រុស អាយុ៩០ឆ្នាំ កើតនៅភូមិផៀវ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិផៀវ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំស្តាប់មិនឮតាំងពីឆ្នាំ២០២០ មូលហេតុដោយសារចាស់ជរា។ ខ្ញុំពិតជាពិបាកក្នុងខ្លួនណាស់ ត្រចៀករបស់ខ្ញុំឮសំឡេងខ្យល់វឹងៗ ពិបាកទាក់ទងជាមួយកូនចៅ និងប្រជាជននៅក្នុងភូមិណាស់ជាក់ស្តែងដូចថ្ងៃនេះ។ បច្ចុប្បន្ននេះសុខភាពរបស់ខ្ញុំកាន់តែទ្រុឌទ្រោមទៅហើយ ដោយសារវ័យចាស់ជរា។ ខ្ញុំចង់បានការសជំនួយត្រចៀកដើម្បីធ្វើខ្ញុំឱ្យងាយស្រួលស្តាប់ ហើយពេលដែលស្តាប់ឮ ខ្ញុំសប្បាយចិត្ត និងងាយស្រួលក្នុងការទាក់ទងជាមួយកូនចៅព្រមទាំងអ្នកភូមិ។ ពេលហៅខ្ញុំពីក្រោយខ្នង ខ្ញុំស្តាប់មិនឮទេ បើចង់និយាយទាល់តែនិយាយឱ្យខ្លាំងៗទើបខ្ញុំស្តាប់បាន។






ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចុះចែករទេះរុញ និងការសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព នៅភូមិដាំអំពិល, ភូមិផៀវ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បន្តផ្ដល់រទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកវាលវែង ខេត្តពោធិ៍សាត់

ឡុង ដានី



ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចុះចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ដឹកនាំដោយលោក ឡុង ដានី នាយកនៃមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានធ្វើដំណើរចុះទៅកាន់ឃុំប្រម៉ោយ និង ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ក្នុងគោលបំណងផ្ដល់ជូនជារទេះរុញចំនួន ៥គ្រឿង និងកាសជំនួយត្រចៀកចំនួនមួយ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព។

នៅក្នុងឱកាសនេះក៏មានការចូលរួមស្វាគមន៍ពីលោក សួន សែម អាយុ៧៤ឆ្នាំ គឺជាប្រធានភូមិដីក្រហម ស្ថិតក្នុងឃុំអន្លង់រាបដែរ។ លោក សួន សែម ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅកាន់ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ដែលមានទឹកចិត្តសប្បុរសធម៌ចែករទេះរុញ និងកាសជំនួយត្រចៀក ជូនជនពិការដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិដីក្រហម។ ការចែករទេះរុញ និងកាសជំនួយត្រចៀកជូនដល់បងប្អូនដែលមានពិការភាព គឺជាការជួយសម្រួលដល់គាត់ក្នុងការប្រាស្រ័យទាក់ទងជាមួយមនុស្សជុំវិញខ្លួន និងជួយឱ្យ

សុខភាពផ្លូវចិត្ត និងផ្លូវកាយបានប្រសើរជាងមុន។ លោកមេភូមិបានជូនពរឱ្យក្រុមការងារ ទាំងអស់ជួបប្រទះតែសេចក្តីសុខ និងរីកចម្រើនតទៅមុខជានិរន្តរ៍។

ជាកិច្ចបន្តលោក ឡុង ដានី ព្រមទាំងក្រុមការងារ បានណែនាំខ្លួនទៅកាន់លោកមេឃុំអន្លង់វាប ប្រធានភូមិដីក្រហម និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ លោក ឡុង ដានី បានលើកឡើងថាគោលបំណងដែលក្រុមការងារមកក្នុងថ្ងៃនេះ គឺក្នុងបំណងចង់ឱ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានធូរទាំងសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្ត ដើម្បីជាម្លប់ដល់កូនចៅជំនាន់ក្រោយ ព្រោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់ សុទ្ធតែជាមនុស្សកម្រ និងជាសាក្សីរស់ដែលរួចផុតជីវិតពីរបបខ្មែរក្រហម។ ការរួមចំណែកតិចតួចនេះ អាចជួយសម្រួលដល់ អ៊ំពូមីង ឱ្យមានភាពងាយស្រួលជាងមុន និងមានសុខភាពល្អរស់នៅបានយូរ។ អ៊ំពូមីង នៅតែបន្តនិយាយរឿងរ៉ាវដែលខ្លួនបានជួបប្រទះប្រាប់ដល់កូនចៅជំនាន់ក្រោយឱ្យបានដឹងពីការឈឺចាប់ ការបែកបាក់ ព្រមទាំងការប្រឈមមុខជាមួយគ្រោះថ្នាក់ផ្សេងៗនៅក្នុងរបបខ្មែរក្រហម។ លោក ឡុង ដានី ក៏បានជូនពរដល់អ៊ំពូមីង ទាំងអស់មានសុខភាពល្អ ព្រមទាំងជួបប្រទះពុទ្ធពរ ទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខាងក្រោមនេះ គឺជាចំណាប់អារម្មណ៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានទទួលរទេះរុញ និងកាសជំនួយត្រចៀក៖

ខ្ញុំឈ្មោះ **កែវ ធី** អាយុ៧៦ឆ្នាំ កើតនៅភូមិឫស្សីក្រាំង ឃុំព្រៃក្រឡាញ់ ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ បច្ចុប្បន្នខ្ញុំរស់នៅភូមិដីក្រហម ឃុំអន្លង់វាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានជំងឺពិការត្រឹមចង្កេះចុះក្រោម។ ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយណាស់ ដែលបានទទួលរទេះរុញ ព្រោះរទេះរុញអាចជួយខ្ញុំបានច្រើន ជាពិសេស ធ្វើឱ្យខ្ញុំបានផ្លាស់ទីកន្លែងដោយខ្លួនឯងបាន មិនចាំបាច់មានអ្នកជួយគ្រាដូចពីមុន។ ខ្ញុំសូមជូនពរមជ្ឈមណ្ឌលផ្សះផ្សារវាលវែងកាន់តែបន្តភាពរីកចម្រើនតទៅមុខរហូត។

ខ្ញុំឈ្មោះ **ឡេង ឈាង** ភេទប្រុស អាយុ៦៧ឆ្នាំ ខ្ញុំមានស្រុកកំណើតនៅភូមិអូរក្រសារ ឃុំកែប ស្រុកកំពត ខេត្តកំពត។ បច្ចុប្បន្នខ្ញុំរស់នៅភូមិដីក្រហម ឃុំអន្លង់វាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំពិតជាមានអារម្មណ៍សប្បាយចិត្តជាខ្លាំងដែលក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សារវាលវែង បានចុះមកចែកកាសជំនួយត្រចៀកមកដល់រូបខ្ញុំ។ កាសជំនួយត្រចៀកវាពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ខ្ញុំ វាអាចជួយឱ្យខ្ញុំស្តាប់ឮឡើងវិញ ជួយឱ្យខ្ញុំងាយស្រួលក្នុងការទំនាក់ទំនងជាបងប្អូនញាតិមិត្ត និងក្រុមគ្រួសារ។ ជាចុងក្រោយខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលផ្សះផ្សារវាលវែងដែលបានផ្តល់កាសជំនួយត្រចៀកដល់រូបខ្ញុំ។

ខ្ញុំឈ្មោះ **សាំ គឹមសួ** ភេទប្រុស អាយុ៥៥ឆ្នាំ ខ្ញុំកើតនៅភូមិជ្រោយស្តៅ ឃុំជ្រោយស្តៅ ស្រុកថ្មគោល ខេត្តបាត់ដំបង។ សព្វថ្ងៃខ្ញុំរស់នៅភូមិដីក្រហម ឃុំអន្លង់វាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ចំពោះរទេះរុញ ដែលខ្ញុំបានទទួលនៅថ្ងៃនេះ វាពិតជាមានសារសំខាន់សម្រាប់ខ្ញុំ ព្រោះចាប់តាំងពីខ្ញុំធ្លាក់ខ្លួនពិការ ខ្ញុំមិនដែលបានចេញទៅក្រៅផ្ទះទេ ពិតជាមានភាពស្មុគស្មាញខ្លាំងណាស់។ ខ្ញុំមានអារម្មណ៍សប្បាយរីករាយខ្លាំងណាស់ ដែលក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សារវាលវែង តែងតែយកចិត្តទុកដាក់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ថែមទាំងផ្តល់ជូនរទេះរុញសម្រាប់ជនពិការដូចជារូបខ្ញុំ។ ខ្ញុំពិការអស់រយៈពេល២ឆ្នាំមកហើយ ជួបការលំបាកជាច្រើន ព្រោះជើងខ្ញុំទាំងពីរទន់មិនអាចទប់លំនឹងបាន។ មួយវិញទៀត តាំងពីខ្ញុំធ្លាក់ខ្លួនពិការមក ខ្ញុំមិនអាចរកចំណូលផ្គត់ផ្គង់គ្រួសារដូចមុនបានឡើយ ដូច្នេះជីវភាពរបស់គ្រួសារខ្ញុំក៏ធ្លាក់ចុះទៅតាមនឹងដែរ សូម្បីតែចង់ដើរតាមជុំវិញផ្ទះក៏មិនអាចដើរបាន គឺអង្គុយនៅតែមួយកន្លែងហើយពេលខ្លះមានអារម្មណ៍ធុញធប់នៅក្នុងខ្លួនជាខ្លាំង។ រទេះរុញមួយនេះ វាពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ខ្ញុំជួយស្រួលក្នុងការធ្វើដំណើរផ្លាស់ទីទៅជិតឬឆ្ងាយ ទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យ ឬជួបជុំជាមួយបងប្អូននៅក្បែរផ្ទះ។

ខ្ញុំឈ្មោះ **យ៉ង់ សុខជា** ភេទស្រី អាយុ៦២ឆ្នាំ កើតនៅក្នុងភូមិទូល ឃុំទឹកល្អក់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ បច្ចុប្បន្នរស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំនិយាយមិនច្បាស់ដោយសារជំងឺលើសឈាម។ ខ្ញុំពិតជាមានអារម្មណ៍សប្បាយចិត្តត្រេកអរខ្លាំងមែនទែន ដែលខាងក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានមើលឃើញពីទុក្ខលំបាក និងផ្ដល់រទេះរុញជូនខ្ញុំ ព្រោះចាប់តាំងពីខ្ញុំធ្លាក់ខ្លួនពិការ គឺត្រូវនៅអង្គុយតែក្នុងផ្ទះ មិនសូវបានចេញទៅណាមកណាដូចពេលមុនទេ។ បើចង់ទៅផ្ទះបងប្អូន ទៅធ្វើបុណ្យ ទាល់តែប្ដី ឬកូនៗជួយជូន និងគ្រាទៅទើបបាន ព្រោះគ្មានកម្លាំងទប់លំនឹងខ្លួនឯងបាននោះទេ ជាពិសេសនៅពេលទៅពិនិត្យសុខភាពម្ដងៗ ទាល់តែមានកូន និងប្ដីជួយគ្រា។

ខ្ញុំឈ្មោះ **សុខ រហេង** ភេទស្រី អាយុ៧៣ឆ្នាំ កើតនៅក្នុងភូមិព្រៃកំពែង ឃុំព្រែកណ្ដៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំសប្បាយចិត្ត និងត្រេកអរជាខ្លាំងនៅពេលដែលក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានផ្ដល់រទេះរុញឱ្យខ្ញុំដែលអាចខ្ញុំជិះទៅកន្លែងផ្សេងៗបានងាយស្រួល។

ខ្ញុំឈ្មោះ **អ៊ីន តួយ** ភេទប្រុស អាយុ៥៣ឆ្នាំ កើតនៅភូមិព្រៃគ្រាង ឃុំមានជ័យ ស្រុកឈូក ខេត្តកំពត។ បច្ចុប្បន្នខ្ញុំរស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំពិតជាសប្បាយរីករាយខ្លាំងណាស់ នៅពេលដែលក្រុមការងាររបស់មជ្ឈ-មណ្ឌលផ្សះផ្សាវាលវែងបានចែករទេះរុញដល់រូបខ្ញុំ។ សព្វថ្ងៃនេះ ខ្ញុំជួបផលលំបាកជាច្រើន ព្រោះគ្រួសារមានជីវភាពខ្វះខាត មិនអាចរកចំណូលបានដូចមុន ប្រពន្ធរបស់ខ្ញុំត្រូវធ្វើស្រែចម្ការតែម្នាក់ឯងដើម្បីផ្គត់ផ្គង់គ្រួសារ។ ខ្ញុំចង់បានរទេះរុញមួយនេះយូរហើយ តែគ្មានលទ្ធភាពទិញ។ រទេះរុញអាចជួយសម្រួលដល់ខ្ញុំជាច្រើន ព្រោះខ្ញុំអាចជួយប្រពន្ធកូនប្រកបការងារផ្សេងដើម្បីសម្រួលបន្ទុកគ្រួសារប្ុ ក៏ធ្វើកិច្ចការងារផ្ទះខ្លះៗដែលខ្ញុំអាចធ្វើបាន មិនតែប៉ុណ្ណោះ ខ្ញុំអាចធ្វើដំណើរបានដោយខ្លួនឯងនៅជុំវិញផ្ទះ ឬជួបជុំជាមួយសាច់ញាតិបងប្អូន និងមានទំនាក់ទំនងជាមួយមិត្តជិតខាងថែមទៀតផង។ ជាចុងក្រោយ ខ្ញុំសូមឱ្យមជ្ឈមណ្ឌលផ្សះផ្សាវាលវែងបន្តចែករទេះរុញដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការផ្សេងទៀត។







ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចុះចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តចែករទេះរុញ ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាពនៅស្រុកកំពង់សៀម និងស្រុកកោះសូទិន

**ទូច វណ្ណោត**



ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចុះចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព នៅស្រុកកំពង់សៀម និងស្រុកកោះសូទិន នៅចន្លោះពីថ្ងៃទី១២ ដល់ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចន្លោះពីថ្ងៃទី១២ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បន្តចុះប្រគល់ជូនរទេះរុញចំនួន៨គ្រឿងដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាពមិនអាចដើររួច នៅស្រុកកំពង់សៀម និងស្រុកកោះសូទិន ខេត្តកំពង់ចាម ។ ការផ្តល់រទេះរុញទាំង៨គ្រឿងនេះ ដើម្បីជួយសម្រួលដល់ការផ្លាស់ទី និងធ្វើដំណើររបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការ។ បន្ទាប់មក អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំង៨នាក់ បានបង្ហាញសេចក្តីរីករាយចំពោះមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលខ្វាយខ្វល់អំពីសុខភាព និងស្ថានភាពលំបាកធ្វើដំណើររបស់ខ្លួន និងបានចែករំលែកអំពីបទពិសោធន៍ដែលខ្លួននៅចងចាំអំពីរបបខ្មែរក្រហម ដូចខាងក្រោម៖

## នួន ហុងលីម

«ខ្ញុំឈ្មោះ នួន ហុងលីម។ ខ្ញុំមានជំនាញធ្វើនំប៉័ង និងជាអ្នករស់រានមានជីវិតមួយរូបពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ខ្ញុំកើតនៅឆ្នាំ១៩៥៥ ក្នុងគ្រួសារកសិករនៅភូមិកោះថ្មី ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំមានបងប្អូនប្រុសស្រីសរុបចំនួន១១នាក់ ប៉ុន្តែបានបាត់បង់ជីវិតមួយចំនួន។ ខ្ញុំរៀនដល់ថ្នាក់ទី៧ចាស់ នៅសាលាបឋមសិក្សាភ្នំតាងិល ដែលស្ថិតនៅឆ្ងាយពីភូមិកំណើត។ ដោយសារតែជីវភាពក្រីក្រ ខ្ញុំបានបោះបង់ការសិក្សាត្រឹមថ្នាក់ទី៧ចាស់។ នៅពេលនោះ ខ្ញុំមានអាយុ១៨ឆ្នាំ។ បន្ទាប់ពីឈប់រៀន ខ្ញុំទៅរៀនធ្វើនំប៉័ងលក់។ ខ្ញុំដុតនំប៉័ងលក់នៅទីរួមខេត្តកំពង់ចាម។ នៅថ្ងៃមួយក្នុងឆ្នាំ១៩៧០ ពេលខ្ញុំដឹកនំប៉័ងយកមកលក់ គឺខ្ញុំបានឃើញការធ្វើបាតុកម្មនៅទន្លេអុំ។ ខ្ញុំភ័យខ្លាចចំពោះព្រឹត្តិការណ៍ដែលខ្ញុំបានឃើញ។ មិនយូរប៉ុន្មាន ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិលរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម។

បើទោះបីជាប្រទេសស្ថិតក្នុងសង្គ្រាមស៊ីវិលយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែបន្តធ្វើនំប៉័ង និងលក់ដាច់ដូចធម្មតា ជាពិសេសមានឈ្មួញកណ្តាលបានទទួលទិញនំប៉័ងលក់បន្តនៅតាមចំណត ឡានឈ្នួល។ រហូតដល់ឆ្នាំ១៩៧២ កងទ័ពខ្មែរក្រហមចូលមកដល់ភូមិ ទើបខ្ញុំនិងគ្រួសាររត់ភៀសខ្លួនទៅភូមិជីហែដែលជាតំបន់រំដោះខ្មែរក្រហម។ គិតត្រឹមចុងឆ្នាំ១៩៧២ ខ្ញុំត្រូវបានដាក់ចូលធ្វើការនៅកងចល័តយុវជន ដែលត្រូវ ភ្ជួររាស់ និងដាំដំណាំកសិកម្ម រួមមានដំឡូង និងបន្លែ ជាដើម។ សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហមបានផ្ទុះកាន់ខ្លាំងឡើង ទាំងតាមផ្លូវគោក និងតាមបណ្តោយទន្លេមេគង្គ។ ខ្ញុំតែងតែឃើញនាវាទាហាន លន់ នល់ ដែលដឹកស្បៀង និងសម្ភារសឹកផ្សេងៗពីភ្នំពេញទៅកាន់ទីរួមខេត្តកំពង់ចាម ធ្វើដំណើរចុះឡើងតាមបណ្តោយទន្លេមេគង្គ។ កងទ័ពខ្មែរក្រហមបានវាយឆ្មក់នាវាទាហាន លន់ នល់ ជាញឹកញាប់។



លោក នួន ហុងលីម និងប្រពន្ធ នៅភូមិកោះថ្មី ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានចល័តមកកាន់ភូមិកោះថ្មីវិញ។ នៅចុងឆ្នាំ១៩៧៥ អង្គការបានរៀបការឱ្យខ្ញុំជាមួយមិត្តនារី យ៉ាង ស៊ីម៉ាន់។ ខ្ញុំមិនដែលបានជួបមុខប្រពន្ធខ្ញុំពីមុនមកទេ ពីព្រោះអង្គការគឺជាអ្នករៀបចំឱ្យ។ ក្នុងថ្ងៃរៀបការនោះ គឺមានទាំងអស់ចំនួន១០គូ។ ខ្ញុំមិនហ៊ាននិយាយអ្វីនោះទេ ក្រៅតែពីពាក្យប្តេជ្ញាចំពោះអង្គការ។ បន្ទាប់មកខ្ញុំនិងប្រពន្ធហូបអាហារបន្តិច រួចហើយត្រឡប់មកផ្ទះវិញ។

នៅចុងឆ្នាំ១៩៧៦ ប្រពន្ធខ្ញុំកើតបានកូនប្រុសម្នាក់។ ចំណែកខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅកងចល័តសហករណ៍ឆ្ងាយពីគ្រួសារ។ កងចល័តសហករណ៍មានសមមិត្តប្រហែល១០០នាក់ដើម្បីធ្វើការនៅតាមការដ្ឋានផ្សេងៗ។ ខ្ញុំត្រូវក្រោកធ្វើការពីម៉ោង៥ទៀបភ្លឺ រហូតដល់ព្រលប់។ ការងាររបស់ខ្ញុំមានដូចជា ភ្ជួររាស់ ស្ទូងស្រូវ ដាំដំឡូង និងជីកកាយដីប្រឡាយ ជាដើម។ ខ្ញុំមិនសូវបានជួបមុខប្រពន្ធកូនទេ ពីព្រោះខ្ញុំត្រូវបានបញ្ជូនទៅធ្វើការពីកន្លែងមួយទៅកន្លែងមួយ។ នៅខែភ្លឺ អង្គការបានរៀបចំពេលវេលាធ្វើការ គឺចាប់ពីម៉ោង១យប់ រហូតដល់ម៉ោង១២ថ្ងៃត្រង់ និងចាប់ពីម៉ោង១ថ្ងៃត្រង់រហូតដល់ម៉ោង៦ល្ងាច ទើបបានសម្រាក។ ខ្ញុំ

ត្រូវភ្ជួររាស់ដី និងលើកទំនប់ចាប់ពីម៉ោង១យប់ ដល់ម៉ោង៦ល្ងាច។ ខ្ញុំពិតជាមិនដឹងថា នេះគឺជាផែនការរបស់ខ្មែរក្រហមថ្នាក់លើ ដែលត្រូវដាក់ឱ្យប្រជាជនធ្វើការ ទាំងថ្ងៃទាំងយប់នោះទេ។ ក្នុងយប់មួយ ពេលកំពុងភ្ជួររាស់ដីដាំដំឡូង ខ្ញុំរមួលពោះឃ្លាននំប៉័ង។ គិតដល់ត្រឹមនេះ គឺអស់រយៈពេលជាច្រើនឆ្នាំហើយ ដែលខ្ញុំមិនបានហូបនំប៉័ង។ ខ្ញុំនៅចាំបានថា ខ្ញុំក្រោកនៅម៉ោង៤ទៀបភ្លឺដើម្បីធ្វើនំប៉័ង ប៉ុន្តែក្នុងរបបខ្មែរក្រហម ខ្ញុំក្រោកនៅម៉ោង១យប់ គឺត្រឹមតែធ្វើការភ្ជួររាស់ដីដោយបង្ខំតាមបញ្ជារបស់អង្គការ។ ខ្ញុំធ្វើការនៅក្នុងកងចល័តរហូតដល់ខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកដល់ភូមិកោះថ្មី នៅចន្លោះពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨។ ខ្មែរក្រហមមកពីភូមិភាគនិរតីបានចាប់ផ្តើមចាប់កម្មាភិបាលខ្មែរក្រហមមូលដ្ឋានយកទៅសម្លាប់ចោលជាបន្តបន្ទាប់។ ចាប់តាំងពីពេលនោះមក ការធ្វើការងាររហូស គ្មានពេលសម្រាក ការវាយធ្វើបាប ការបង្អត់អាហារហូប និងការសម្លាប់កើតឡើងកាន់តែខ្លាំងឡើង។ នៅដើមឆ្នាំ១៩៧៩ ខ្ញុំនិងគ្រួសារបានរួចផុតជីវិតពីរបបខ្មែរក្រហម និងបន្តអាជីពធ្វើនំប៉័ងលក់រហូតដល់ឆ្នាំ១៩៩៦។ ខ្ញុំនៅតែចងចាំយ៉ាងល្អអំពីរឿងរ៉ាវជីវិត និងបទពិសោធន៍ធ្វើការគ្មានពេលសម្រាកនៅសហករណ៍ខ្មែរក្រហម»។

## យីន សុងហ៊ីម

ខ្ញុំឈ្មោះ យីន សុងហ៊ីម អាយុ៧៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិហាន់ជ័យ ឃុំហាន់ជ័យ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំមានស្រុកកំណើតនៅក្នុងឃុំហាន់ជ័យ។ ឪពុករបស់ខ្ញុំឈ្មោះ ឈឹម និងម្តាយរបស់ខ្ញុំ ឈ្មោះ ថាត និងមានបងប្អូនសរុបចំនួន៨នាក់។ កាលពីកុមារភាព ដោយសារទីតាំងភូមិសាស្ត្រឃុំហាន់ជ័យ កាលពីពេលនោះពិបាកក្នុងការធ្វើដំណើរទៅសិក្សានៅទីរួមខេត្តកំពង់ចាម ទើបខ្ញុំសម្រេចចិត្តទៅសិក្សានៅស្រុកស្ទឹងត្រង់ ដែលការធ្វើដំណើរមិនឆ្ងាយពីនេះប៉ុន្មានឡើយ។ ក្រោយពីមានព្រឹត្តិការណ៍ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅក្នុងឆ្នាំ១៩៧០ រួចមក ខ្ញុំត្រូវបោះបង់ការសិក្សា និងត្រូវផ្លាស់ប្តូរមកនៅស្រុកកំណើតនៅក្នុងភូមិហាន់ជ័យវិញ។ ក្រោយឆ្នាំ១៩៧៥ នៅពេលដែលកងទ័ពខ្មែរក្រហមបានចូលកាន់កាប់ប្រទេស ខ្ញុំធ្វើការនៅក្នុងភូមិដូចប្រជាជនធម្មតាផ្សេងទៀតដែរ។ ក្រោយពេលដែលខ្មែរក្រហមដាក់ចេញនូវផែនការ៤ឆ្នាំរបស់ខ្លួន បានធ្វើឱ្យប្រជាជនមានការលំបាកយ៉ាងខ្លាំង។ ខ្ញុំក៏មិនខុសពីប្រជាជនខ្មែរផ្សេងទៀតដែរ នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមចល័តខ្ញុំឱ្យទៅធ្វើការនៅទំនប់ត្រួយចេក ដែលមានមេកងម្នាក់ឈ្មោះ ឈុន គឺជាអ្នកគ្រប់គ្រងកងរបស់ខ្ញុំ។ នៅទំនប់ត្រួយចេក ខ្ញុំមិនត្រឹមតែត្រូវមេកងខ្មែរក្រហមបង្ខំឱ្យរែកដីគ្មានពេលឈប់សម្រាកទេ។ ខ្ញុំក៏ត្រូវបានមេកងប្រើឱ្យបររទេះដឹកពោត និងដាំដំណាំផ្សេងៗទៀតនៅទំនប់នោះ សម្រាប់ចុងភៅចម្អិនធ្វើជាអាហារហូបចុក។ និយាយពីការហូបចុកវិញ មិនមែនតែខ្ញុំម្នាក់ទេដែលមិនបានហូបចុកគ្រាប់គ្រាន់ សូម្បីប្រជាជនផ្សេងទៀតដែលនៅក្នុងការដ្ឋានទំនប់ត្រួយចេកជាមួយខ្ញុំនៅពេលនោះ ក៏មិនមានអាហារហូបគ្រប់គ្រាន់ដែរ។ កាលពីពេលខ្ញុំទៅរែកដី និងធ្វើការងារនៅតំបន់ទំនប់ត្រួយចេក រូបរាងរបស់ខ្ញុំមានសភាពស្គមជាខ្លាំង គឺឃើញតែក្បាលជង្គង់ ដែលមើលទៅឃើញធំជាងខ្លួន។ ក្នុងការដ្ឋានទំនប់ត្រួយចេក ស្រុកកំពង់សៀម មានប្រជាជនច្រើនបានស្លាប់នៅទីនោះ អ្នកខ្លះបានស្លាប់ដោយសារការអត់ឃ្លាន អ្នកខ្លះទៀតធ្វើការហួសកម្លាំង ហើយក៏មានប្រជាជនមួយចំនួនត្រូវកងឈ្លបរបស់ខ្មែរក្រហមយកទៅសម្លាប់។ ខ្ញុំបានបន្តធ្វើការនៅទំនប់ត្រួយចេកនេះរហូតដល់របបខ្មែរក្រហមបានដួលរលំ ទើបខ្ញុំ និងប្រពន្ធរបស់ខ្ញុំឈ្មោះ ទួន គឹមសៀង ត្រឡប់មកនៅភូមិកំណើតវិញ។ ក្រោយពីរបបខ្មែរក្រហមបានដួលរលំ ខ្ញុំមានការឈឺចាប់យ៉ាងខ្លាំង ទាំងផ្លូវចិត្ត និងផ្លូវកាយ។ ខ្ញុំឈឺចាប់ផ្លូវចិត្តនៅពេលដែលដឹងថាបងប្អូន និងសាច់ញាតិមួយចំនួនរបស់ខ្ញុំត្រូវបានខ្មែរក្រហមសម្លាប់។ ឯផ្លូវកាយខ្ញុំវិញ ដោយសារការលើក

និងរែកដីគ្មានពេលសម្រាកនៅពេលនោះ បណ្តាលឱ្យខ្ញុំមានបញ្ហាចង្កេះនិងខ្នង ហើយកាលប្រមាណជាង១០ឆ្នាំមុន ខ្ញុំមានបញ្ហាលើសសម្ពាធឈាម ធ្វើឱ្យខ្ញុំដួល និងមានបញ្ហាសរសៃ ពិបាកក្នុងការឈរ និងដើររហូតមកដល់សព្វថ្ងៃនេះ។»

## គង់ យ៉ាត

ខ្ញុំឈ្មោះ គង់ យ៉ាត មានអាយុ៦៤ឆ្នាំ រស់នៅភូមិមាន់ហើរ ឃុំហាន់ជ័យ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្រពន្ធឈ្មោះ ម៉ុន ផល្លី មានកូន២នាក់។ ខ្ញុំគឺជាកូនទី៣ក្នុងចំណោមបងប្អូនប្រុសស្រីសរុបចំនួន៧នាក់។ ខ្ញុំមានស្រុកកំណើតនៅភូមិមាន់ហើរ ឃុំហាន់ជ័យ ស្រុកកំពង់សៀម។ ខ្ញុំរៀននៅត្រឹមថ្នាក់ទី៣ នៅសម័យសង្គមរាស្ត្រនិយម ដែលពេលនោះហៅថ្នាក់អាទិកដ្ឋាន (ថ្នាក់ទី១០ ជំនាន់មុន)។ នៅពេលដែលមានបាតុកម្មផ្ទុះឡើង ខ្ញុំបានមករស់នៅវត្ត និងបួសរៀនជាមួយព្រះចៅអធិការវត្ត។ មិនយូរប៉ុន្មានបន្ទាប់ពីបាតុកម្ម កងទ័ពខ្មែរក្រហមបានចូលមកដល់ភូមិ និងស្នាក់នៅតាមផ្ទះប្រជាជន។ ខណៈនោះ សង្គ្រាមបានផ្ទុះឡើង និងយន្តហោះទាហាន លន់ នល់ បានហោះមកទម្លាក់គ្រាប់បែកជារៀងរាល់ថ្ងៃ។ ខ្ញុំរត់ចូលក្នុងរណ្តៅលេណដ្ឋាននៅខាងក្រោយផ្ទះ។ នៅថ្ងៃមួយ ខ្ញុំទៅមាត់ទន្លេ ស្រាប់តែមានយន្តហោះទាហាន លន់នល់ ហោះមកទម្លាក់គ្រាប់បែក និងបាញ់រះ។ ខ្ញុំបានរត់ពួននៅក្រោមដើមអំពិលធំមួយ។ នៅឆ្នាំ១៩៧២ ការទម្លាក់គ្រាប់បែកនៅ ហាន់ ជ័យ បន្តកាន់តែខ្លាំងឡើងរហូតដល់ឆ្នាំ១៩៧៣ ទើបឈប់មានការទម្លាក់គ្រាប់បែក។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមផ្សឹកព្រះសង្ឃ និងបង្ខំឱ្យធ្វើការដូចប្រជាជននៅតាមកងចល័ត។ នៅពេលនោះ មានព្រះសង្ឃប្រហែល៣០អង្គ។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមដាក់ឱ្យប្រជាជនធ្វើការងារនៅកងចល័ត ដែលមានប្រធានកងឈ្មោះ មិត្ត ទីន, មិត្តឃីម, មិត្តរ៉ន និងមិត្តណាវ។ ការងារពេលនោះ មានដូចជា ដកស្ទូង លើកដី និងកាប់ព្រៃ។ បន្ទាប់មក ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការលើកទំនប់កែប្រែ និងទំនប់ត្រួយចេក។ ខ្ញុំត្រូវធ្វើការពេញមួយថ្ងៃគឺពីព្រឹកដល់យប់។ ខ្ញុំត្រូវលើកដីទៅតាមប្រភេទដី គឺចាប់ពី២ម៉ែត្រកន្លះ ទៅ៣ម៉ែត្រគូប។ បន្ទាប់មក ខ្ញុំបានផ្លាស់ទៅធ្វើការនៅស្រុកព្រៃឈរ នៅភូមិច្រេស គឺលើកភ្លឺស្រែ។ ក្រោយមក ខ្ញុំត្រូវបានបញ្ជូនមករកត្រីនៅព្រែកគៀនជ្រៃ។ នៅឆ្នាំ១៩៧៨ ខ្ញុំធ្លាក់ខ្លួនឈឺ និងត្រូវបានពេទ្យខ្មែរក្រហមឱ្យថ្នាំអាចម៍ទន្សាយលេប និងចាក់ថ្នាំឱ្យខ្ញុំ។ ការចាក់ថ្នាំពេលនោះធ្វើឱ្យខ្ញុំមិនអាចដើរបាននោះទេ។ ខ្ញុំមិនដឹងថា មកពីចាក់ខុសសរសៃ ឬជាតិថ្នាំនោះទេដែលធ្វើឱ្យខ្ញុំដើរមិនរួចរហូតដល់អស់ជាតិថ្នាំ ទើបខ្ញុំអាចក្រោកឈរដើរបាន។ សំណាងដែរ ខ្ញុំមិនស្លាប់។ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានចាប់បញ្ជូនធ្វើជាកងទ័ពខ្មែរក្រហម និងបញ្ជូនទៅសមរភូមិទល់ដែន។ នៅពេលនោះ ខ្ញុំមានអាយុ១៨ឆ្នាំ។ ប៉ុន្តែក្រោយមក ខ្ញុំត្រូវបានដកឱ្យទៅឈរជើងនៅព្រែកតាងិន និងដកស្ទូងនៅទីនោះរហូតដល់បែកឆ្នាំ១៩៧៩។ រឿងដែលខ្ញុំចងចាំមិនភ្លេចបាននោះគឺ របបខ្មែរក្រហមបង្អត់អាហារ និងសម្លាប់ប្រជាជន។»

## គីម អាត កងចល័តវ័យកណ្តាល

ខ្ញុំឈ្មោះ គីម អាត ភេទស្រី អាយុ៦៣ឆ្នាំ រស់នៅក្នុងភូមិបឹងកុក២ សង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម។ ខ្ញុំមានកូនប្រុសស្រីសរុបចំនួន៤នាក់ ដែលកូនច្បងរបស់ខ្ញុំមានជំងឺស្ពឹកជើងទាំង២មិនអាចដើររួច។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំ និងគ្រួសាររស់នៅក្នុងជីវភាពក្រីក្រ។ នៅពេលដែលកំពុងតែមានផ្ទៃពោះកូនឈ្មោះ ហម សំអុល ខ្ញុំមិនមានអាហារជីវជាតិគ្រាប់គ្រាន់ហូបនោះទេ ទើបបានកូនប្រុសច្បងរបស់ខ្ញុំកើតមកទាំងមានជំងឺស្ពឹកជើងពីកំណើត។ ខ្ញុំសូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលបានផ្តល់រទេះរុញដល់កូនប្រុសរបស់ខ្ញុំនាពេលនេះ ដើម្បីជួយដល់ការធ្វើ

ដំណើររបស់គាត់។ ឆៀតពេលនេះផងដែរ ខ្ញុំសូមរំឭកអំពីប្រវត្តិសាវតារ និងបទពិសោធន៍របស់ខ្ញុំក្នុងរបបខ្មែរក្រហម។ នៅពីក្មេង ខ្ញុំរៀននៅសាលាបឋមសិក្សាខត្តរ រហូតដល់ថ្នាក់ទី៦ សង្គមចាស់។ ខ្ញុំមិនបានរស់នៅជាមួយគ្រួសារក្នុងខេត្តកំពង់ចាម នៅឆ្នាំ១៩៧០ទេ។ ខ្ញុំបានរស់នៅជាមួយបងស្រីដែលគាត់បានរៀបការប្ដី និងទៅរស់នៅខេត្តបាត់ដំបង នៅឆ្នាំ១៩៦៩។ នៅឆ្នាំ១៩៧០ រដ្ឋប្រហារ លន់ នល់ បានកើតឡើង ដូច្នេះម្ដាយរបស់ខ្ញុំបានទៅយកខ្ញុំនៅខេត្តបាត់ដំបង ប៉ុន្តែនៅពេលនោះ ការធ្វើដំណើរតាមរថយន្តត្រូវបានផ្ដាច់ គឺមានតែជិះយន្តហោះនោះទេដែលអាចធ្វើដំណើរបាន។ នៅឆ្នាំ១៩៧២ បងស្រីខ្ញុំមកទិញសំបុត្រយន្តហោះបាន២កន្លែង បងស្រី និងម្ដាយខ្ញុំបានមកមុន។

នៅឆ្នាំ១៩៧៣ ខ្ញុំរស់នៅជាមួយបងថ្លៃ និងបានរត់គេចពីការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានវាយដណ្ដើមយកខេត្តបាត់ដំបងទាំងអស់។ ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសពីស្ពានដែកមកនៅអន្លង់វិលព្រៃចែក។ ខ្ញុំត្រូវបានខ្មែរក្រហមហៅទៅធ្វើប្រវត្តិរូប។ ខ្មែរក្រហមបានសួរខ្ញុំពីមុនធ្វើអ្វី? ឪពុកម្ដាយធ្វើអ្វី? តើមានបុណ្យស័ក្តិអីដែរឬទេ? ខ្ញុំឆ្លើយប្រាប់ថា ធ្វើស្រែចម្ការ អត់មានធ្វើអ្វីទេ។ ខ្មែរក្រហមនៅតែសួរខ្ញុំថា មិនមែនទេ អ្នកឯងមានឪពុកធ្វើមន្ត្រីរាជការ និងមានបងប្អូនធ្វើទាហាន។ ខ្មែរក្រហមបន្តសួរឈ្លេច ប៉ុន្តែខ្ញុំប្រាប់ថាមិនមែនទេ។ ខ្ញុំឆ្លើយថា ជាក្មេងកំព្រា។ លុះដល់ព្រឹកស្អែកឡើង ខ្មែរក្រហមឱ្យខ្ញុំទៅស្ទូងស្រូវ។ ខ្ញុំទៅស្ទូងស្រូវ ដោយមិនចេះយកសំណាបចុចចូលក្នុងដីទាំងម្រាមដៃ៥ ស្ទូងរួចសំណាបអណ្ដែតឡើងវិញ។

សំណាងល្អ អ៊ំម្នាក់បានប្រាប់ខ្ញុំពីរបៀបស្ទូងស្រូវ។ អ៊ំនោះបានប្រាប់ថា យកម្រាមដៃមេនិងម្រាមដៃចង្អុលចាប់សំណាប ហើយម្រាមដៃកណ្ដាលគាវដីបិទភ្ជាប់សំណាប។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានខ្មែរក្រហមយកទៅរៀបការជាមួយជនពិការនៅប៉ៃលិន។ ខ្ញុំមិនបានដឹងដែរ។ ខ្មែរក្រហមប្រាប់ថាទៅដកដីឡូងដូច្នេះខ្ញុំក៏ឡើងជិះឡានទៅ។ នៅពេលដែលទៅដល់ប៉ៃលិន ខ្មែរក្រហមរៀបការឱ្យខ្ញុំជាមួយជនពិការ។ ខ្ញុំប្រកែកថា មិនទាន់ចង់បានទេ។ ខ្ញុំនិយាយអង្វរកម្មាភិបាលខ្មែរក្រហម តែត្រូវបានប្រាប់វិញថា បើមិត្តនារីឯងមិនព្រមយកប្ដីទេ មិត្តឯងត្រូវទៅដកដីឡូង និងបេះសាវម៉ាវជាមួយមិត្តនារី៤នាក់ផ្សេងទៀត ដែលគេចមិនព្រមយកប្ដី។ បន្ទាប់មក ខ្ញុំត្រូវបានដាក់ឱ្យធ្វើការនៅម្ដុំស្រះកែវចំមាត់ផ្លូវ។ នៅពេលយប់ខ្ញុំឃើញខ្មែរក្រហមយកមនុស្សទៅសម្លាប់ចោលដោយចងដៃមកក្រោយបណ្ដើរទាំងជួរៗ។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានដាក់ឱ្យទៅច្រូតស្រូវ។ ខ្មែរក្រហមតែងតែតាមដាន និងពិនិត្យមើលការងារខ្ញុំរហូត។ ខ្ញុំត្រូវបានខ្មែរក្រហមលត់ដំឱ្យធ្វើការងារយ៉ាងខ្លាំង។ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឱ្យដឹកប្រឡាយ ទាំងយប់ជាមួយកងនារី និងយុវជន ចំណែកនៅពេលថ្ងៃច្រូតស្រូវ។ ខ្ញុំត្រូវដើរពីការដ្ឋាននៅម៉ោង៨យប់ ហើយទៅដល់កន្លែងស្នាក់នៅម៉ោង១២យប់ រហូតដល់រំដោះឆ្នាំ១៩៧៩។ ក្រោយរំដោះឆ្នាំ១៩៧៩ ខ្ញុំរត់ភៀសខ្លួនទៅរស់នៅជំរំសាយធូ ដោយមានក្ដីសង្ឃឹមថាអាចចេញទៅរស់នៅក្រៅប្រទេស ប៉ុន្តែខ្ញុំមិនទៅឡើយ។ ខ្ញុំបន្តរស់នៅអូរបុកលើភ្នំដងរែក។



ទិដ្ឋភាពស្រុកកំពង់សៀម ខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការកកើត និង ឥទ្ធិពល នៃជាតិនិយម

ព្រំ ផល្លា



ប្រជាជនកម្ពុជាវិលត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាតិនិយម ត្រូវបានផ្តល់និយមន័យថា ជាការបណ្តុះគំនិតនៃការលើកតម្កើងផលប្រយោជន៍ជាតិរបស់ខ្លួនជាធំ ដែលភាគច្រើនទាក់ទងនឹងផលប្រយោជន៍អធិបតេយ្យភាពជាតិនៃប្រទេសឬមាតុភូមិរបស់ខ្លួន។ អ្នកជាតិនិយមគិតថា មធ្យោបាយដ៏ល្អបំផុតដើម្បីធ្វើឱ្យរឿងនេះកើតឡើង និងចៀសវាងការគ្រប់គ្រងឬការគាបសង្កត់ពីជាតិផ្សេង គឺចាំបាច់ត្រូវមានជាតិឬប្រទេសផ្ទាល់ខ្លួន។ តាមនិយមន័យផ្សេងមួយទៀតនៃជាតិនិយម គឺការកំណត់អត្តសញ្ញាណនៃជាតិសាសន៍របស់ខ្លួន និងគាំទ្រផលប្រយោជន៍របស់ខ្លួនជាពិសេសចំពោះការមិនរាប់បញ្ចូលឬការធ្វើឱ្យខូចប្រយោជន៍របស់ជាតិសាសន៍ដទៃ។

ប្រវត្តិសាស្ត្រនៃការកកើតឡើងនូវជាតិនិយម ត្រូវបានរកឃើញជាបួនដំណាក់កាល រួមមាន ១. សម័យបុរេទំនើបត្រូវបានចាត់ទុកថា ជាការចាប់ផ្តើមនៃជាតិនិយមនៅសម័យបុរាណ និងមជ្ឈិមសម័យ នៅពេលដែលក្រុមមនុស្សរួមគ្នាមានភាសា វប្បធម៌ និងប្រពៃណីដូចគ្នា។ នៅចុងសតវត្សរ៍ទី១៨ និងដើមសតវត្សរ៍ទី១៩ លទ្ធិជាតិនិយមសម័យទំនើបត្រូវបានចាប់ផ្តើមដោយសារឥទ្ធិពលនៃបដិវត្តន៍នៅអាមេរិក និងបារាំង។ បដិវត្តន៍ទាំងពីរនេះបានបង្កើតឱ្យមានពីសញ្ញាណនៃប្រទេស និងគោលការណ៍នៃការគ្រប់គ្រងប្រទេសដោយខ្លួនឯង។ នៅចន្លោះសតវត្សរ៍ទី១៩ ដល់សតវត្សរ៍ទី២០ គឺជាចលនានៃការបង្រួបបង្រួម

នៃបណ្តាប្រទេសនៅក្នុងទ្វីបអឺរ៉ុប ហើយក្នុងពេលជាមួយគ្នានោះ វាគឺជាពេលដែលប្រទេសនានាក្នុងទ្វីបអឺរ៉ុបបានដាក់អាណានិគមនៅទូទាំងអាស៊ី និងអាហ្វ្រិក ហើយបានឈានទៅដល់ការតស៊ូដោយប្រទេសក្រោមអាណានិគមដើម្បីឯករាជ្យរបស់ខ្លួនពីមហាអំណាចនៅអឺរ៉ុប ដែលជាវេលានៃការកើតឡើងយ៉ាងខ្លាំងនៃជាតិនិយមៗ នៅក្នុងពេលនេះយើងស្ថិតនៅក្នុងយុគសម័យនៃសកលភាវូបនីយកម្ម ដែលជាតិនិយមនឹងកើតឡើងក្នុងចំណោមក្រុមផ្សេងគ្នា អ្នកនយោបាយ និងការខិតខំប្រឹងប្រែងដើម្បីរក្សាអត្តសញ្ញាណវប្បធម៌ជាតិ។

ជាតិនិយមនៅក្នុងប្រទេសកម្ពុជា នឹងត្រូវបានកំណត់ថាជាជាតិនិយមខ្មែរ។ ដោយសារជនជាតិខ្មែរជាប្រជាជនភាគច្រើន ដូច្នេះស្របតាមនិយមន័យនៃជាតិនិយមមានន័យថា ជាចលនាដែលបម្រើផលប្រយោជន៍ អត្តសញ្ញាណ និងវប្បធម៌របស់ជនជាតិខ្មែរ។ អត្តសញ្ញាណជាតិខ្មែរ ត្រូវបានកត់សម្គាល់ថាបានចាប់ផ្តើមនៅសម័យអាណាចក្រអង្គរ ដែលជាចំណុចកំពូលនៃអរិយធម៌ខ្មែរ ដោយមានវប្បធម៌និងស្ថាបត្យកម្មដ៏រុងរឿង។ នៅសម័យនោះ ប្រាសាទអង្គរវត្ត ត្រូវបានកសាងឡើង ហើយបានប្រែក្លាយជានិមិត្តរូប និងស្មារតីនៃមោទនភាព និងមរតកជាតិខ្មែរ។ វាច្បាស់ណាស់ថា ទម្រង់នៃជាតិនិយមត្រូវបានកំណត់ឡើងជាពិសេសដោយប្រវត្តិសាស្ត្រ ហើយត្រូវបានបន្តពីមួយសម័យកាលមួយទៅមួយសម័យកាលមានដូចជា សម័យអាណានិគម សម័យឯករាជ្យភាព និងបរិបទនយោបាយសម័យទំនើប ដែលការវិវត្តន៍នៃជាតិនិយមខ្មែរមានឥទ្ធិពលជាពិសេសពីបុសគល់នៃប្រវត្តិសាស្ត្រ។

បារាំងបានគ្រប់គ្រងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣ ក្នុងអំឡុងការគ្រប់គ្រងរយៈពេល៩០ឆ្នាំ និងការគាបសង្កត់ ដែលជាកត្តាជំរុញឱ្យកើតមានឡើងមនោសញ្ចេតនាស្រឡាញ់ជាតិក្នុងចំណោមឥស្សរជន និងបញ្ញវន្តខ្មែរ។ នេះជាកាលៈទេសៈមួយដែលបានត្រួសត្រាយផ្លូវដល់ការបង្កើតចលនារំដោះជាតិ ដែលរួមមាន ចលនាខ្មែរសេរី ចលនាខ្មែរឥស្សរៈ និងចលនាខ្មែរក្រហម។ ជាតិនិយមខ្មែររបស់ចលនាខ្មែរក្រហម ត្រូវបានគេជឿថាបានរួមចំណែកដល់ការទទួលបានជ័យជម្នះ និងឡើងកាន់អំណាចរបស់ខ្លួន។ ការកើនឡើងនៃចលនាខ្មែរក្រហមក្រោមការដឹកនាំរបស់ ប៉ុល ពត ត្រូវបានមើលឃើញថា ជាជាតិនិយមជ្រុល។ របបនេះបានប្តេជ្ញាក្នុងការកសាងប្រទេសកម្ពុជា ដែលពឹងផ្អែកទៅលើកសិកម្មដែលជាគោលនយោបាយចំបង ដោយរំពឹងថាប្រទេសកម្ពុជាមិនទទួលរងឥទ្ធិពលពីបរទេស។ មនោសញ្ចេតនាជាតិនិយមជ្រុលនេះ បានបណ្តាលឱ្យមានភាពអន្តរាយដល់សង្គមជាតិ និងសេដ្ឋកិច្ច រហូតដល់មានការសម្លាប់ប្រជាជនអស់រាប់លាននាក់ និងការកើតមានអំពើប្រល័យពូជសាសន៍។

នួន ជា ដែលជាអតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងក្រោយមកបានក្លាយជានាយករដ្ឋមន្ត្រីស្តីទី នៃរបបកម្ពុជាប្រជាធិបតេយ្យ បានផ្តល់និយមន័យខ្លីៗរបស់ខ្លួនអំពីជាតិនិយម និងស្នេហាជាតិថាជាតិនិយម «ជាការស្រឡាញ់ប្រទេសជាតិ» ប៉ុន្តែពឹងផ្អែកលើជំនួយបរទេស ចំណែកឯពាក្យស្នេហាជាតិគឺ «អារម្មណ៍ស្រឡាញ់ប្រទេសជាតិ ត្រូវពឹងផ្អែកលើប្រជាជនខ្លួនឯង» ។

ជាការពិត នួន ជា បាននិយាយក្នុងឱកាសជាច្រើនថា គាត់មិនមានអារម្មណ៍សោកស្តាយចំពោះអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមទេ។ គាត់ជឿជាក់ថា អ្វីដែលខ្មែរក្រហមបានធ្វើទៅលើប្រជាជនក្រោមការដឹកនាំរបស់គាត់ ដែលជាថ្នាក់ដឹកនាំកំពូលលំដាប់ទីពីរ គឺជាជម្រើសដ៏ត្រឹមត្រូវក្នុងការការពារប្រទេសពីការលេបត្របាក់ដោយការឈ្លានពានពីបរទេស។ គាត់បានទទួលស្គាល់ថា គាត់មានឆន្ទៈ និងមោទនភាពក្នុងការសម្លាប់ជនក្បត់ជាតិដែលគាត់ចាត់ទុកថា ជាគ្រោះថ្នាក់សម្រាប់ជាតិ ។

នួន ជា ថែមទាំងបានអះអាងក្នុងឱកាសចុងក្រោយរបស់គាត់ថា «ខ្ញុំនៅតែនិយាយថា ខ្ញុំជាអ្នកស្នេហាជាតិ ហើយខ្ញុំត្រឹមត្រូវក្នុងការតស៊ូដើម្បី

ជាតិ។ អ្នកស្នេហាជាតិដោយមានការចូលរួមក្នុងសមរភូមិ គឺមនសិការក្នុងការស្នេហាជាតិ ព្រោះវាជាការចូលរួមក្នុងចលនាតស៊ូដ៏ពិតប្រាកដ។ ដូច្នេះហើយ ការលះបង់ដើម្បីជាតិ ប្រទេសជាតិ និងប្រជាជន ហើយលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីជាតិ ទាមទារការសាកល្បងជាច្រើន ជាពិសេសអ្នកដែលមិនមែនជាកសិករ ដែលត្រូវការកម្លាំងចិត្តផ្ទាល់ខ្លួនជាច្រើនឆ្នាំ ដើម្បីក្លាយជាអ្នកជាតិនិយមពិតប្រាកដ»។

ផ្នែកមួយនៃគំនិតជាតិនិយមជ្រុលរបស់ខ្មែរក្រហម គឺការសន្យាផ្លាស់ប្តូរសង្គមកម្ពុជាដោយការបំបាត់អ្វីដែលជាឧបសគ្គចំពោះការគ្រប់គ្រងដោយខ្លួនឯង និងយុត្តិធម៌សង្គម តាមរយៈអំណាច និងថាមពលបដិវត្តន៍។ ដោយសារតែមេដឹកនាំខ្មែរក្រហមជឿថា ប្រជាជនកម្ពុជាដែលក្រីក្រតែងតែត្រូវបានគាបសង្កត់ និងធ្វើជាទាសករ ខ្មែរក្រហមបានស្វែងរកការរំដោះ និងផ្តល់អំណាចដល់អ្នកទាំងនោះ ដូច្នេះគេនឹងក្លាយជាម្ចាស់ប្រទេស។

នៅពេលដែលខ្មែរក្រហមបានគ្រប់គ្រងប្រទេស ខ្មែរក្រហមបានផ្តល់សិទ្ធិដល់ប្រជាជនមូលដ្ឋាន (អ្នកដែលរស់នៅក្នុងតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហមមុនឆ្នាំ១៩៧៥) ដែលភាគច្រើនជាប្រជាជនក្រីក្រ។ ប្រជាជនថ្មី ឬប្រជាជន១៧ មេសា ត្រូវបានបង្ខំឱ្យធ្វើការកាន់តែខ្លាំង ហើយជារឿយៗត្រូវបានកំណត់ជាគោលដៅក្នុងការសម្លាប់។ ខ្មែរក្រហមក៏បានសម្លាប់ទាហាន និងសមាជិកបក្សរបស់ខ្លួនជាច្រើន ដែលត្រូវបានចោទប្រកាន់ថា ជាជនក្បត់ជាតិ ឬប្រឆាំងនឹងការគ្រប់គ្រងរបស់ខ្លួន។

ដូចនិយមន័យនៃជាតិនិយមថា ជាភក្តីភាព និងការលះបង់ចំពោះជាតិ ជាពិសេសមនសិការជាតិដែលលើកតម្កើងជាតិសាសន៍មួយលើសជាតិសាសន៍មួយទៀត ហើយលើកស្ទួយជាសំខាន់ដល់វប្បធម៌ និងផលប្រយោជន៍របស់ខ្លួន ខុសពីជាតិសាសន៍ដទៃ ឬប្រទេសដទៃ។ ដូច្នេះវានាំឱ្យមានការបង្កើតឡើងនូវការខុសគ្នា ដើម្បីមានការបែងចែងរវាង «យើង» និង «គេ» ។

សម្រាប់ខ្មែរក្រហម ពាក្យថា «យើង» បានសំដៅប្រទេសជាតិ ប្រជាជនក្នុងវណ្ណៈកសិករ បដិវត្តន៍ និងកងទ័ព និងប្រព័ន្ធសមូហភាព។ល។ ចំពោះពាក្យថា «គេ» គឺរាប់បញ្ចូលទាំងអ្នកដែលត្រូវបានវិនិច្ឆ័យថាជាចក្រពត្តិនិយម និងសមាជិកនៃវណ្ណៈសក្តិភូមិ-មូលធននិយម ដូចជា រាជវង្ស អ្នកដែលបម្រើរបបលន់ នល់ អ្នកមាន និងអ្នកដែលរស់នៅក្នុងទីក្រុង ឬទីរួមខេត្តជាដើម។ នៅក្នុងក្រសែភ្នែករបស់ខ្មែរក្រហម ក្រុមទាំងនេះ ជាក្រុមដែលមានគ្រោះថ្នាក់ ហើយត្រូវតែវិនាស។ ភាពខុសគ្នាបែបនេះក៏បានកើតឡើងនៅប្រទេសអាល្លឺម៉ង់ ដែលជនជាតិអាល្លឺម៉ង់ ត្រូវបានចាត់ទុកឱ្យខុសពីជនជាតិជ្វីហ្វ ជនជាតិហ៊ូទូ ខុសពីទុតស៊ី ជនជាតិទួគី ខុសពីជនជាតិអាមេនី ជនជាតិបូស្នៀស៊ែប ខុសពីអ្នកកាន់សាសនាមូស្លីមជាដើម។

ជាតិនិយមពិតជាមនោគមវិជ្ជាដ៏មានអានុភាព និងស្មុគស្មាញជាមួយនឹងទម្រង់ និងផលប៉ះពាល់ផ្សេងៗ។ វាជាតួនាទីដ៏សំខាន់ក្នុងការថែរក្សា និងលើកស្ទួយឋានៈរបស់ប្រទេសជាតិ ប៉ុន្តែវានឹងជាគ្រោះថ្នាក់នៅពេលដែលវាឈានដល់ភាពជ្រុលនិយមខ្លាំងដែលអាចនាំឱ្យមានជម្លោះ សង្គ្រាម និងអំពើប្រល័យពូជសាសន៍។ សូម្បីតែនៅសហរដ្ឋអាមេរិក អ្នកប្រាជ្ញបានព្រមានពីការបន្តកើនឡើងនៃមនោគមវិជ្ជាជ្រុលនិយមរបស់ក្រុមស្បែកស។ ការធ្វើឃាតទៅលើបណ្ឌិត Luther King និងប្រធានាធិបតី John F Kennedy គឺជាមេរៀនមួយក្នុងចំណោមមេរៀនផ្សេងទៀតនៅក្នុងប្រវត្តិសាស្ត្រអាមេរិក។ គម្រោងការធ្វើឃាតមិនបានសម្រេចទៅលើបេក្ខជនប្រធានាធិបតីក្នុងពេលថ្មីនេះ គឺជាសញ្ញាមួយ។ អ្នកប្រាជ្ញដែលមានឈ្មោះល្បីអំពីការសិក្សាអំពើប្រល័យពូជសាសន៍ លោកសាស្ត្រាចារ្យកិត្តិយសអា ឡិច ហ៊ីនតុន បានសរសេរអំពីសញ្ញាព្រមាននៃអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មដ៏យោរយៅដែលអាចកើតមាន ដោយការប្រើប្រាស់មនោគមវិជ្ជាដើម្បីបំផុសអណ្តាតភ្លើងនៃសេចក្តីស្អប់ ប្រភពដើមនៃគំនិតស្តាំជ្រុលនិយមនៃអ្វីដែលគេហៅថា ការប្រល័យពូជសាសន៍ដោយអំណាចស្បែកស និងការផ្លាស់ប្តូរ និងវិធីដ៏គួរឱ្យកត់សម្គាល់ដែល «យើង» និង «គេ» ដែលអំពើហិង្សាត្រូវបានគាំទ្រដោយស្ថាប័ន និងគោលនយោបាយ ដែលប្រកាន់ពូជ

សាសន៍។ ដោយមើលឃើញពីភាពជ្រុលនិយមនៃអំណាចស្បែកសនៅក្នុងសហសម័យ សាស្ត្រាចារ្យ អា ឡិច ហ៊ីនតុនបានព្យាករណ៍ថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងអំពើឃោរឃៅអាចកើតឡើងនៅក្នុងសហរដ្ឋអាមេរិក។ ទោះយ៉ាងណាក៏ដោយ អំពើទាំងនេះអាចទប់ស្កាត់បានកុំឱ្យកើតមានឡើង។

ដើម្បីអនាគតប្រទេសកម្ពុជាគ្មានអំពើប្រល័យពូជសាសន៍ មេដឹកនាំកម្ពុជា បានលើកឡើងយ៉ាងឈ្លាសវៃក្នុងការទប់ស្កាត់នូវមនោគមវិជ្ជាជ្រុលនិយមមិនឱ្យចាក់ឫសកើតឡើងជាថ្មីនៅក្នុងសង្គមកម្ពុជា។ សម្តេចនាយករដ្ឋមន្ត្រីបានរំឭកឡើងវិញនៅក្នុងសុន្ទរកថានាពេលថ្មីៗនេះថា «ប្រវត្តិសាស្ត្រដែលល្អយើងត្រូវខិតខំប្រឹងប្រែងដើម្បីដោគជ័យ ប៉ុន្តែប្រវត្តិសាស្ត្រដែលជូរចត់ត្រូវចងចាំ ហើយធ្វើយ៉ាងណាជៀសវាងឱ្យបាន ជាពិសេសការប្រព្រឹត្តអំពើជ្រុលនិយមការកាប់សម្លាប់ប្រជាពលរដ្ឋ”។

លោកក៏បានផ្តល់អាទិភាពដល់ការអប់រំ ដែលជាយន្តការមួយក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ដោយលោកមានប្រសាសន៍ថា «ស្ថាប័នរដ្ឋាភិបាលទាំងអស់ ទាំងយោធា និង ស៊ីវិល ត្រូវតែគាំទ្រការងារអប់រំពីអំពើប្រល័យពូជសាសន៍សម្រាប់មនុស្សជំនាន់ក្រោយ។ យើងត្រូវតែធានាថា ការបង្រៀនប្រវត្តិសាស្ត្រត្រូវបានដាក់បញ្ចូលយ៉ាងត្រឹមត្រូវនៅក្នុងកម្មវិធីសិក្សារបស់សាលារដ្ឋ និង ឯកជន ចាប់ពីអនុវិទ្យាល័យរហូតដល់សាកលវិទ្យាល័យ ហើយគ្រូបង្រៀនទាំងអស់របស់យើង អាចចូលរួមជាកម្លាំងដើម្បីផ្សព្វផ្សាយការអប់រំពីអំពើប្រល័យពូជសាសន៍នៅក្នុងសាលារៀនទូទាំងប្រទេស។ ការអប់រំពីអំពើប្រល័យពូជសាសន៍ មិនចាំបាច់កំណត់ត្រឹមតែមេរៀនប្រវត្តិសាស្ត្រនោះទេ។ យើងក៏អាចបញ្ចូលទៅក្នុងមុខវិជ្ជាគ្រប់ប្រភេទ ចាប់ពីសីលធម៌ និង អក្សរសាស្ត្រខ្មែរ រហូតដល់ការសិក្សាពីភាពជាអ្នកដឹកនាំ និង ការអភិវឌ្ឍជំនាញទន់ផ្សេងទៀតផងដែរ។ យើងក៏អាចស្វែងរកវិធីច្នៃប្រឌិតផ្សេងៗ ដើម្បីរៀបរាប់រឿងរ៉ាវពិបាកទាំងនេះ ទៅកាន់មនុស្សដែលមានវ័យ និង ជំនាន់ផ្សេងគ្នារួមមាន តាមរយៈសិល្បៈ មាតិកាឌីជីថល ឬ គំនូរជីវចល ជាដើម។» ។

ដូច្នេះ វាមានសារសំខាន់ណាស់ក្នុងការស្វែងយល់ពីសមាសភាពផ្សេងនៃជាតិនិយម និងបរិបទប្រវត្តិសាស្ត្ររបស់ខ្លួនដើម្បីសម្របប្រទេសជាមួយនឹងនយោបាយសកលភាវូបនីយកម្មក្នុងពេលបច្ចុប្បន្ន ហើយការអប់រំអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងអំពើឃោរឃៅ គួរតែនៅពាក់ព័ន្ធគ្រប់ពេល។



ប្រជាជនកម្ពុជាវិលត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រទេសរ៉្វាន់ដា បានប្រារព្ធខួបលើកទី ៣០ឆ្នាំ

## ក្រោយពីមានអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិទុតស៊ី

*មីន សាណាស់*



កិច្ចប្រជុំនៅអង្គការសហប្រជាជាតិទាក់ទងនឹងអំពើប្រល័យពូជសាសន៍ដែលកើតឡើងនៅក្នុងប្រទេសរ៉្វាន់ដា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រទេសរ៉្វាន់ដា ប្រារព្ធខួបលើកទី៣០ឆ្នាំ ក្រោយពីមានអំពើប្រល័យពូជសាសន៍ពីក្រុមហ៊ូទូ ប្រឆាំងនឹងជនជាតិទុតស៊ី។ ស្ថាប័ន Aegis Trust កំពុងរៀបចំសន្និសីទសកល ក្រោមប្រធានបទថា «ការស្តាប់ និងការដឹកនាំ៖ សិល្បៈ និងវិទ្យាសាស្ត្រនៃសន្តិភាព ភាពធន់ និងការផ្លាស់ប្តូរយុត្តិធម៌ ស្តីពីការផ្សះផ្សា ការអត់ឱន និងសន្តិភាព» ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៤ នៅទីក្រុងគីហ្គាលី ប្រទេសរ៉្វាន់ដា ដែលមានការចូលរួមពីសំណាក់សាស្ត្រាចារ្យ អ្នកស្រាវជ្រាវផ្នែកគោលនយោបាយ និងអ្នកកសាងសហគមន៍។ នៅក្នុងនោះក៏មានការចូលរួមពីមជ្ឈមណ្ឌលឯកសារកម្ពុជា តំណាងដោយអ្នកស្រី សូ ហ្វារីណា នាយករង និងសហការីចំនួនពីររូបទៀតចូលរួម និងពិភាក្សាលើព្រឹត្តិការណ៍ដ៏សំខាន់នេះ។

មជ្ឈមណ្ឌលឯកសារកម្ពុជា បានបោះពុម្ពសៀវភៅមួយក្បាលមានចំណងជើងថា «អំពើប្រល័យពូជសាសន៍ និង ការសម្លាប់រង្គាល នៅក្នុងប្រវត្តិសាស្ត្រពិភពលោក» កាលពីឆ្នាំ២០១៩ និងបានរកឃើញថា៖ ការសម្លាប់រង្គាលលើក្រុមទុតស៊ីគឺកើតឡើងរាប់ខែរាប់ឆ្នាំនៅតាមផ្នែកផ្សេងៗនៅក្នុងប្រទេសរ៉្វាន់ដា ដែលបណ្តាលឱ្យកើតមានអំពើប្រល័យពូជសាសន៍។ កងកម្លាំងយោធា និងរដ្ឋាភិបាលបានចូលរួមនៅក្នុងការសម្លាប់យ៉ាងរង្គាលនេះ។ តាមរបាយការណ៍របស់អ្នកសង្កេតការណ៍បរទេសបានបង្ហាញថា រដ្ឋាភិបាលប្រទេសរ៉្វាន់ដា បានរៀបចំគម្រោងផែនការ ដើម្បីអនុវត្តអំពើប្រល័យពូជសាសន៍ជាប្រព័ន្ធលើជនជាតិទុតស៊ី។ ចាប់ពីល្ងាចថ្ងៃទី៦ ខែមេសា រហូតដល់ថ្ងៃទី១៨ ខែកក្កដា

ឆ្នាំ១៩៩៤ ប្រជាជនចន្លោះពី៨សែនទៅ១លាននាក់ត្រូវបានសម្លាប់នៅក្នុងអំឡុងរយៈពេល១០០ថ្ងៃ។ អំពើហិង្សានេះបានបង្ហាញថា ក្រុមហ៊ូទូបានសម្លាប់ក្រុមទុតស៊ី។ អំពើប្រល័យពូជសាសន៍នេះបានបញ្ចប់នៅពេលដែលរណសិរ្សអ្នកស្នេហាជាតិរ៉្វាន់ដា ដែលគាំទ្រដោយក្រុមទុតស៊ីបានឡើងគ្រប់គ្រងប្រទេស។ ជាច្រើនឆ្នាំកន្លងមក ទើបតុលាការអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានរកឃើញថាបុគ្គលមួយចំនួនមានពិរុទ្ធភាពក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ គឺជាកាតព្វកិច្ចរបស់មនុស្សគ្រប់រូបនៅលើពិភពលោក ហើយវាជាប្រធានបទមួយដែលមជ្ឈមណ្ឌលឯកសារកម្ពុជារំពឹងថា នឹងមានការចូលរួមពីគ្រប់សង្គមនៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅទូទាំងពិភពលោក។



រូបពីឆ្វេងទៅស្ដាំ៖ ១) អ្នកស្រី អាលីស វៃរីមូ ឌីរីទូ អគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជាទីប្រឹក្សាពិសេសទទួលបន្ទុកការទប់ស្កាត់អំពើប្រល័យពូជសាសន៍, ២) អ្នកស្រី សុភ័ក្ត្រ ភាណា ប្រធានគម្រោងស្រាវជ្រាវភាសាចិននៃមជ្ឈមណ្ឌលឯកសារកម្ពុជា, ៣) អ្នកស្រី សូ ហ្វារី នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា ចូលរួមសន្និសីទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រោមប្រធានបទ «ការស្ដាប់ និងការដឹកនាំ» ដែលធ្វើឡើងរយៈពេល៣ថ្ងៃ ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៤ នៅទីក្រុងគីហ្គាលី ប្រទេសរ៉្វាន់ដា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





# ក្រុមអ្នកស្រាវជ្រាវមកពីវិទ្យាស្ថានអប់រំអំពីសិទ្ធិមនុស្សភូមា និងបុគ្គលិកអង្គការពណ៌ឥន្ទធនូ

## ទស្សនកិច្ចព្រះរាជបណ្ណាល័យហ្វូងម៉ែ និងទីស្នាក់ការកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ជាវ៉ារដ្ឋ មេត្តា



ក្រុមអ្នកស្រាវជ្រាវមកពីវិទ្យាស្ថានអប់រំអំពីសិទ្ធិមនុស្សភូមា និងបុគ្គលិកអង្គការពណ៌ឥន្ទធនូ ទស្សនកិច្ចព្រះរាជបណ្ណាល័យ ហ្វូងម៉ែ និងទីស្នាក់ការកណ្តាលរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៤ ក្រុមអ្នកស្រាវជ្រាវមកពីវិទ្យាស្ថានអប់រំអំពីសិទ្ធិមនុស្សភូមា និងបុគ្គលិកអង្គការពណ៌ឥន្ទធនូ ចំនួន២៦នាក់ បានមកធ្វើទស្សនកិច្ចនៅព្រះរាជបណ្ណាល័យ ហ្វូងម៉ែ និងនៅ ទីស្នាក់ការកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីសិក្សាឈ្វេងយល់អំពីយុត្តិធម៌អន្តរកាលនៅប្រទេសកម្ពុជា, សន្តិភាព, ការផ្សះផ្សារបស់កម្ពុជា ជាពិសេសវិធីសាស្ត្រនៃការស្រាវជ្រាវ, ដំណើរការបញ្ចូលទិន្នន័យ, ការចងចាំ, យុត្តិធម៌, សន្តិភាព, រឿងរ៉ាវ និងបញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥-១៩៧៩)។

ដំណើរទស្សនកិច្ចរបស់ក្រុមអ្នកស្រាវជ្រាវមកពីវិទ្យាស្ថានអប់រំអំពីសិទ្ធិមនុស្សភូមា និងបុគ្គលិកអង្គការពណ៌ឥន្ទធនូ គឺមានការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកស្រី សូ ហ្វារីណា នាយករង



មជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅក្នុងឱកាសនោះ លោក ឆាំង យុ បានលើកឡើងអំពីកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា, ដំណើរការនៃការប្រមូលឯកសារដោយការចុះទៅសម្ភាសន៍ដោយផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, ការកើតឡើងនូវអំពើប្រល័យពូជសាសន៍នៅកម្ពុជា, ដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម, យុត្តិធម៌, ការផ្សះផ្សារវាងជនរងគ្រោះ និងជនដៃដល់ និងសំណងជំងឺចិត្តសម្រាប់ជនរងគ្រោះពីអំពើប្រល័យពូជសាសន៍។

លោក ឆាំង យុ ក៏បានលើកឡើងពីជំហររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលធ្វើការដោយផ្តោតសំខាន់ទៅលើជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍, ការដាក់បញ្ចូលកម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ទៅក្នុងកម្មវិធីសិក្សាជាផ្លូវការរបស់រដ្ឋ និងមិនផ្លូវការនៅតាមសហគមន៍ដាច់ស្រយាល ព្រមទាំងការយកចិត្តទុកដាក់ទៅលើសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បន្ទាប់ពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលកិច្ចការទាំងនេះត្រូវការចំណាយពេលវេលាយ៉ាងយូររហូតដល់ទៅ១៦ឆ្នាំ។

រហូតមកដល់សព្វថ្ងៃប្រទេសភូមានៅតែបន្តកើតមានជម្លោះផ្ទៃក្នុងយ៉ាងខ្លាំងក្លា ហើយត្រូវបាន





ក្រុមអ្នកស្រាវជ្រាវមកពីវិទ្យាស្ថានអប់រំអំពីសិទ្ធិមនុស្សភូមា និងបុគ្គលិកអង្គការពណ៌ឥន្ទធនូ ជួបប្រជុំជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៤។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្គាល់ថាជាប្រទេសដែលមានសង្គ្រាមស៊ីវិលអូសបន្លាយយូរជាងគេនៅក្នុងតំបន់ និងពិភពលោក។ ក្រុមអ្នកស្រាវជ្រាវរំពឹងថា កម្ពុជាអាចជាមេរៀនដល់ប្រទេសភូមាឱ្យសម្រេចបាននូវសន្តិភាពមួយក្នុងពេលអនាគត។

# សិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែន បាក់ចិញ្ចៀន ទស្សនកិច្ចសិក្សាតំបន់ប្រវត្តិសាស្ត្រយោធាតេជោ ចិនយំ

ឡុង ដានី




*សិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែនបាក់ចិញ្ចៀន ទស្សនកិច្ចសិក្សាតំបន់ប្រវត្តិសាស្ត្រយោធាតេជោ ចិនយំ ស្ថិតនៅក្នុងភូមិសាស្ត្រភូមិស្ទឹងថ្មី ត្រង់ចំណុចច្រកព្រាល និងចំណុចទួលគ្រួស នៃឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅវេលាម៉ោង៧:៣០នាទីព្រឹកថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានដឹកនាំយុវជនមកពីវិទ្យាល័យ ហ៊ុន សែន បាក់ចិញ្ចៀន ក្នុងស្រុកភ្នំក្រវាញ ចំនួន២០នាក់ ក្នុងនោះស្រីចំនួន១៧នាក់ ទៅទស្សនកិច្ចសិក្សាតំបន់ប្រវត្តិសាស្ត្រយោធាតេជោ ចិនយំ ស្ថិតនៅក្នុងភូមិសាស្ត្រភូមិស្ទឹងថ្មី ត្រង់ចំណុចច្រកព្រាល និងចំណុចទួលគ្រួស នៃឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ តំបន់ប្រវត្តិសាស្ត្រយោធាតេជោ ចិនយំ មានចម្ងាយប្រមាណ៧៤គីឡូម៉ែត្រពីទីរួមខេត្តពោធិ៍សាត់ និងប្រមាណ៣៥គីឡូម៉ែត្រពីរង្វង់មូលប្រម៉ោយនៃស្រុកវាលវែងតាមផ្លូវជាតិលេខ៥៥។

នៅមុនរដ្ឋប្រហារឆ្នាំ១៩៧០ ចំណុចភូមិសាស្ត្រចិនយំ ស្ថិតក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ គឺជាកន្លែងដែលជនជាតិដើមភាគតិចព័ររស់នៅ ធ្វើចម្ការដាំស្រូវ បរបាញ់សត្វ រកខ្លឹមច័ន្ទក្រឹះស្នា រុក្ខជាតិកម្រ




*តំបន់ប្រវត្តិសាស្ត្រយោធាគេជោ ចិនយំ ស្ថិតនៅក្នុងភូមិសាស្ត្រភូមិស៊ឹងថ្មី ត្រង់ចំណុចច្រកព្រាល និងចំណុចទួលគ្រួស នៃឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

បេះផ្លែក្រវាញ និងផ្លែដង្កោ លក់ដើម្បីចិញ្ចឹមជីវិត។ បើតាមអ្នកភូមិជនជាតិដើមភាគតិចព័រដែលរស់នៅភូមិស៊ឹងថ្មីចំណុចទួលគ្រួសនៅក្បែរតំបន់ប្រវត្តិសាស្ត្រយោធាគេជោចិនយំ បាននិយាយតៗគ្នាថា កាលពីមុន និងអំឡុងសង្គ្រាមលោកលើកទី២អំឡុងឆ្នាំ១៩៤៥ មានជនជាតិចិនបានរត់ភៀសខ្លួនមករស់នៅប្រទេសកម្ពុជា ហើយក៏មានជនជាតិចិនមួយចំនួនបានមករស់នៅក្នុងស្រុកភ្នំក្រវាញក្បែរតំបន់ភូមិសាស្ត្រចិនយំ ដោយបានប្រកបរបររកស៊ីលក់ដូរដូចជា លក់ស្រា ទឹកត្រី អ៊ីវ៉ាន់ចាប់ហួយ និងរបស់របរផ្សេងៗទៀត។ នៅខណៈពេលដែលជនជាតិចិនបានរែកអ៊ីវ៉ាន់យកទៅលក់ឱ្យអ្នកស្រុកដែលជាជនជាតិដើមភាគតិចព័រ នៅភូមិទួលគ្រួស និងភូមិដទៃទៀតនៅតាមផ្លូវធ្វើដំណើរមានសភាពចំណោត មានផ្ទាំងថ្មធំៗរដិបរដុប និងរអិលនៅរដូវវស្សា បណ្តាលឱ្យជនជាតិចិនបានដួលកំពប់អ៊ីវ៉ាន់ បែកឪទីនស្រា និងទឹកត្រីអស់។ ដោយសារតែមានការសោកស្តាយអ៊ីវ៉ាន់ស្រា និងទឹកត្រី ហើយមានភាពអស់កម្លាំងផងនោះ ជនជាតិចិនក៏បានអង្គុយយំ។ បន្ទាប់មកចំណុចដែលជនជាតិចិនបានដួលបែកឪទីនស្រា ទឹកត្រី និងអង្គុយយំនោះ ត្រូវបានអ្នកភូមិជនជាតិដើមភាគតិចព័រហៅថា ចំណុចចិនយំ រហូតមកដល់សព្វថ្ងៃ។

នៅរបបសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥) ចំណុចភូមិសាស្ត្រចិនយំ ស្ថិតក្នុងតំបន់រំដោះរបស់ខ្មែរក្រហម។ ចំណុចភូមិសាស្ត្រចិនយំ ស្ថិតនៅក្នុងស្រុកពាមព្រូស ដែលជាស្រុកថ្មីដែលខ្មែរក្រហមបានបង្កើតឡើងក្នុងចន្លោះឆ្នាំ១៩៧២ និងឆ្នាំ១៩៧៣។ ស្រុកពាមព្រូស ស្ថិតក្នុងតំបន់៦ភូមិភាគពាយ័ព្យ។

នៅឆ្នាំ១៩៧៧ មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បានរំលាយស្រុកពាមព្រូស និងតំបន់៦ នៃភូមិភាគពាយ័ព្យ ដោយសារមេដឹកនាំខ្មែរក្រហមបានចោទប្រកាន់មេដឹកនាំតំបន់៦ និងស្រុកពាមព្រូសបានក្បត់អង្គការខ្មែរក្រហមចូលដៃចូលជើងជាមួយប្រទេសថៃ និងបណ្តោយឱ្យប្រជាជនរត់ភៀសខ្លួនទៅប្រទេសថៃ។ ក្នុងអំឡុងឆ្នាំ១៩៧៧ នេះដែរខ្មែរក្រហមបានជម្លៀសប្រជាជនដែលជាជនជាតិដើមភាគតិចព័ររស់នៅក្នុងភូមិទួលគ្រួស ក្បែរចំណុចភូមិសាស្ត្រចិនយំ និងភូមិ ឃុំផ្សេងៗទៀតក្នុងស្រុកពាមព្រូសឱ្យមករស់នៅក្នុងស្រុកភ្នំក្រវាញ ស្រុកបាកាន និងស្រុកមោងឫស្សី តំបន់២ភូមិភាគពាយ័ព្យ។ ចាប់ពីពេលនោះមកចំណុចភូមិសាស្ត្រចិនយំ ភូមិទួលគ្រួស និងភូមិឃុំនៃស្រុកពាមព្រូសទាំងមូលលែងមានប្រជាជនរស់នៅ គឺមានតែវត្តមានកងទ័ពនៃកងវរសេនាធំមួយចំណុះកងពលទី២ភូមិភាគពាយ័ព្យមកប្រចាំការនៅតំបន់ព្រំដែនកម្ពុជា-ថៃ

(ត្រង់ឃុំថ្មដា ស្រុកវាលវែងសព្វថ្ងៃ)។ ខ្មែរក្រហមបានសង់បន្ទាយកងទ័ពនៅតំបន់ផ្ទះ២០ (បច្ចុប្បន្នឃុំអន្លង់រាបស្រុកវាលវែង) តំបន់ផ្ទះ៥ (បច្ចុប្បន្នភូមិដីក្រហម ឃុំអន្លង់រាប) ស្ថិតនៅជាប់នឹងភ្នំ១៥០០ឬភ្នំស្វារអិល និងតំបន់ផ្ទះ៧ ស្ថិតនៅត្រើយខាងកើតស្ពានជ័យជម្នះ (ស្ពានមេទឹក) ក្នុងឃុំថ្មដា ស្រុកវាលវែង ជាដើម។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ កម្មាភិបាល កងទ័ព និងមេដឹកនាំខ្មែរក្រហមមួយចំនួនបានភៀសខ្លួនពីភ្នំពេញ និងភូមិភាគនានាមកតាមផ្លូវជាតិលេខ៥៦ចាស់នេះ ដើម្បីទៅលាក់ខ្លួននៅព្រំដែនកម្ពុជា-ថៃ តំបន់សមរភូមិកោះកុង-សំឡូត ក្នុងគោលបំណងធ្វើសង្គ្រាមទ័ពព្រៃវាយបកមកលើកងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាវិញ។

បន្ទាប់មក កងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏បានប្រើប្រាស់កំណាត់ផ្លូវជាតិលេខ៥៦ចាស់ ក្នុងការដឹកជញ្ជូនកងកម្លាំង សព្វាវុធ និងស្បៀងទៅផ្គត់ផ្គង់នៅទីតាំងសមរភូមិមុខ លើផ្លូវជាតិលេខ៥៦ ចាស់នេះ។ ភូមិសាស្ត្រចំណុចចិនយំនេះ គឺជាចំណុចដែលមានឧបសគ្គខ្លាំងជាពិសេសនៅក្នុងរដូវវស្សា។ នៅខណៈពេលដែលរថយន្តដឹកកងកម្លាំង ដឹកស្បៀងឆ្លងកាត់ចំណុចនេះ បានចំណាយពេលប្រមាណកន្លះម៉ោងទៅមួយម៉ោងក្នុងចម្ងាយផ្លូវមិនដល់មួយគីឡូម៉ែត្រ ពីព្រោះចំណុចភូមិសាស្ត្រចិនយំនេះ គឺជាកន្លែងដែលត្រូវបើករថយន្តឡើងភ្នំដែលមានផ្ទាំងថ្ម និងមានដីក្រហែងក្រហូងធំៗ។ ចំណុចនេះក៏មានភ្នំអមសងខាង និងមានស្មៅនៅខាងត្បូងផ្លូវដែលបង្កលក្ខណៈងាយស្រួលឱ្យកងកម្លាំងខ្មែរក្រហមធ្វើដំណើរឆ្លងកាត់ វាយឆ្មក់ និងដាក់មីនមកលើរថយន្តកងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ មុនពេលរថយន្តឆ្លងកាត់ចំណុចភូមិសាស្ត្រចិនយំម្តងៗ កងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពនៃកងពលលេខ១៤ តែងតែតម្រូវឱ្យកងកម្លាំងត្រួតពិនិត្យបោសសម្អាតមីន និងយាមការពារតាមផ្លូវយ៉ាងហ្មត់ចត់ក្រែងមាន



សិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែន បាក់ចិញ្ចៀន ទស្សនកិច្ចសិក្សាតំបន់ប្រវត្តិសាស្ត្រយោធាតេជោ ចិនយំ ស្ថិតនៅក្នុងភូមិសាស្ត្រភូមិស្មឹងថ្មី ត្រង់ចំណុចច្រកព្រាល និងចំណុចទួលគ្រូស នៃឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កងទ័ពខ្មែរក្រហមដាក់មីន ឬក៏ចាំពួនស្ទាក់វាយមកលើរថយន្ត និងកងទ័ពៗ ទោះបីជាមានការត្រួតពិនិត្យយ៉ាងណាក៏ដោយ ក៏មានពេលខ្លះរថយន្តបានបរកិនគ្រាប់មីន កងទ័ពមួយចំនួនតូចត្រូវរបួសស្លាប់ និងមានការប្រយុទ្ធគ្នាជាមួយកងទ័ពខ្មែរក្រហមនៅចំណុចភូមិសាស្ត្រចិនយំនេះដែរ។ បន្ទាប់ពីកងទ័ពវៀតណាមដកត្រឡប់ទៅប្រទេសខ្លួនវិញនៅឆ្នាំ១៩៨៩ កងវរសេនាតូចលេខ១៥ យោធាខេត្តពោធិ៍សាត់ បានទៅបោះទីតាំងប្រចាំការនៅក្នុងភូមិទួលគ្រួស ដែលមានចម្ងាយប្រហែល២គីឡូម៉ែត្រពីចំណុចភូមិសាស្ត្រចិនយំ។ មេបញ្ជាការកងវរសេនាតូចលេខ១៥ មានឈ្មោះ លក់ ណូក និង អោ ហោ។ បន្ទាប់មកទៀតចំណុចភូមិសាស្ត្រចិនយំនេះ ក៏ជាទីបញ្ជាការដ្ឋានមុខរបស់យោធភូមិភាគទី៥ និងតំបន់ប្រតិបត្តិការសឹករងពោធិ៍សាត់ ហើយក៏ជាទីតាំងអនុវត្តនូវគោលនយោបាយ ឈ្នះ ឈ្នះ ដោយមានអង្គភាព និងកងពលរបស់ខ្មែរក្រហមចំនួន៨ បានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជានៅស្រុកភ្នំក្រវាញនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៦។ សព្វថ្ងៃចំណុចភូមិសាស្ត្រចិនយំនៅសល់ផ្លូវចាស់ចម្ងាយប្រហែល១គីឡូម៉ែត្រ ដោយសាររាជរដ្ឋា-ភិបាលកម្ពុជាបានសាងសង់ផ្លូវជាតិលេខ៥៥ រំលងចំណុចនេះ។ បច្ចុប្បន្ន ចំណុចភូមិសាស្ត្រចិនយំត្រូវបានក្រសួងការពារជាតិ និងរាជរដ្ឋាភិបាលកម្ពុជារៀបចំជាតំបន់ប្រវត្តិសាស្ត្រយោធាតេជោ ចិនយំ។

ខាងក្រោមគឺជាចំណាប់អារម្មណ៍របស់សិស្សានុ-សិស្សដែលចូលរួមទស្សនកិច្ចសិក្សា៖

ខ្ញុំឈ្មោះ **យ៉ន សុភា** អាយុ១៨ឆ្នាំ មកពីវិទ្យាល័យ ហ៊ុន សែន បាក់ចិញ្ចៀន។ ខ្ញុំសប្បាយរីករាយដែលបានមកទស្សនកិច្ចសិក្សានៅតំបន់ប្រវត្តិសាស្ត្រយោធាចិនយំ ហើយខ្ញុំទទួលបានចំណេះដឹងបន្ថែមពីរបបខ្មែរក្រហម។ ខ្ញុំបានដឹងពីកន្លែងប្រវត្តិសាស្ត្រយោធាចិនយំ, ដឹងពីទុក្ខលំបាករបស់ប្រជាជន, ដឹងពីការចូលមករស់នៅរបស់ជនជាតិចិននៅតំបន់ចិនយំពីមុនមក។

ខ្ញុំឈ្មោះ **សុំ សូរ៉ាយុទ្ធ** អាយុ១៧ឆ្នាំ មកពីវិទ្យាល័យ ហ៊ុន សែន បាក់ចិញ្ចៀន។ ខ្ញុំសប្បាយរីករាយដែលបានមកទស្សនកិច្ចសិក្សានៅតំបន់ប្រវត្តិ-សាស្ត្រយោធាចិនយំ។ ខ្ញុំទទួលបានចំណេះដឹងបន្ថែមពីរបបខ្មែរក្រហម, ដឹងពីប្រវត្តិដែលអ្នកស្រុកដាក់ឈ្មោះចិនយំ, ស្គាល់កន្លែងប្រវត្តិសាស្ត្រកាលពីមុន និង ស្គាល់ឈ្មោះជនជាតិភាគតិចនៅស្រុកវាលវែង។

ខ្ញុំឈ្មោះ **ស្រ៊ិន ចាន់ឌី** អាយុ១៨ឆ្នាំ មកពីវិទ្យាល័យ ហ៊ុន សែន បាក់ចិញ្ចៀន។ ខ្ញុំសប្បាយរីករាយដែលបានមកទស្សនកិច្ចសិក្សានៅតំបន់ប្រវត្តិសាស្ត្រយោធាចិនយំ ហើយខ្ញុំទទួលបានចំណេះដឹងបន្ថែមពីរបបខ្មែរក្រហម។ ខ្ញុំទទួលបានបទពិសោធន៍ថ្មី និងដឹងពីប្រវត្តិសាស្ត្រក្នុងខេត្តពោធិ៍សាត់, ដឹងពីមូលហេតុដែលនាំឱ្យមានរបបប្រល័យពូជសាសន៍, ដឹងពីទុក្ខវេទនារបស់ប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, ដឹងពីការគ្រប់គ្រងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងតំបន់ប្រវត្តិសាស្ត្រយោធាចិនយំ។

ខ្ញុំឈ្មោះ **សែម ធ្យូងឌី** អាយុ១៨ឆ្នាំ មកពីវិទ្យាល័យ ហ៊ុន សែន បាក់ចិញ្ចៀន។ តាមរយៈការធ្វើដំណើរទស្សនកិច្ចសិក្សាតំបន់ប្រវត្តិសាស្ត្រយោធាចិនយំ បានធ្វើឱ្យខ្ញុំដឹងភាពអសន្តិសុខពីរបបមុន ការបាញ់វាយប្រយុទ្ធគ្នា ដែលបន្សល់ទុកជាប្រវត្តិសាស្ត្រដ៏ជូរចត់មួយសម្រាប់ខេត្តពោធិ៍សាត់។



សិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែន បាក់ចិញ្ចៀន ទស្សនកិច្ចសិក្សាតំបន់ប្រវត្តិសាស្ត្រយោធាតេជោ ចិនយំ ស្ថិតនៅក្នុងភូមិសាស្ត្រភូមិស្ទឹងថ្មី ត្រង់ចំណុចច្រកព្រាល និងចំណុចទួលគ្រួស នៃឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកម្ពុជា បោះពុម្ពសៀវភៅ «រឿងរ៉ាវក្នុងភូមិនៅសម័យខ្មែរក្រហម» ដើម្បីជាការរំឭកពីអនុស្សាវរីយ៍ និងការផ្សះផ្សាផ្លូវចិត្តរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

*មីន សាណាស់*




*សៀវភៅ «រឿងរ៉ាវក្នុងភូមិនៅសម័យខ្មែរក្រហម» បោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

សៀវភៅ **«រឿងរ៉ាវក្នុងភូមិនៅសម័យខ្មែរក្រហម»** គឺជាការប្រមូលផ្តុំនូវសាច់រឿងពីសម័យខ្មែរក្រហម ចំនួន៥៩រឿង ចេញពីស្នាដៃតែងនិពន្ធ និងសរសេររបស់អ្នកនិពន្ធខ្មែរ ដែលរៀបចំដោយលោក ផេង ពង្សរ៉ាស៊ី ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តតាកែវ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបោះពុម្ពសៀវភៅ «រឿងរ៉ាវក្នុងភូមិនៅសម័យខ្មែរក្រហម» លើកទី១ ចំនួន៥០០ក្បាល ដើម្បីតម្កល់ទុកនៅព្រះរាជបណ្ណាល័យ ហ្វូងម៉ែ, សាខាមជ្ឈមណ្ឌលឯកសារកម្ពុជានៅតាមបណ្តាខេត្តនានា និងចែកជូនសាធារណជនទៅតាមការស្នើសុំ។ គោលបំណងនៃការបោះពុម្ព និងផ្សព្វផ្សាយសៀវភៅ «រឿងរ៉ាវក្នុងភូមិនៅសម័យខ្មែរក្រហម» គឺដើម្បីជាការរំឭកពីអនុស្សាវរីយ៍នៃស្ថានភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាក្នុងរបបខ្មែរក្រហម, បង្ហាញ

ពីភាពអត់ធ្មត់របស់សហគមន៍កម្ពុជា ដើម្បីជីវិតរស់នៅ, ការកសាងសង្គមឡើងវិញ និងជួយជាផ្នែកស្មារតីផ្លូវចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឱ្យមានការធូរស្បើយអារម្មណ៍នៅពេលបច្ចុប្បន្ន និងអនាគត។

សៀវភៅ «រឿងរ៉ាវក្នុងភូមិនៅសម័យខ្មែរក្រហម» គឺសរសេរចេញពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលខ្មែរក្រហមបានប្រព្រឹត្តអំពើឃោរឃៅ និងបង្កឱ្យប្រជាជនកម្ពុជារាប់លាននាក់បានបាត់បង់អាយុជីវិត។ ក្នុងសាច់រឿងទាំងនេះ អ្នកនិពន្ធបានសរសេរឡើងវិញ ដោយមិនផ្តោតតែទៅលើការឈឺចាប់ ទុក្ខវេទនារបស់ប្រជាជន និងជីវិតផ្ទាល់ខ្លួនដែលបានឆ្លងកាត់ក្នុងរបបកម្ពុជាប្រជា-ធិបតេយ្យ ប៉ុល ពត តែប៉ុណ្ណោះទេ ប៉ុន្តែអ្នកនិពន្ធបានសរសេររំលេចឡើងនូវវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហា និងយកឈ្នះលើរឿងរ៉ាវទាំងឡាយដែលធ្លាប់ជួបប្រទះក្នុងរបបខ្មែរក្រហម។ រឿងរ៉ាវចេញពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺជាផ្នែកមួយដែលនឹងអាចជួយឱ្យប្រជាជនកម្ពុជា និងក្មេងជំនាន់ក្រោយគិតពិចារណាឡើងវិញ ពីការប្រព្រឹត្តទង្វើឃោរឃៅរបស់ខ្មែរក្រហមមកលើជនរងគ្រោះនៃរបបនេះ។

មជ្ឈមណ្ឌលឯកសារកម្ពុជា សង្ឃឹមថាសៀវភៅ «រឿងរ៉ាវក្នុងភូមិនៅសម័យខ្មែរក្រហម» នឹងចូលរួមចំណែកក្នុងការថែរក្សាសន្តិភាព និងការផ្សះផ្សានៅក្នុងសង្គមកម្ពុជា និងជួយឱ្យមានការធូរស្បើយផ្លូវចិត្តរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ការរំឭកពីអនុស្សាវរីយ៍ដែលយើងតែងតែប្រើជំនួសដោយពាក្យការចងចាំ គឺជាវិធីសាស្ត្រអហិង្សាក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងជំរុញដល់ការស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មានតួនាទីសំខាន់ក្នុងការជួយផ្សព្វផ្សាយ អប់រំយុវជនជំនាន់ក្រោយដើម្បីការពារកុំឱ្យមានអំពើប្រល័យពូជសាសន៍កើតឡើងសារជាថ្មី។



សៀវភៅ «រឿងរ៉ាវក្នុងភូមិនៅសម័យខ្មែរក្រហម» បោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សាស្ត្រាចារ្យប្រវត្តិសាស្ត្រ និងអ្នកស្រាវជ្រាវជាន់ខ្ពស់វៀតណាម សិក្សាស្រាវជ្រាវអំពី

## ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) សហការជាមួយមជ្ឈមណ្ឌលផ្សះផ្សាវាលវែង

ឡុង ដានី



សាស្ត្រាចារ្យប្រវត្តិសាស្ត្រ និងអ្នកស្រាវជ្រាវជាន់ខ្ពស់វៀតណាមសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) សហការជាមួយមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សប្តាហ៍នេះ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំដំណើរទស្សនកិច្ចសិក្សាលើកទី១៨ តាមរយៈផ្លូវរថភ្លើងដោយផ្តោតលើប្រធានបទ«ផ្លូវដែកខ្មែរក្រហម៖ ដំណើរទស្សនកិច្ចសិក្សាអំពីអំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី២ និងទី៣ ក្នុងរបបខ្មែរក្រហម»។ ដំណើរទស្សនកិច្ចសិក្សានេះ គឺមានការចូលរួមពីយុវជនគ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជា, សាស្ត្រាចារ្យប្រវត្តិសាស្ត្រ និងអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់វៀតណាម មកពីសាកលវិទ្យាល័យជាតិវៀតណាម ដើម្បីចុះធ្វើការសិក្សាស្រាវជ្រាវលើប្រវត្តិសាស្ត្រខ្មែរក្រហម និងរឿងរ៉ាវរបស់កងទ័ពស្ម័គ្រចិត្តវៀតណាមដែលបានចូលរួមប្រយុទ្ធក្នុងសង្គ្រាមផ្តួលរំលំរបបខ្មែរក្រហម។

ចាប់ពីចុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់



កាលទី២ និងទី៣ ចេញពីភូមិភាគបូព៌ាតាមផ្លូវរថភ្លើង សំដៅទៅកាន់ភូមិភាគពាយ័ព្យ (បច្ចុប្បន្នគឺខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន)។ យោងតាមឯកសាររបស់របបខ្មែរក្រហមដែលរក្សាទុកនៅបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រជាជនចន្លោះពី៤០០,០០០នាក់ ទៅ៥០០,០០០នាក់ ត្រូវបានខ្មែរក្រហមជម្លៀសដោយបង្ខំទៅកាន់ភូមិភាគពាយ័ព្យ។ ក្នុងនោះមានប្រជាជនប្រមាណ ៥០,០០០នាក់ ត្រូវបានជម្លៀសចេញពីភូមិភាគបូព៌ា រួមមានខេត្តព្រៃវែង និងខេត្តស្វាយរៀង ទៅកាន់ភូមិភាគពាយ័ព្យ។ កម្មាភិបាលខ្មែរក្រហមម្នាក់ដែលធ្វើការនៅស្ថានីយរថភ្លើងក្នុងរបបខ្មែរក្រហម បានឃើញមនុស្សរាប់ពាន់នាក់ត្រូវបានជម្លៀសតាមខ្សែរថភ្លើងពីទីក្រុងភ្នំពេញ ទៅកាន់ស្ថានីយរថភ្លើងផ្សេងៗទៀតក្នុងខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង នៃភូមិភាគពាយ័ព្យ។

ដំណើរទស្សនកិច្ចសិក្សាតាមរថភ្លើងនេះ គឺបើកទូលាយសម្រាប់ការផ្លាស់ប្តូរបទពិសោធន៍រវាងយុវជន, គ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជា ជាមួយនឹងអ្នកស្រាវជ្រាវជាន់ខ្ពស់ និងគ្រូបង្រៀនផ្នែកប្រវត្តិ-សាស្ត្រវៀតណាម ដើម្បីឈ្វេងយល់ពីគ្នាទៅវិញ



សាស្ត្រាចារ្យប្រវត្តិសាស្ត្រ និងអ្នកស្រាវជ្រាវជាន់ខ្ពស់វៀតណាមសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) សហការជាមួយមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទៅមក។ យុវជន គ្រូបង្រៀនកម្ពុជា, អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់វៀតណាម និងសាស្ត្រាចារ្យប្រវត្តិសាស្ត្រវៀតណាម នឹងមានឱកាសសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅទីតាំងឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្រោមរបបខ្មែរក្រហម នៅស្រុកកណ្តៀង, ស្រុកបាកាន និងស្រុកវាលវែង ខេត្តពោធិ៍សាត់។

អ្នកស្រាវជ្រាវជាន់ខ្ពស់វៀតណាមនឹងធ្វើដំណើរតាមរថយន្តក្រុង ដើម្បីទៅទស្សនាស្តូបតម្កល់ធាតុជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ខ្មែរក្រហម





សាស្ត្រាចារ្យប្រវត្តិសាស្ត្រ និងអ្នកស្រាវជ្រាវជាន់ខ្ពស់វៀតណាមសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) សហការជាមួយមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

និងសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលដឹងអំពីព័ត៌មានពាក់ព័ន្ធនឹងទីតាំងទាំងនោះ ព្រមទាំងទៅទស្សនាទីតាំងប្រវត្តិសាស្ត្រផ្សេងទៀត រួមមាន ទីតាំងប្រវត្តិសាស្ត្រយោធាតេជោភ្នំមាន់(A4) និងទីតាំងប្រវត្តិសាស្ត្រយោធាតេជោ ស្ពានជ័យជម្នះ ដែលជាអតីតទីស្នាក់ការកណ្ដាល និងជាសមរភូមិប្រយុទ្ធដ៏ស៊ិតស្វាញរវាងកងកម្លាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលជាសម្ព័ន្ធមិត្តជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពខ្មែរក្រហម។ នៅទីនោះ សាស្ត្រាចារ្យប្រវត្តិសាស្ត្រវៀតណាម និងអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់វៀតណាម នឹងជួបសម្ភាសន៍ជាមួយអតីតកងទ័ពស្ម័គ្រចិត្តវៀតណាមពីរនាក់ ដែលបច្ចុប្បន្នរស់នៅស្រុកវាលវែង ដើម្បីឈ្វេងយល់អំពីរឿងរ៉ាវជីវិតក្នុងសមរភូមិរបស់គាត់។

ចាប់ពីដើមឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំដំណើរទស្សនកិច្ចសិក្សាតាមរយៈផ្លូវរថភ្លើង យ៉ាងហោចណាស់១៧ដងរួចមកហើយ ផ្ដោតលើប្រធានបទ «ការជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលលើកទី២ និងទី៣ ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)» ដោយមានការចូលរួមពីយុវជនសរុបចំនួន១,០៦៦នាក់។ ប៉ុន្តែនេះគឺជាលើកទីមួយហើយដែលសាស្ត្រាចារ្យ និងអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ជនជាតិបរទេសត្រូវបានអញ្ជើញឱ្យចូលរួមសិក្សាស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈផ្លូវរថភ្លើង។ ទីក្រុងហាណូយគឺជាចំណុចចាប់ផ្ដើមនៃដំណើរទស្សនកិច្ចសិក្សាស្រាវជ្រាវនេះ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាចង់ឃើញវត្តមានចូលរួមពីសំណាក់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និងអ្នកអប់រំ

ផ្សេងទៀតមកពីក្នុងតំបន់ចូលរួមដំណើរទស្សនកិច្ចសិក្សានេះ ដើម្បីសរសេរបោះពុម្ពផ្សាយឱ្យមនុស្សគ្រប់ជាតិសាសន៍អាចសិក្សារៀនសូត្រ និងចូលរួមផ្សព្វផ្សាយប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ដើម្បីធានាថា រឿងរ៉ាវរបស់ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមិនត្រូវបានបំភ្លេចចោល។ មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការផ្តោតលើរឿងរ៉ាវផ្ទាល់ខ្លួនរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ព្រោះវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងផ្នត់គំនិត និងការផ្សះផ្សាពីអំពើប្រល័យពូជសាសន៍»។

បណ្ឌិត ហ៊ុង ធីង៉ា គឺសាស្ត្រាចារ្យប្រវត្តិសាស្ត្រមកពីមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យជាតិវៀតណាម បានថ្លែងអំណរគុណចំពោះមជ្ឈមណ្ឌលផ្សះផ្សាវាលវែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលផ្តល់ឱកាសឱ្យគាត់បានចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាស្រាវជ្រាវតាមរថភ្លើងនេះ។ លោកស្រីបណ្ឌិត បានបន្ថែមថា ដំណើរទស្សនកិច្ចសិក្សានេះនឹងជំរុញកិច្ចសហប្រតិបត្តិការផ្នែកសិក្សាលើប្រវត្តិសាស្ត្រខ្មែរក្រហមបន្ថែមទៀតរវាងកម្ពុជា និងវៀតណាមទៅថ្ងៃអនាគត។

តាមការប៉ាន់ប្រមាណ គឺមានកងទ័ពស្ម័គ្រចិត្តវៀតណាមប្រមាណ ១៥០,០០០នាក់ បានចូលមកប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៨ ដើម្បីរួមជាមួយរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ប្រយុទ្ធប្រឆាំងនឹងកងទ័ពខ្មែរក្រហម។ ភាគីវៀតណាមជឿជាក់ថា កងទ័ពស្ម័គ្រចិត្តរបស់ខ្លួនយ៉ាងតិច២០,០០០នាក់បានបាត់បង់ជីវិតក្នុងសង្គ្រាមនៅកម្ពុជា នៅពេលដែលវាយផ្តួលរំលំកងទ័ពខ្មែរក្រហម និងរបបកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

សាស្ត្រាចារ្យប្រវត្តិសាស្ត្រ និងអ្នកស្រាវជ្រាវជាន់ខ្ពស់វៀតណាមសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) សហការជាមួយមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្តល់រទេះរុញជូន អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាព នៅឃុំស្នោ ស្រុកព្រៃកប្បាស ខេត្តតាកែវ

*ផេង ពង្សរ៉ាស៊ី*





*ជីម សុខគា បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

តាមរយៈការអនុវត្តគម្រោងស្តីពី «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា យើងសង្កេតឃើញថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពមួយចំនួន មិនបានមកចូលរួមក្នុងកម្មវិធីវេទិកាអប់រំសុខភាព និងទទួលសេវាពិនិត្យសុខភាព និងពិគ្រោះយោបល់ជាមួយគ្រូពេទ្យ រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីពេលកន្លងមកថ្មីៗឡើយ។ ការខកខានមិនបានចូលរួមនេះ គឺដោយមូលហេតុពិការភាព ដែលបណ្តាលមកពីជំងឺទឹកនោមផ្អែម លើសសម្ពាធឈាម ឬស្លាប់មួយចំហៀងខ្លួន និងខ្វះខាតឧបករណ៍ជំនួយក្នុងការនាំយកគាត់មកកាន់ទីតាំងកម្មវិធី។

ដោយមូលហេតុនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតកម្មវិធីផ្តល់រទេះរុញសម្រាប់ជនពិការ និងកាសជំនួយដល់ការស្តាប់សំឡេង ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពទាំងឡាយណា ដែលធ្លាប់បានផ្តល់ការសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការប្រមែប្រមូលការ

ចងចាំពីបទពិសោធន៍ក្នុងរបបខ្មែរក្រហមនាពេលកន្លងមក។ ក្នុងដំណាក់កាលដំបូងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បាននិងកំពុងផ្តល់រទេះរុញចំនួនជាង ២០០ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព នៅតាមបណ្តាខេត្តមួយចំនួនក្នុងប្រទេសកម្ពុជា។

នាថ្ងៃទី១០ និងទី១១ ខែសីហា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បាននាំយករទេះរុញសម្រាប់ជនពិការចំនួន ៤គ្រឿងទៀត ទៅប្រគល់ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាពចំនួន៤នាក់ គឺស្រី២នាក់ និងប្រុស២នាក់ រស់នៅឃុំស្មោ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ អ្នករស់រានមានជីវិតទាំង៤នាក់នោះគឺ ៖ ១) ប៉ាន់ រិន អាយុ ៧១ឆ្នាំ គឺជាប្រធានភូមិស្មោរ ឃុំស្មោ, ២) សុង ហ៊ិត អាយុ៨២ឆ្នាំ បច្ចុប្បន្នរស់នៅភូមិទន្លេ ឃុំស្មោ, ៣) ហ៊ាន ខុន អាយុ៧០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិស្មោ ឃុំស្មោ និង ៤) ប៉ាន់ សុខ អាយុ៦៨ឆ្នាំ បច្ចុប្បន្នរស់នៅ ភូមិស្មោ ឃុំស្មោ។

គោលបំណងនៃការចែករទេះរុញ គឺដើម្បីជួយសម្រួលដល់ការធ្វើដំណើរ និងបង្កើនការប្រាស្រ័យទាក់ទងជាមួយអ្នកជិតខាង ឬចូលរួមនៅក្នុងកិច្ចការងារផ្សេងៗ រាប់ទាំងការបន្តការចែករំលែកការចងចាំពីប្រវត្តិសាស្ត្រខ្មែរក្រហមដល់យុវជនជំនាន់ក្រោយផង។ ការផ្តល់រទេះរុញនេះក៏ជួយសម្រាលបន្ទុកមួយផ្នែកដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងការចំណាយថវិកាទិញរទេះរុញ ឬឧបករណ៍ដែលអាចសម្រួលដល់ការធ្វើដំណើររបស់ខ្លួន។

រាល់ពេលដែលក្រុមការងារផ្តល់រទេះរុញជូនអ្នករស់រានមានជីវិតម្នាក់ៗ យើងសង្កេតឃើញថា អ្នករស់រានមានជីវិតទាំងអស់បានបង្ហាញអារម្មណ៍រំភើបរីករាយ និងពោលពាក្យសម្តីជូនពរដល់ក្រុមការងារ និងមជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់ការផ្តល់ជូននូវឧបករណ៍ជំនួយដល់ការរស់នៅរបស់គាត់។ អ៊ំប្រុស ប៉ាន់ សុខ អាយុ៦៨ឆ្នាំ បាននិយាយថា «ខ្ញុំបានរួចផុតពីគុកឥតជញ្ជាំងហើយ»។ អ៊ំស្រីម្នាក់ទៀតឈ្មោះ សុង ហ៊ិត អាយុ៨២ឆ្នាំ បានប្រាប់ថា គាត់អាចជិះរទេះនេះចេញក្រៅផ្ទះមើលគេ មើលឯង និងទៅវត្តបានវិញហើយ។ ចំណែកអ៊ំប្រុស ប៉ាន់ រិន អាយុ៧១ឆ្នាំ ដែលជាមេភូមិស្មោ បានបង្ហាញស្នាមញញឹមញញែម ហើយពោលពាក្យថា «ខ្ញុំចង់បានរទេះនេះយូរមកហើយ តាំងពីខ្ញុំធ្លាក់ខ្លួនឈឺដើរលែងរួចមក។ ឥឡូវខ្ញុំបានវាដូចបំណងហើយ។ កន្លងមក ខ្ញុំមានតែឈើច្រត់ឫស្សីមួយសម្រាប់កាន់ដើរទៅបន្ទប់ទឹក។ ដើរម្តងៗ ខ្ញុំពិបាកណាស់! ជួនកាលខ្ញុំដួលផងក៏មាន។ ខ្ញុំស្រឡាញ់រទេះរុញនេះណាស់។ ខ្ញុំមិនចាំបាច់ពឹងពាក់កូនចៅទៀតទេ។ ខ្ញុំនឹងរៀនជិះវាឱ្យស្ទាត់ ហើយខ្ញុំអាចចេញក្រៅផ្ទះធ្វើលំហាត់ប្រាណរៀងរាល់ព្រឹក និងល្ងាចបានដោយស្រួល។ ទោះបីជាខ្ញុំមិនជិះវា ក៏ខ្ញុំចាត់ទុកវាជាឈើច្រត់របស់ខ្ញុំ ព្រោះខ្ញុំអាចកាន់ដៃទាំងពីររបស់វាបាន។ វាមានហ្វាំងសម្រាប់ចាប់ពេលដែលខ្ញុំចង់ឈប់។ វាងាយស្រួលណាស់។ ខ្ញុំសូមអរគុណក្មួយៗ និងមជ្ឈមណ្ឌលឯកសារកម្ពុជាជាខ្លាំងណាស់ ព្រោះក្មួយ និងមជ្ឈមណ្ឌលឯកសារកម្ពុជាបានបំពេញក្តីស្រមៃរបស់ខ្ញុំ។ ខ្ញុំមិនភ្លេចគុណនេះទេ»។



ជឹម សុខគា បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សវិទ្យាល័យស្រែណូយទស្សនកិច្ចសិក្សា ស្តីពី «សន្តិភាព និងសិទ្ធិមនុស្ស» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង លើភ្នំដងរែក

**រមេក ទិន**




សិស្សវិទ្យាល័យស្រែណូយ ទស្សនកិច្ចសិក្សា ស្តីពី «សន្តិភាព និងសិទ្ធិមនុស្ស» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង លើភ្នំដងរែក នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានរៀបចំទស្សនកិច្ចសិក្សា ស្តីពី «សន្តិភាព និង សិទ្ធិមនុស្ស» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន២០នាក់ មកពីវិទ្យាល័យស្រែណូយ។ ទស្សនកិច្ចសិក្សានេះ ធ្វើឡើងក្នុងគោលបំណងឱ្យសិស្សានុសិស្សបានចូលរួមទស្សនកិច្ចទីតាំងប្រវត្តិសាស្ត្រផ្ទាល់ដែលនៅសេសសល់ពីរបបខ្មែរក្រហម ក៏ដូចជាការឆ្លុះបញ្ចាំងអំពីប្រវត្តិសាស្ត្រកាលពី២៦ឆ្នាំមុនដែលសង្គ្រាមស៊ីវិលនៅតែបន្តកើតមាននៅតំបន់អន្លង់វែង។ លើសពីនេះ ទស្សនកិច្ចសិក្សានៅថ្ងៃនេះ នឹងជួយលើកកម្ពស់តម្លៃនៃសន្តិភាព ការផ្សះផ្សា និងការអភិវឌ្ឍន៍សហគមន៍អន្លង់វែង។

នៅវេលាម៉ោង៨៖៣០នាទីព្រឹក សិស្សានុសិស្សបានធ្វើដំណើរមកដល់ការិយាល័យលើខ្នងភ្នំដងរែក ដែលជាអតីតផ្ទះប្រជុំរបស់ តាម៉ុក ហើយក្លាយជាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងពេលបច្ចុប្បន្ន។ សិស្សានុសិស្សទាំងនោះ មានទឹកមុខសប្បាយរីករាយ ពេលឃើញក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រង់ចាំទទួលស្វាគមន៍។

ជាកិច្ចចាប់ផ្តើម បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រួមទាំងក្រុមការងារ បានធ្វើការណែនាំខ្លួនដល់សិស្សានុសិស្ស។ បន្ទាប់មក បណ្ឌិត លី សុខឃាង ធ្វើការសម្របសម្រួល និងធ្វើបទបង្ហាញទៅកាន់សិស្សានុសិស្ស ដោយផ្តោតសំខាន់លើកិច្ចការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលបានធ្វើកន្លងមក ជាពិសេសបានលើកយកបរិបទប្រវត្តិសាស្ត្រជុំវិញការកកើតរបបខ្មែរក្រហម សោកនាដកម្មក្រោមអំពើឃោរឃៅ និងការបិទបញ្ចប់នូវទំព័រប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាមកបង្ហាញ។ នៅក្នុងឱកាសនោះដែរ «ប្លង់គោលស្រុកអន្លង់វែង» ក៏ត្រូវបានបញ្ចាំងជូនដល់សិស្សានុសិស្សទស្សនា និងឈ្វេងយល់អំពីការអភិវឌ្ឍន៍សហគមន៍អន្លង់វែងទៅជាទីក្រុងសន្តិភាព ការបង្កើតជីវិតថ្មី និងភាពរុងរឿងនៅតំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហម។

កម្មវិធីបន្ទាប់ បណ្ឌិត លី សុខឃាង ចាក់បញ្ចាំងខ្សែភាពយន្តឯកសារ «ខ្មែរបាត់បង់តន្ត្រីករ» រួមទាំងកុនឯកសារមន្ទីរសន្តិសុខស-២១ ដល់សិស្សានុសិស្សបានទស្សនា។ សិស្សានុសិស្សមួយចំនួនមានភាពរន្ធត់ នៅពេលបានឃើញសាកសពហើមស្អុយជាប់ដោយខ្នោះដៃជើងនៅក្នុងមន្ទីរស-២១ នៅក្នុងខ្សែភាពយន្តឯកសារ ដែលបង្ហាញដល់យុវជនឱ្យឃើញពីការធ្វើទារុណកម្មយ៉ាងព្រៃផ្សៃនៅក្នុងរបបខ្មែរក្រហមមកលើប្រជាជនខ្មែរ។ នៅក្នុងឱកាសនោះ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក៏បានចែកសៀវភៅទស្សនាវដ្តី ស្វែងរកការពិត(លេខពិសេស) ជូនសិស្សានុសិស្ស សម្រាប់អាន និងសិក្សារៀនសូត្រ។ បន្ទាប់មកទៀត សិស្សានុសិស្សក៏បន្តដំណើរទៅកាន់ទីតាំងប្រវត្តិសាស្ត្រសំខាន់ៗមួយចំនួនដូចជា ទីតាំងបូជាសពប៉ុល ពត, ទីតាំងបូជាសពសុន សេន និងក្រុមគ្រួសារ, កន្លែងលាក់ខ្លួនប៉ុល ពត, ចេតិយ តាម៉ុក និងសារមន្ទីរ តាម៉ុក។

គួររំឭកថា «ដំណើរទស្សនកិច្ចសិក្សាស្តីពីសន្តិភាព និងសិទ្ធិមនុស្ស» ធ្វើឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងទៅលើប្រវត្តិសាស្ត្រដល់យុវជន ការកសាងសន្តិភាព និងការផ្សះផ្សា។ ក្នុងនោះក៏មានការចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាមកកាន់តំបន់ប្រវត្តិសាស្ត្រតស៊ូចុងក្រោយរបស់ខ្មែរក្រហម ពី ឯកអគ្គរដ្ឋទូតតាមបណ្តាប្រទេសនៃសមាជិកអាស៊ាន រួមមាន៖ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក, ឯកអគ្គរដ្ឋទូត ហ្វីលីពីន, ឯកអគ្គរដ្ឋទូតសិង្ហបុរី, ឯកអគ្គរដ្ឋទូត អូស្ត្រាលី, រួមទាំងឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន និងភរិយា ក្នុងនោះក៏មាន សាស្ត្រាចារ្យ សុង ហូកាង នៃប្រទេសកូរ៉េ ដែរ។

ក្រោយបញ្ចប់ដំណើរទស្សនកិច្ច សិស្សវិទ្យាល័យស្រែណូយបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

ខ្ញុំឈ្មោះ **រាជ គន្ធា** ភេទស្រី អាយុ១៩ឆ្នាំ មកពីវិទ្យាល័យស្រែណូយ។ ខ្ញុំមានអារម្មណ៍ត្រេកអរណាស់ ដែលមានឱកាសបានចូលរួមក្នុងដំណើរទស្សនកិច្ចតំបន់ប្រវត្តិសាស្ត្រនៅអន្លង់វែង។ គោលបំណងដែលខ្ញុំចង់មកគឺសិក្សាឈ្វេងយល់ទីតាំងប្រវត្តិសាស្ត្រផ្ទាល់ភ្នែក និងការពង្រឹងការយល់ដឹងផ្នែកប្រវត្តិសាស្ត្របន្ថែម។ ចំពោះការធ្វើដំណើរទៅកាន់ទីតាំងប្រវត្តិសាស្ត្រនីមួយៗ ខ្ញុំយល់ឃើញថា ខ្ញុំពិតជាបានសិក្សារៀនសូត្រច្រើនអំពីដើមហេតុនៃការមកតាំងទីលំនៅចុងក្រោយរបស់ខ្មែរក្រហម នៅតំបន់អន្លង់វែង។ ខ្ញុំឃើញពីលក្ខណៈពិសេស និងខ្លឹមសារដែលសរសេរបង្ហាញទីតាំងប្រវត្តិសាស្ត្រនីមួយៗបានកាន់តែច្បាស់។ ទីតាំងទាំងអស់ ខ្ញុំចាប់អារម្មណ៍ទៅលើទីតាំងផ្ទះលាក់ខ្លួនរបស់ ប៉ុល ពត ជាងគេ ដោយសារ ប៉ុល ពត អាចរកទីតាំងលាក់ខ្លួនបានយ៉ាងល្អដោយគ្មានអ្នកណាងាយរកឃើញ។ ក្រៅពីនេះ ខ្ញុំបានឈ្វេងយល់ និងស្គាល់ តាម៉ុក បានកាន់តែច្បាស់ ព្រមទាំងបានស្គាល់ពីផ្ទះរស់នៅរបស់គាត់កាលពីជំនាន់សង្គ្រាម។ នៅពេលខ្ញុំបានមកដល់ទីតាំងផ្ទាល់ ខ្ញុំអាចស្រមៃឃើញពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងទីតាំងនីមួយៗ។ ជាចុងក្រោយ ខ្ញុំសូមអរគុណទៅដល់ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលតែងតែផ្តល់ឱកាសដល់សិស្សានុសិស្សអាចសិក្សារៀនសូត្រពីទីតាំងប្រវត្តិសាស្ត្រនៅក្នុងស្រុកអន្លង់វែង។

ខ្ញុំឈ្មោះ **រី ចន្ថា** ភេទប្រុស អាយុ២១ឆ្នាំ មកពីវិទ្យាល័យស្រែណូយ។ ការចូលរួមក្នុងដំណើរ

ទស្សនកិច្ចនៅថ្ងៃនេះ ធ្វើឱ្យខ្ញុំបានយល់ដឹងកាន់តែច្រើនអំពីប្រវត្តិសាស្ត្រដ៏ជូរចត់ ដូចជា ខ្ញុំបានស្គាល់ឈ្មោះមេដឹកនាំក្នុងរបបខ្មែរក្រហមរួមមានប៉ុល ពត, តាម៉ុក, នួន ជា និង ខៀវ សំផន។ ខ្ញុំបានដឹងពីទីកន្លែងស្លាប់របស់ ប៉ុល ពត, សុន សេន និងគ្រួសារ។ ការធ្វើដំណើរទៅកាន់ទីតាំងប្រវត្តិសាស្ត្រនីមួយៗ ខ្ញុំចាប់អារម្មណ៍ទៅលើសារមន្ទីរផ្ទះ តាម៉ុក ជាងគេ ដោយសារនៅទីនោះមានសំណង់ផ្ទះទាំងបួនហើយត្រូវបានថែរក្សាទុករហូតមកដល់បច្ចុប្បន្ននេះ។ សំណង់ទាំងនេះបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយបានសិក្សារៀនសូត្រ និងបានឃើញដោយផ្ទាល់។ ខ្ញុំមិនចង់ឱ្យកើតមានអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាទៀតទេ។ ខ្ញុំចង់ឱ្យប្រទេសកម្ពុជាស្ថិតនៅក្នុងសន្តិភាពជារៀងរហូត។ ដូច្នេះហើយ ទើបខ្ញុំខិតខំរៀនសូត្រ ដើម្បីចូលរួមការអភិវឌ្ឍន៍សង្គមជាតិ។

ខ្ញុំឈ្មោះ **សុខ លីណា** ភេទស្រី អាយុ១៨ឆ្នាំ មកពីវិទ្យាល័យស្រែណូយ។ ដំណើរទស្សនកិច្ចនៅថ្ងៃនេះគឺជាលើកទីមួយសម្រាប់ខ្ញុំ ហើយខ្ញុំទទួលបាននូវបទពិសោធន៍ថ្មីៗ និងយល់ដឹងពីប្រវត្តិសាស្ត្រដែលមាននៅក្នុងស្រុកអន្លង់វែង។ ជាក់ស្តែង ពីមុនមកខ្ញុំធ្លាប់តែរៀនតាមសៀវភៅ និងពុចាស់ៗនិយាយប្រាប់តៗគ្នាថា នៅក្នុងសម័យនោះមានការលំបាកខ្លាំង ប៉ុន្តែមិនដែលបានជួបផ្ទាល់ និងឃើញពីរូបភាពព្រមទាំងទីតាំងទាំងនេះផ្ទាល់ទេ។ ខ្ញុំបានមកជួប និងឃើញផ្ទាល់ពីទីតាំងរស់នៅរបស់មេដឹកនាំខ្មែរក្រហម។ ខ្ញុំបានឃើញទីតាំងបូជាសាកសពប៉ុល ពត ដែលជាមេខ្លោងធំក្នុងរបបខ្មែរក្រហម និងឃើញចេតិយ តាម៉ុក នៅក្នុងវត្តស្រះឈូក រួមទាំងផ្ទះស្នាក់នៅរបស់ តាម៉ុក។

ខ្ញុំឈ្មោះ **សាំ ស្រីនីន** ភេទស្រី អាយុ២០ឆ្នាំ មកពីវិទ្យាល័យស្រែណូយ។ ខ្ញុំមានអារម្មណ៍រំភើប និងរីករាយដែលបានមកទស្សនាទីតាំងប្រវត្តិសាស្ត្រផ្ទាល់ រួមទាំងបានសិក្សារៀនសូត្របន្ថែមពីប្រវត្តិសាស្ត្រកាលពីជំនាន់ខ្មែរក្រហម។ ការចូលរួមទស្សនកិច្ចសិក្សានៅថ្ងៃនេះធ្វើឱ្យខ្ញុំបានស្គាល់ពីទីតាំង បូជាសព ប៉ុល ពត ទីតាំងបូជាសព សុន សេន និងគ្រួសារ និងទីតាំងចេតិយ តាម៉ុក។ ខ្ញុំចាប់អារម្មណ៍លើសារមន្ទីរផ្ទះតាម៉ុក ដោយសារនៅទីនោះមានភាពលេចធ្លោជាងគេ និងមានរូបគំនូរប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ រួមទាំងរូបគំនូរផែនទីប្រទេសកម្ពុជា។ ទីតាំងពិសេសមួយទៀត គឺទីតាំងផ្ទះលាក់ខ្លួនរបស់ប៉ុល ពត ដែលជាទីតាំងមួយដ៏កម្រនៅក្នុងសម័យសង្គ្រាម។ ពេលទស្សនាខ្សែភាពយន្តឯកសារ មន្ទីរសន្តិសុខស-២១ ខ្ញុំចាប់អារម្មណ៍ទៅលើរូបភាពអ្នកទោសដេកស្លាប់ដោយមានវះពោះ និងជាប់ច្រវាក់ ធ្វើឱ្យខ្ញុំមានភាពតក់ស្លុត និងភ័យខ្លាចពីទិដ្ឋភាពនៅក្នុងគុកទួលស្លែង។







សិស្សវិទ្យាល័យស្រែណូយទស្សនកិច្ចសិក្សាស្តីពី «សន្តិភាព និងសិទ្ធិមនុស្ស» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង លើភ្នំដងរែក នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# នុត ជៀន ៖ ខ្ញុំភ័យខ្លាចចំពោះគ្រាប់បែក អាមេរិកាំងនៅជាប់សំយាបផ្ទះខ្ញុំ

ផេង ពង្សរ៉ាស៊ី



នុត ជៀន អាយុ៨១ឆ្នាំ រស់នៅភូមិតាកោ សង្កាត់តាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គ្រាប់មិនទាន់ផ្ទុះមួយគ្រាប់យ៉ាងធំ កំពុងស្ថិតនៅក្នុងដីជាប់សំយ៉ាបផ្ទះអ្នករស់រានមានជីវិតរបបខ្មែរក្រហមម្នាក់រស់នៅភូមិតាកោ សង្កាត់តាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។ នេះបើតាមការអះអាងរបស់លោកតា នុត ជៀន អាយុ៨១ឆ្នាំ ដែលជាម្ចាស់ផ្ទះស្ថិតនៅក្បែរទីនេះណោះ គ្រាប់។ ជៀន បានឃើញហេតុការណ៍ទម្លាក់គ្រាប់បែកនេះដោយផ្ទាល់ភ្នែកក្នុងអំឡុងពេលប្រទេសកម្ពុជាកំពុងជួបប្រទះនឹងសង្គ្រាមពុំរ៉ៃកាលពីដើមទសវត្សរ៍ឆ្នាំ១៩៧០។ អស់រយៈពេលជាង៥០ឆ្នាំកន្លងផុតទៅ គ្រាប់មិនទាន់ផ្ទុះមួយនេះ នៅតែបន្តភាពភ័យខ្លាចដល់ម្ចាស់ផ្ទះ និងអ្នកភូមិរស់នៅជិតនោះ។ ជៀន បានប្រាប់ថា វាគឺជាស្រមោលអតីតកាលនៃយន្តហោះសហរដ្ឋអាមេរិកនៅក្នុងទឹកដីប្រទេសកម្ពុជា ដែលបានបំផ្លាញផ្ទះសម្បែង ជីវិតមនុស្ស និងដីស្រែរាប់សិបហិកតាកាលពីសម័យសង្គ្រាម។

ចាប់តាំងពីរបបសង្គមរាស្ត្រនិយម ត្រូវបានផ្តួលរំលំដោយរដ្ឋប្រហាររបស់សេនាប្រមុខ លន់ នល់ ភូមិតាកោ បានធ្លាក់ចូលក្នុងភាពចលាចល។ ការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងទាហានខ្មែររំដោះបាន

កើតមានជាហូរហែនៅក្នុងភូមិ និងជុំវិញភូមិ រហូតធ្វើឱ្យមានការបែងចែកទឹកដីគ្នាគ្រង់គ្រង។ ក្រុមខ្មែររំដោះ បានកាន់កាប់ទឹកដីមួយផ្នែកធំក្នុងខេត្តព្រៃវែង។ ភូមិតាកោ បានក្លាយជាទឹកដីនៃតំបន់រំដោះ ហើយទីកន្លែងមួយចំនួនក្នុងភូមិ បានក្លាយជាកន្លែងប្រមូលផ្តុំរបស់កងយោធាខ្មែររំដោះ។ អ្នកភូមិភាគច្រើនមិនបានប្រកបរបរធ្វើស្រែចម្ការដូចសព្វមួយដងឡើយ ដោយសារតែមានការរំខានពីការប្រយុទ្ធគ្នានៅពេលយប់ និងទម្លាក់គ្រាប់បែកនៅពេលថ្ងៃ។ ដៀន និងគ្រួសារ បានចាកចេញពីផ្ទះសម្បែងទៅរស់នៅតាមទីកន្លែងផ្សេងៗក្នុងស្រុកព្រៃវែង ដូចជាខ្សោត ស្វាយអន្ទរ និង ត្រយ៉ូង ដើម្បីគេចចេញពីគ្រាប់ផ្លោង និងការប្រយុទ្ធគ្នា។ ការចាកចេញរបស់ ដៀន គឺដោយសារបានឃើញផ្ទាល់ភ្នែកនូវការទម្លាក់គ្រាប់បំផ្លាញផ្ទះសម្បែងប្រជាជន និងភ័យរន្ធត់ចំពោះគ្រាប់មិនទាន់ផ្ទុះមួយគ្រាប់ដែលធ្លាក់មកពីលើយន្តហោះ។ «ខ្ញុំមើលឃើញគ្រាប់បែកមួយគ្រាប់នេះធ្លាក់ចំផ្ទះក្បឿងមួយខ្នងយ៉ាងធំ ដែលជាផ្ទះអ្នកមានទ្រព្យសម្បត្តិច្រើនជាងគេក្នុងភូមិតាកោ រួចគ្រាប់បែកនោះបានបន្តធ្លាក់ចូលទៅក្នុងដីក្បែរកម្ទេចកម្ទីផ្ទះនោះ។ ផ្ទះខ្ញុំ និងផ្ទះក្បឿងធំនោះ ស្ថិតនៅចម្ងាយប្រហែលមួយរយម៉ែត្រពីគ្នា។ បន្ទាប់ពីយន្តហោះទម្លាក់គ្រាប់បែកចេញទៅ ខ្ញុំបានចេញទៅមើលស្លាកស្នាម។ ពុំមានមនុស្សណាម្នាក់ស្លាប់ឡើយ ដោយសារតែម្ចាស់ផ្ទះបានចេញពីផ្ទះអស់ទៅហើយ។ ខ្ញុំឃើញរូងធំមួយ និងបានឃើញគូទ (ផ្នែកខាងក្រោយ) គ្រាប់បែកនៅក្នុងរូងនោះ។ វាមិនទាន់ផ្ទុះទេ។»

ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដៀន និងប្រពន្ធ ព្រមទាំងកូនបីនាក់បានវិលត្រឡប់មកកាន់ផ្ទះគាត់វិញ និងបន្តរស់នៅទីនោះពេញមួយរបបខ្មែរក្រហម ដោយមិនអើពើចំពោះវត្តមានគ្រាប់មិនទាន់ផ្ទុះនោះឡើយ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ដៀនបានផ្លាស់ប្តូរមករស់នៅលើដីដែលជាកន្លែងគ្រាប់បែកមិនទាន់ផ្ទុះកំពុងស្ថិតនៅនៅ



ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជារួមជាមួយអាជ្ញាធរមូលដ្ឋានយករទេះរុញជូនលោកតា នុត ដៀន អាយុ៨១ឆ្នាំ រស់នៅភូមិតាកោ សង្កាត់តាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឡើយ។ គាត់បានសាងសង់ផ្ទះនៅក្បែរទីងរណ្ដៅគ្រាប់នោះ ដោយមិនបានបារម្ភអ្វីឡើយ។ ថ្មីៗនេះ នៅពេលដែល ជៀន មានវ័យកាន់តែចាស់ គាត់កើតក្តីបារម្ភខ្លាចគ្រាប់ដែលមិនទាន់ផ្ទុះនោះ ផ្ទុះឡើងនៅថ្ងៃណាមួយនាពេលអនាគត ប្រសិនជាគ្រាប់នេះមិនត្រូវបានយកចេញទេ។ ជៀន បារម្ភពីសុវត្ថិភាពក្រុមគ្រួសារគាត់ជាខ្លាំង។

កាលពីប៉ុន្មានឆ្នាំមុន បុគ្គលិករបស់អង្គភាពកម្ចាត់មីនកម្ពុជា (ស៊ីម៉ាក់) បានមកពិនិត្យមើលពីស្ថានភាព និងទីតាំងគ្រាប់ម្តងរួចហើយ ប៉ុន្តែសកម្មភាពនេះបានស្ងាត់ទៅវិញរហូតដល់ពេលនេះ។ ជៀន បាននិយាយថា «ប្រធានភូមិតាកោ ធ្លាប់បានដឹកនាំក្រុមការងារដោះមីនមកមើលម្តងរួចហើយ។ ក្រុមនោះបានប្រាប់ថា ប្រសិនជាក្រុមការងារមកដឹកយកគ្រាប់នោះ គឺត្រូវរុះរើផ្ទះខ្ញុំសិន។ បន្ទាប់ពីដោះយកគ្រាប់ចេញរួចរាល់ គេសន្យាថានឹងសាងសង់ផ្ទះឱ្យខ្ញុំវិញ។ ប៉ុន្តែតាំងពីពេលនោះមក ខ្ញុំមិនដែលបានទទួលដំណឹង ឬឃើញមានវត្តមានរបស់ក្រុមនោះមកម្តងទៀតដែរ។ ប្រធានភូមិតាកោ ដែលបានដឹកនាំក្រុមនោះមកពិនិត្យមើលទីតាំងក៏បានស្លាប់បាត់ទៅទៀត។ ដូច្នេះ ខ្ញុំពុំមានសង្ឃឹមថា គ្រាប់នេះត្រូវបានយកចេញពីដីក្នុងបរិវេណផ្ទះរបស់ខ្ញុំឡើយ។» ជាមួយនឹងក្តីកង្វល់នេះ ជៀន បានបន្ថែមទៀតថា «ខ្ញុំបារម្ភថា ថ្ងៃណាមួយគ្រាប់នេះវានឹងអាចផ្ទុះឡើង ដោយសារតែមានការប៉ះពាល់វាពីសមាជិកគ្រួសារខ្ញុំ ដែលមិនបានដឹងរឿងនេះ។ ចៅៗខ្ញុំវាអាចនឹងធ្វើផ្ទះធំជាងនេះ ហើយនឹងត្រូវជីកគ្រឹះជ្រៅទៅក្នុងដី ដែលជាហេតុធ្វើឱ្យប៉ះនឹងគ្រាប់នេះ ហើយអាចធ្វើឱ្យផ្ទុះឡើងបំផ្លាញទាំងជីវិតមនុស្ស និងទ្រព្យសម្បត្តិរបស់ក្រុមគ្រួសារខ្ញុំ។» កូនៗទាំងអស់របស់ ជៀន បានដឹងថាមានគ្រាប់នៅក្នុងដីដែលមិនទាន់ផ្ទុះ។ ប៉ុន្តែចៅៗទាំងអស់ មិនបានដឹងរឿងនេះឡើយ។ សព្វថ្ងៃ ជៀន មានចៅទួតពីរបីនាក់ហើយ ហើយកំពុងរស់នៅក្នុងភូមិជាមួយគ្នា។

ព្រឹត្តិការណ៍សង្គ្រាម និងការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជា បានកន្លងផុតទៅអស់រយៈពេលជាង៥០ឆ្នាំហើយ។ គ្រាប់បែកនិងមីនរាប់លានគ្រាប់ ទាំងគ្រាប់ផ្ទុះហើយ និងគ្រាប់មិនទាន់ផ្ទុះ ត្រូវបានដោះចេញពីដីរួចរាល់ដើម្បីសង្គ្រោះជីវិតមនុស្ស លើកលែងតែគ្រាប់ ឬមីនទាំងឡាយណាដែលមិនទាន់មានអ្នកដឹង។ ក្រុមការងាររបស់ស៊ីម៉ាក់ កំពុងរុករកមីននៅក្នុងដី និងគ្រាប់មិនទាន់ផ្ទុះតទៅទៀត។ កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៤ កន្លងទៅនេះ កាសែតភ្នំពេញប៉ុស្តិ៍ បានចុះផ្សាយពីការសកម្មភាពដឹកយកក្បាលគ្រាប់អឹម១១៧ មិនទាន់ផ្ទុះមួយគ្រាប់ មានទម្ងន់៣៤០គីឡូក្រាម នៅក្នុងទឹកដីឃុំបុស្សខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ក្នុងជម្រៅដីប្រហែល៥ម៉ែត្រ។ ស្ថិតនៅព្រំប្រទល់ខេត្តជាប់គ្នា ប្រជាជនបានដឹងថា មានក្បាលគ្រាប់បែកយ៉ាងធំមួយគ្រាប់ ដែលមិនទាន់ផ្ទុះ ហើយកំពុងស្ថិតនៅក្នុងដីជាប់សំយ៉ាបផ្ទះរបស់ នុត ជៀន រស់នៅភូមិតាកោ សង្កាត់តាកោ ក្រុងព្រៃវែងនៅឡើយ។ គ្រាប់នេះ កំពុងក្លាយជាប្រធានបទនៃការរំខានដល់ការរស់នៅរបស់ម្ចាស់ផ្ទះ និងអ្នកភូមិឯទៀត អស់រយៈពេល៥២ឆ្នាំកន្លងមកហើយ ហើយការរំខាននេះនឹងបន្តទៅពេលអនាគតទៀត។ ជៀន បាននិយាយម្តងហើយម្តងទៀតថា «ខ្ញុំភ័យខ្លាចចំពោះស្រមោលអាមេរិកាំងនៅជាប់សំយ៉ាបផ្ទះខ្ញុំណាស់។ ខ្ញុំកំពុងរស់នៅក្នុងសភាពភ័យខ្លាចបំផុត។»



នុត ជៀន អាយុ៨១ឆ្នាំ រស់នៅភូមិតាកោ សង្កាត់តាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំ
## វេទិកាថ្នាក់រៀនស្តីពី ការជម្លៀសប្រជាជនដោយបង្ខំ ក្នុងរបបខ្មែរក្រហម ដល់សិស្សវិទ្យាល័យព្រែកដំបូក

**សាំង ចាន់ធូ**





សិស្សមកពីវិទ្យាល័យព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ៖ «ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម» ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ សិស្សានុសិស្សចំនួន៣០នាក់ មកពីវិទ្យាល័យព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម បានចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ៖ «ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម» ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ វេទិកាថ្នាក់រៀននេះរៀបចំឡើងក្នុងគោលបំណងជំរុញដល់ការយល់ឃើញ លើកកម្ពស់ការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលផ្តោតទៅលើព្រឹត្តិការណ៍នៃការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជានាពេលអនាគត។

មុនឈានដល់ការធ្វើបទបង្ហាញពីប្រវត្តិសាស្ត្រខ្មែរក្រហម សិស្សានុសិស្សទាំងអស់បានទស្សនាផ្ទាំងពិព័រណ៍អំពីប្រវត្តិរូបមេដឹកនាំខ្មែរក្រហម, ការជម្លៀសប្រជាជនដោយបង្ខំ, សកម្មភាពប្រជាជនធ្វើការងារតាមការដ្ឋានក្នុងរបបខ្មែរក្រហម និងរូបភាពមេដឹកនាំខ្មែរក្រហម ក្នុងដំណើរការនៃការកាត់ទោស

ដែលតាំងបង្ហាញនៅក្នុងបរិវេណខាងក្រោមមជ្ឈ-មណ្ឌលឯកសារខេត្តកំពង់ចាម។ ផ្នែកខាងក្នុងនៃមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម គឺមានបន្ទប់តម្កល់ឯកសារខ្មែរក្រហម សៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហម ដែលសិស្សានុសិស្សអាចមកសិក្សាស្រាវជ្រាវឈ្វេងយល់បន្ថែមក្រៅពីបានសិក្សាក្នុងថ្នាក់រៀន។ លើសពីនេះ ក៏មានការតាំងបង្ហាញព្រះឆាយាល័ក្ខណ៍ចំនួន១៨ផ្ទាំង ដែលជាផ្នែកនៃពិព័រណ៍ «ក្តីសុបិនកម្ពុជា» ដែលរៀបចំឡើងដោយព្រះរាជបណ្ណាល័យ ហ្វូងម៉ៃ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

ជាកិច្ចចាប់ផ្តើមនៃវេទិកាថ្នាក់រៀនលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានលើកអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលផ្តោតទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ រួមមាន៖ រដ្ឋប្រហាររបស់លន់ នល់ នៅក្នុងឆ្នាំ១៩៧០, ការផ្ទុះឡើងនូវសង្គ្រាមជិត៥ឆ្នាំរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម, ការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជនទៅកាន់ជនបទ, ជីវិតរស់នៅប្រចាំថ្ងៃ និងការកាប់សម្លាប់ទៅលើប្រជាជនក្នុងរបបខ្មែរក្រហម។ ប្រធានបទដែលផ្តោតសំខាន់ក្នុងវេទិកាថ្នាក់រៀននាថ្ងៃនេះ គឺការពិភាក្សាអំពីការជម្លៀសប្រជាជនដោយបង្ខំទាំង ៣ ដំណាក់កាលដែលខ្មែរក្រហមបានអនុវត្ត៖

- **ដំណាក់កាលទី១**៖ បន្ទាប់ពីចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហម ជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជននានាទៅកាន់ទីជនបទ។
- **ដំណាក់កាលទី២**៖ ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧ ប្រជាជននៅភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា (រួមមានខេត្តកណ្តាល កំពង់ធំ តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម) ត្រូវបានជម្លៀសដោយបង្ខំឱ្យផ្លាស់ទៅកាន់ខេត្តសៀមរាប ព្រះវិហារ និង ភូមិភាគពាយ័ព្យ (រួមមានខេត្តបាត់ដំបង ពោធិ៍សាត់ និងបន្ទាយមានជ័យ)។
- **ដំណាក់កាលទី៣**៖ ការជម្លៀសប្រជាជនពីភូមិភាគបូព៌ាចាប់ពីឆ្នាំ១៩៧៧ រហូតដល់ចុងឆ្នាំ១៩៧៨។ ប្រជាជននៅភូមិភាគបូព៌ាត្រូវបានជម្លៀសចេញពីភូមិផ្ទះទៅទិសពាយ័ព្យ (ខេត្តពោធិ៍សាត់ និង ខេត្តបាត់ដំបង)។

នៅចុងបញ្ចប់នៃបទបង្ហាញលោក ស៊ាង ចិន្តា ពន្យល់អំពីនិយមន័យ និងវិធីសាស្ត្រទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនៃអំពើប្រល័យពូជសាសន៍ និងចែកទស្សនាវដ្តីស្វែងរកការពិត ដែលចុះផ្សាយអំពីរឿងរ៉ាវ របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តកំពង់ចាម ជូនដល់សិស្សសម្រាប់អាន។ កម្មវិធីសំខាន់មួយទៀតបន្ទាប់ពីវេទិកាថ្នាក់រៀននេះ គឺការចុះទស្សនកិច្ចសិក្សាទៅកាន់ស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះក្នុងសហគមន៍ឃុំកោះសូទិន ស្រុកកោះសូទិនខេត្តកំពង់ចាម ដែលសិស្សានុសិស្សទាំងអស់អាចស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅមូលដ្ឋានផ្ទាល់។ ស្តូបរំឭកវិញ្ញាណក្ខន្ធសម្រាប់ជនរងគ្រោះសហគមន៍កោះសូទិន ស្ថិតនៅចំកណ្តាលចំការពោតនៅក្នុងភូមិទី៨ ឃុំកោះសូទិនស្រុកកោះសូទិនខេត្តកំពង់ចាម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឈ្មោះ ម៉ៅ វណ្ណា បានប្រាប់អំពីបទពិសោធន៍ និងការចងចាំអំពីការបាត់បង់ឪពុកម្តាយ និងបងប្អូនចំនួន ៣នាក់ ដែលត្រូវបានខ្មែរក្រហមចាប់យកទៅវាយសម្លាប់ទម្លាក់ចូលទន្លេមេគង្គជូនសិស្សានុសិស្សឱ្យបានដឹង។

បន្ទាប់ពីវេទិកាថ្នាក់រៀន និងដំណើរទស្សនកិច្ចសិក្សា សិស្សានុសិស្សបានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម៖

**ជា ផាន់និច** រៀនថ្នាក់ទី១១នៃវិទ្យាល័យព្រែកដំបូក ស្រុកស្រីសន្ធរ បានរៀបរាប់«ក្រោយពីបានចូលរួមវេទិកាថ្នាក់រៀនរួច ខ្ញុំទទួលបានចំណេះដឹងថ្មីអំពីប្រវត្តិសាស្ត្រក្នុងរបបខ្មែរក្រហម។ បន្ថែម

លើនេះទៀត ខ្ញុំបានស្ដាប់រឿងរ៉ាវរបស់អ៊ំស្រី ម៉ៅ វណ្ណា ដែលបានឆ្លងកាត់សម័យខ្មែរក្រហម និងការបាត់បង់សមាជិកគ្រួសារ។ ខ្ញុំនឹងយកចំណេះដឹង និងបទពិសោធន៍ថ្មីៗដែលខ្ញុំទទួលបាននៅថ្ងៃនេះទៅចែករំលែកបន្តទៀតជាមួយអ្នកនៅជុំវិញខ្លួនខ្ញុំ ក៏ដូចជាសួរនាំ លោកតា លោកយាយ របស់ខ្ញុំបន្តទៀតពីរបបខ្មែរក្រហម»។

**ស្រ៊ាង ម៉េងលី** រៀនថ្នាក់ទី១១នៃវិទ្យាល័យព្រែកដំបូក នៅក្នុងស្រុកស្រីសន្ធរ លើកឡើងថា «វេទិកាថ្នាក់រៀនផ្ដល់ចំណេះដឹង និងបទពិសោធន៍ថ្មីជាច្រើនដល់រូបខ្ញុំ។ ខ្ញុំយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមបានច្រើនជាងមុន ពីព្រោះក្រៅពីការរៀននៅក្នុងថ្នាក់រៀន និងការរៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមជាទ្រឹស្ដី វេទិកាថ្នាក់រៀនក្នុងថ្ងៃនេះបានផ្ដល់ឱ្យខ្ញុំមានឱកាសស្ដាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសួរនាំដោយផ្ទាល់ពីអ៊ំដែលគាត់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម។ ខ្ញុំនឹងចែករំលែកចំណេះដឹង និងការចងចាំល្អៗពីវេទិកាថ្នាក់រៀននាពេលនេះជាមួយមិត្តរួមថ្នាក់ និងលោកយាយរបស់ខ្ញុំ»។





សិស្សមកពីវិទ្យាល័យព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ចូលរួមវេទិកាថ្នាក់រៀនស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ៖ «ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម» ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំ

## វេទិកាស្រាវជ្រាវស្តីពី «ជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ដល់សិស្សវិទ្យាល័យស្គន់

**លី វេជវីត**







សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ស្គន់ ចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ៖ «ជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាស្រាវជ្រាវស្តីពី«ជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ដោយមានការចូលរួមពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឈ្មោះ ប៉ោង ព្រីន និងសិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន ស្គន់ ចំនួន ៤៥នាក់។ វេទិកាស្រាវជ្រាវនេះ ធ្វើឡើងដើម្បីផ្តល់ឱកាសដល់សិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយ ស្តាប់រឿងរ៉ាវផ្ទាល់ពីវាគ្មិនដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អំពីបទពិសោធន៍ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម និងការសិក្សាឈ្វេងយល់បន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) ដែលបានប្រព្រឹត្តអំពើឃោរឃៅទៅលើប្រជាជនកម្ពុជា។

ជាកិច្ចចាប់ផ្តើមលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានធ្វើបទបង្ហាញជាសង្ខេបអំពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) ផ្តោតទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ ចាប់ពីរដ្ឋប្រហារ លន់ នល់ នៅឆ្នាំ១៩៧០, ការឡើងកាន់អំណាចរបស់ខ្មែរក្រហម, ការជម្លៀស

ប្រជាជនដោយបង្ខំ, ការរស់នៅប្រចាំថ្ងៃរបស់ប្រជាជន និងការកាប់សម្លាប់ទៅលើប្រជាជនៗ កម្មវិធីបន្ទាប់ គឺជាកិច្ចសន្ទនាអន្តរជំនាន់រវាងវាគ្មិនឈ្មោះ ប៉ោង ព្រីន គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព និងសិស្សានុសិស្សដែលជាយុវជនជំនាន់អំពីស្ថានភាពរស់នៅ និងធ្វើការងារប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម។

លោក ប៉ោង ព្រីន ចាប់ផ្តើមរំឭកពីពេលវេលាមួយថ្ងៃដែលខ្មែរក្រហមបង្ខំឱ្យគាត់ធ្វើការងារដូចតទៅ ៖ ខ្ញុំពិការជើងម្ខាងដោយសារតែត្រូវគ្រាប់កាំភ្លើងពេលដែលមានការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម។ បើទោះបីជាខ្ញុំពិការជើងយ៉ាងណាក្តី ខ្មែរក្រហមបានបង្ខំឱ្យខ្ញុំធ្វើការងារដូចអ្នកភូមិផ្សេងទៀតដែរ។ ខ្ញុំត្រូវបានខ្មែរក្រហមប្រើឱ្យជីកដីកាប់ខស និងធ្វើកាមែលសម្រាប់សហករណ៍។ ខ្ញុំធ្វើការងារគ្រប់បែបយ៉ាងមិនមានពេលសម្រាក។ ខ្ញុំធ្លាប់ឃើញខ្មែរក្រហមដឹកមនុស្សយកទៅសម្លាប់ ធ្វើឱ្យខ្ញុំមានអារម្មណ៍តក់ស្លុតយ៉ាងខ្លាំង។ ខ្ញុំខិតខំធ្វើការងារទាំងដែលខ្លួនពិការ និងមិនហ៊ានប្រកែកឡើយ។ ខ្ញុំចង់ផ្តែផ្តាំដល់ចៅៗ ត្រូវតែចងចាំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលធ្វើបាបប្រជាជន មិនថាជាជនធម្មតា ឬជនពិការ គឺគ្មានការសណ្តោះប្រណីឡើយ។ ចៅត្រូវតែខិតខំរៀនសូត្រដើម្បីចូលរួមការពារកុំឱ្យរបបប្រល័យពូជសាសន៍កើតឡើងម្តងទៀត»។



ទូច វណ្ណេត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ធ្វើបទបង្ហាញដល់សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ស្គន់ ដែលមកចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ ៖ «ជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីការនិយាយចែករំលែកអំពីបទពិសោធន៍របស់លោក ប៉ោង ព្រីន ដែលជាជនពិការ និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម សិស្សានុសិស្សបានចោទជាសំណួរជាច្រើនទៅលើការចងចាំមិនភ្លេចពីការធ្វើបាបរបស់ខ្មែរក្រហម, ការជម្លៀសប្រជាជន និងស្ថានភាពសុខភាពប្រចាំថ្ងៃដល់វាគ្មិនៗ បន្ទាប់មកសិស្សានុសិស្សបានទៅទស្សនកិច្ចសិក្សាទៅកាន់ស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះក្នុងសហគមន៍ស្រុកកោះសូទិន និងស្រុកកំពង់សៀម ខេត្តកំពង់ចាម ដោយបានជួបសន្ទនាផ្ទាល់ជាមួយតំណាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំង២ទីតាំងៗ ស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះ គឺជាទីកន្លែងដែលផ្តល់ឱកាសដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមសម្រាប់ធ្វើការចែករំលែកបទពិសោធន៍ និងរឿងរ៉ាវដែលបានកើតឡើងក្នុងមូលដ្ឋានទៅកាន់យុវជន-យុវនារីដែលកើតក្រោយរបបខ្មែរក្រហម។

ខាងក្រោមនេះជាចំណាប់អារម្មណ៍របស់សិស្សានុសិស្សបន្ទាប់ពីចូលរួមវេទិកាស្រាវជ្រាវ និង ដំណើរទស្សនកិច្ចសិក្សា៖

**ខា រតនា** រៀនថ្នាក់ទី១០ នៃវិទ្យាល័យ ហ៊ុន សែន ស្គន់ នៅស្រុកជើងព្រៃ បានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនថា ៖ «ខ្ញុំទទួលបានចំណេះដឹងថ្មីៗ ទាក់ទងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ទាំងមេរៀន និងការស្តាប់រឿងរ៉ាវរបស់អ៊ំៗដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម។ ខ្ញុំបានឃើញការដាក់តាំងពិព័រណ៍រូបថតប្រវត្តិសាស្ត្រ។ អ្វីដែលខ្ញុំគិតថា ល្អខ្លាំងនោះ គឺការដែលអាចស្តាប់រឿងរ៉ាវរបស់លោកតា ប៉ោង ព្រីន ដែលបាននិយាយចែករំលែកបទពិសោធន៍ជីវិតផ្ទាល់របស់លោកតា។ លោកតា ប៉ោង ព្រីន រំឭកអំពីខ្សែជីវិតលំបាកវេទនារបស់ខ្លួន ចាប់តាំងពីការចូលប្រយុទ្ធក្នុងសង្គ្រាមរវាងកងកម្លាំងខ្មែរក្រហម និងកងទ័ព លន់ នល់, ការពិការជើងដោយសារតែកងទ័ពខ្មែរក្រហមបាញ់ត្រូវគាត់ និងការបង្ខំឱ្យគាត់ធ្វើការងារគ្មានពេលសម្រាក បើទោះបីជាគាត់ជាជនពិការក៏ដោយៗ ខ្ញុំនឹងយកចំណេះដឹងដែលខ្ញុំទទួលបាននាពេលនេះទៅចែករំលែកជាមួយមិត្តភក្តិ និងប្អូនៗជំនាន់ក្រោយ»។

**ស៊ង សុវណ្ណាវតី** រៀនថ្នាក់ទី១០នៃវិទ្យាល័យ ហ៊ុន សែន ស្គន់ នៅស្រុកជើងព្រៃ លើកឡើងថា ៖ «វេទិកាស្រាវជ្រាវនេះ គឺជាកម្មវិធីថ្មីមួយដែលខ្ញុំបានចូលរួម។ ខ្ញុំទទួលបានចំណេះដឹង និងការយល់ឃើញថ្មីចំពោះប្រវត្តិសាស្ត្រខ្មែរក្រហម និងជាពិសេសមានចិត្តអាណិតអាសូរដល់ប្រជាជនកម្ពុជាដែលរស់នៅឆ្លងកាត់សង្គ្រាម និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ តាមរយៈវេទិកានេះ ខ្ញុំមិនត្រឹមតែអាចរៀនមេរៀនប្រវត្តិសាស្ត្រខ្មែរក្រហម ទាំងទ្រឹស្តី និងការរៀនផ្ទាល់ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនោះទេ ខ្ញុំថែមទាំងអាចមានឱកាស សួរសំណួរជាច្រើនទៅកាន់លោកគ្រូ និងអ៊ំៗដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ បន្ថែមលើនេះទៀត ខ្ញុំបានចុះទៅសិក្សាស្វែងយល់ដោយផ្ទាល់នៅ ទីតាំងស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះនៃរបបខ្មែរក្រហមសម្រាប់សហគមន៍នៅភូមិគគរ និងភូមិកោះសូទិន។ បើទោះបីជា ទីតាំងសម្លាប់ប្រជាជននៅក្នុងមូលដ្ឋានទាំង២នេះក្លាយទៅជាដីចម្ការ និងលំនៅដ្ឋានរបស់ប្រជាជន ការចងចាំរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅតែបន្តដើម្បីនិយាយប្រាប់ក្មេងជំនាន់ក្រោយដូចជាខ្ញុំឱ្យបានដឹងទាំងអស់គ្នា»។

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំសិស្សវិទ្យាល័យ ហ៊ុន សែន ស្គន់ ទស្សនកិច្ចសិក្សាស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)







# ការិយាល័យព័ត៌មានសាធារណៈ















«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!














រូបក្របមុខ ៖
ប្លង់គោលវិទ្យាស្ថានស៊ីករីតដែលគូរដោយស្ថាបត្យករ ហ្សា ហា ហាឌីត
គឺជាស្ថាបនិកក្រុមហ៊ុន ហ្សា ហា ហាឌីត មានមូលដ្ឋាននៅប្រទេសអង់គ្លេស។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ ៖
លោក លី មីណា អភិបាលនៃគណៈអភិបាលស្រុកបុរីអូរស្វាយសែនជ័យ បានទទួលស្វាគមន៍ឯកឧត្តម សរ សុពុត្រា អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង និងគណៈប្រតិភូនៃដំណើរទស្សនកិច្ចមហាជន និងយុវជនខេត្តស្ទឹងត្រែង មកទស្សនកិច្ចសិក្សាស្រុកបុរីអូរស្វាយសែនជ័យ ជាប់ព្រំដែនប្រទេស ឡាវ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៤។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 296, August 2024 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.